# សាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University Of Law And Economics**

# សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបបទល្មើសលួចដោយប្រើហិង្សា

# និង

# ការកំហែងយក

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី ៣១ ឧសភា ឆ្នាំ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **សេង សែនភិរម្យ**

**ហេង គឹមហួរ**

សាស្ត្រាចារ្យណែនាំ

លោក **ហោ សុភ័ណ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំបាទ **សេង សែនតិរម្យ** និងខ្ញុំបាទ **ហេង គឹមហួរ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០១៧ ។

**សូមលំឱនកាយវាចាចិត្តដើម្បីសម្ដែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ ៖**

**លោកឪពុក សេង សារ៉ែម** — **លោកឪពុក ច័ន្ទ សុខហេង**

**អ្នកម្ដាយ គុយ វិបុលវណ្ណា** — **អ្នកម្ដាយ អ៊ុង ហេងស៊ីម**

ដែលបានផ្ដល់កំណើតសំរាប់ការរស់នៅ និងការសិក្សារបស់កូនរហូតទទួលបានការបញ្ចប់ការសិក្សាដោយជោគជ័យ។ គុណូបករៈរបស់លោកទាំងពីរមានទំហំធំធេង ពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់នូវភាពកក់ក្ដៅ សេចក្ដីស្រលាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានអោយដើរតាមគន្លងធម៌ ។មិនតែប៉ុណ្ណោះ លោកទាំងពីរបានទំនុកបំរុងថវិការ និងសិក្ខាបករណ៍ចាប់តាំងពី កម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្ដមសិក្សា ធ្វើអោយកូនចងចាំជានិច្ចមិនអាចបំភ្លេចបានឡើយ ។

ចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន** ដែលជាអគ្គមគ្គុទ្ទេសន៍ដ៏ឆ្នើម រួមជាមួយសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានបង្កអោយមានកាលានុវត្តភាពដ៏គាប់ប្រសើរ និងជម្រុញអោយសង្គមកម្ពុជាមានការអភិវឌ្ឍគ្រប់វិស័យទាំងអស់ រួមនឹងការរីកចំរើនវិស័យអប់រំផងដែរ ។

ចំពោះ**ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីទាំងអស់**ដែលជាសាស្ត្រាចារ្យបម្រើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលាព្រមទាំងកម្លាំងកាយចិត្តដល់យើងខ្ញុំទាំងពីរ ក្នុងរយៈពេល៤ឆ្នាំ ដើម្បីអោយយើងខ្ញុំទាំងពីរមានសមត្ថភាពយល់ដឹងផ្នែកនីតិសាស្ត្រ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់នៅក្នុងប្រទេសព្រមទាំងច្បាប់អន្តរជាតិថែមទៀត ។

ចំពោះលោកសាស្ត្រាចារ្យ **ហោ សុវ៉ណ្ណា** ជាសាស្ត្រាចារ្យណែនាំសារណារបស់យើងខ្ញុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីធ្វើការណែនាំផ្តល់យោបល់ និងកែនូវកំហុសដើម្បីជួយអោយសារណារបស់យើងខ្ញុំលេចចេញជារូបរាងឡើង និងទទួលបានជោគជ័យ ។

ជាចុងក្រោយយើងខ្ញុំទាំងពីរ សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុសក្តិសិទ្ធិក្នុងលោក សូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតា ឥន្ទព្រហ្មជួយអោយប្រទេសជាតិរបស់យើង រួមទាំងប្រជាជនទាំងអស់គ្នាជួបតែសន្តិភាព សុវត្ថិភាព និងអភិវឌ្ឍរីកចំរើនឆ្ពោះទៅមុខជានិរន្តន៍ ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី១៧ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៣ ដល់ ២០១៧ បានចំនាយរយៈពេល៤ឆ្នាំ ដ៏មានតម្លៃ ដើម្បីទទួលបាននូវចំណេះដឹង។ ក្នុងអំឡុងពេលនេះដែរ និស្សិតគ្រប់រូបទទួលបានចំណេះដឹងជាច្រើន ក្រោមការបង្ហាត់បង្រៀន ពីសាស្ត្រាចារ្យទាំងឡាយដែលបានចំណាយពេលវេលា និងបទពិសោធន៍របស់លោក ក្នុងការជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជម្រុញការអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើន ដូចបណ្តាប្រទេសដទៃ។

ទន្ទឹមនឹងនេះ ដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់សាស្ត្រាចារ្យ ក៏ដូចជាតម្រូវការចាំបាច់របស់សាកលវិទ្យាល័យ ដែលតម្រូវឲ្យនិស្សិតទទួលបានចំណាត់ថ្នាក់តាមការកំណត់ត្រូវរៀបចំជាសារណា ឬរបាយការណ៍ នៅពេលបញ្ចប់ការសិក្សា និងដើម្បីទុកជាស្នាដៃក៏ដូចជាឯកសារសម្រាប់ប្អូននិស្សិតជំនាន់ក្រោយ ធ្វើការស្រាវជ្រាវបន្ថែម។ នៅក្នុងឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំបានជ្រើសរើស និងរៀបចំតាក់តែង នូវសារណាក្រោមប្រធានបទ ការប្រៀបធៀបបទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក ដែលកើតចេញពីកិច្ចខិតខំ ប្រឹងប្រែង និងការព្យាយាមស្រាវជ្រាវ។ យើងខ្ញុំបានយកចិត្តទុកដាក់អស់ពីលទ្ធភាព សមត្ថភាព និងចំណេះដឹងដែលបានសិក្សាកន្លងមក រួមផ្សំនឹងការពិភាក្សា ក៏ដូចជាសុំយោបល់ពីសាស្ត្រាចារ្យមួយចំនួន បានសម្រេចចេញជារូបរាងសារណានេះឡើង។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលបានសរសេរ និងរៀបរៀងសារណានេះឡើង ក្រោមការណែនាំពីសាស្ត្រាចារ្យ **ហោ សុភ័ណ្ឌ**។ ស្នាដៃមួយនេះ យើងខ្ញុំសង្ឃឹមថា នឹងចូលរួមចំណែកក្នុងការសម្រួលដល់និស្សិត និងមិត្តអ្នកអាន ក្នុងការពង្រីកចំណេះដឹង ផ្តល់គំនិតបន្ថែមទៀត។

ជាទីបញ្ចប់ យើងខ្ញុំសង្ឃឹមថា មិត្តនិស្សិត និងមិត្តអ្នកអានទាំងអស់ ចូលរួមវាយតម្លៃ និងរិះគន់ក្នុងន័យស្ថាបនាឲ្យបានទាំងអស់គ្នា ដើម្បីរួបរួម សាមគ្គីបំពេញចន្លោះខ្វះខាត ដោយកំហុសអចេតនាផ្សេងៗនៅក្នុងសារណានេះផងដែរ។

# មាតិកា


**សេចក្តីផ្តើម** ..................................................... **០១**

**ជំពូកទី១ អំពើលួច** ..................................................... **០៥**

**កថាខណ្ឌទី១ សញ្ញាណទូទៅ** ..................................................... **០៥**

១. និយមន័យនៃអំពើលួច (ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩) ..................................................... ០៥

២. ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ..................................................... ០៥

**កថាខណ្ឌទី២ ធាតុផ្សំនៃអំពើលួច** ..................................................... **០៥**

១. ធាតុផ្សំនីត្យានុកូលនៃអំពើលួច ..................................................... ០៥

២. ធាតុផ្សំសត្យានុម័តនៃអំពើលួច ..................................................... ០៦

២.១ ស្តែងឡើងតាមរូបភាពជាការដកហូត ..................................................... ០៦

២.១.១ សញ្ញាណនៃការដកហូតដោយគ្មានសិទ្ធិ ..................................................... ០៨

២.១.២ សញ្ញាណនៃការដកហូតដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ..................................................... ០៩

២.២ ស្តែងឡើងតាមគ្រប់មធ្យោបាយ ..................................................... ១៥

២.៣ ស្តែងឡើងតាមការប្រើប្រាស់ថាមពលទុច្ចរិត ..................................................... ១៦

៣. ធាតុផ្សំអត្តនោម័តនៃអំពើលួច ..................................................... ១៧

៣.១ ចេតនាទុច្ចរិតទូទៅ ..................................................... ១៧

៣.២ ចេតនាទុច្ចរិតពិសេស ..................................................... ១៧

**កថាខណ្ឌទី៣ ទោសដែលត្រូវអនុវត្ត** ..................................................... **២៣**

១. ករណីគ្មានស្ថានទម្ងន់ទោស ..................................................... ២៣

២. ករណីមានស្ថានទម្ងន់ទោស ..................................................... ២៧

២.១ ប្រព្រឹត្តអំពើហិង្សា ..................................................... ២៧

២.២ ការកាត់អវយវៈ ឬពិការភាព ..................................................... ២៩

២.៣ ការធ្វើទារុណកម្ម និងអំពើឃោរឃៅ ..................................................... ៣០

២.៤ មរណភាពនៃជនរងគ្រោះ ..................................................... ៣០

៣. ទោសបន្ថែម ..................................................... ៣១

៤. អភ័យឯកសិទ្ធិគ្រួសារ ..................... ៣២
៥. ការប៉ុនប៉ងក្នុងបទលួច ..................... ៣៣
**ជំពូកទី២ ការកំហែងយក ..................... ៣៤**
**កថាខណ្ឌទី១ សញ្ញាណទូទៅ ..................... ៣៤**
១. និយមន័យ ..................... ៣៤
២. ច្បាប់ព្រហ្មទណ្ឌអន្តរកាល ..................... ៣៤
**កថាខណ្ឌទី២ ធាតុផ្សំនៃការកំហែងយក ..................... ៣៤**
១. ធាតុផ្សំនីត្យានុកូល ..................... ៣៤
២. ធាតុផ្សំសត្យានុម័ត ..................... ៣៥
២.១ រូបភាពនៃការព្រមព្រៀងប្រគល់ ..................... ៣៥
២.២ កម្មវត្ថុនៃការកំហែងយក ..................... ៣៦
២.៣ រូបរាងនៃអំពើ ..................... ៣៦
៣. ធាតុផ្សំអត្តនោម័ត ..................... ៣៧
**កថាខណ្ឌទី៣ ទោសដែលត្រូវអនុវត្ត ..................... ៣៨**
១. ករណីគ្មានស្ថានទម្ងន់ទោស ..................... ៣៨
២. ករណីមានស្ថានទម្ងន់ទោស ..................... ៣៩
២.១ ស្ថានទម្ងន់ទោសទាក់ទងជនរងគ្រោះ ..................... ៣៩
២.១.១ បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុ ..................... ៤០
២.១.២ បុគ្គលដែលជានារីមានគភ៌ ..................... ៤២
២.១.៣ បុគ្គលទន់ខ្សោយពិសេស ដោយមូលហេតុជម្ងឺ ឬពិការភាព ..................... ៤៣
២.២ ស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ..................... ៤៦
២.៣ ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព ..................... ៤៧
២.៤ ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ ..................... ៤៩
២.៥ ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ..................... ៥០
**ជំពូកទី៣ ការប្រៀបធៀបបទល្មើសទាំងពីរ ..................... ៥២**

**កថាខណ្ឌទី១ ភាពខុសគ្នា និងដូចគ្នា ........................................................ ៥២**

**១. ចំណុចដូចគ្នា** ........................................................ ៥២

១.១ នីត្យានុកូលភាពនៃបទល្មើស ........................................................ ៥២

១.១.១ ការចែងក្នុងគន្ថី ........................................................ ៥២

១.១.២ ការចែងក្នុងមាតិកា ........................................................ ៥៣

១.១.៣ ការចែងក្នុងជំពូក ........................................................ ៥៣

១.២ ប្រធាននៃបទល្មើស ........................................................ ៥៣

១.២.១ ជនល្មើស ........................................................ ៥៣

១.២.២ ជនរងគ្រោះ ........................................................ ៥៤

១.៣ លក្ខណៈនៃអំពើ ........................................................ ៥៤

១.៤ មធ្យោបាយប្រព្រឹត្តបទល្មើស ........................................................ ៥៤

១.៥ បច្ច័យនៃអំពើ ........................................................ ៥៤

**២. ចំណុចខុសគ្នា** ........................................................ ៥៥

២.១ ធាតុនីត្យានុកូល ........................................................ ៥៥

២.១.១ នីត្យានុកូលភាពនៃបទល្មើស ........................................................ ៥៥

២.១.២ នីត្យានុកូលភាពនៃទោស ........................................................ ៥៦

២.១.៣ ប្រភេទនៃបទល្មើស ........................................................ ៥៦

២.១.៤ អាជ្ញាយុកាល ........................................................ ៥៦

២.១.៤.១ អាជ្ញាយុកាលនៃទោស ........................................................ ៥៦

២.១.៤.២ អាជ្ញាយុកាលនៃបទល្មើស ........................................................ ៥៧

២.២ ធាតុសត្យានុម័ត ........................................................ ៥៧

២.២.១ រូបរាងនៃអំពើ ........................................................ ៥៧

២.២.២ លក្ខណៈនៃអំពើ ........................................................ ៥៨

២.២.៣ កម្មវត្ថុនៃបទល្មើស ........................................................ ៥៨

២.៣ ធាតុអត្តនោម័ត ........................................................ ៥៩

**កថាខណ្ឌទី២ មូលហេតុ និងវិធានការ ...... ៥៩**

**១. មូលហេតុ** ...... ៥៩

១.១ កត្តាច្បាប់ ...... ៥៩

១.២ កត្តាអប់រំ ...... ៥៩

១.៣ កត្តាបុគ្គល ...... ៦០

**២. វិធានការប្រឆាំង** ...... ៦១

២.១ វិធានការទប់ស្កាត់ ...... ៦២

២.១.១ អប់រំប្រជាជនតាមមូលដ្ឋាន ...... ៦២

២.១.២ ពង្រឹងវិស័យច្បាប់ ...... ៦៣

២.១.៣ ពង្រឹងស្ថាប័នដែលពាក់ព័ន្ធ ...... ៦៣

២.១.៤ បង្កើតមជ្ឈមណ្ឌលអប់រំ ...... ៦៣

២.១.៥ ស្ថេរភាពនយោបាយ ...... ៦៤

២.២ វិធានការបង្ក្រាប ...... ៦៤

២.២.១ ពង្រឹងជំនាញអាជ្ញាធរមានសមត្ថកិច្ច ...... ៦៤

២.២.២ ការអនុវត្តផែនការឲ្យមានប្រសិទ្ធិភាព ...... ៦៥

២.២.៣ លើកទឹកចិត្តដល់អាជ្ញាធរដែលបានសម្រេចភារកិច្ច ...... ៦៥

២.២.៤ ការសហការរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ...... ៦៥

**សេចក្តីសន្និដ្ឋាន ...... ៦៦**

**អនុសាសន៍ ...... ៦៩**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

៙៙📖៚៚

## លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើសកលលោក មិនថាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍នោះទេ បទល្មើសតែងតែកើតមាន ទោះកម្រិតនៃសកម្មភាពដែលប្រព្រឹត្តបទល្មើសនោះស្រាល ឬធ្ងន់ក៏ដោយ គឺវាអាស្រ័យទៅលើប្រទេសនោះ ដែលមានច្បាប់សម្រាប់អនុវត្តទៅលើបុគ្គលឲ្យមានការរាងចាល។ នៅក្នុងប្រទេសនីមួយៗ សុទ្ធសឹងតែមានការអនុម័តច្បាប់ ក្នុងគោលដៅកាត់បន្ថយអត្រានៃបទល្មើសដែលកើតមានឡើង ក៏ដូចជាការបង្ការដើម្បីឲ្យបុគ្គលនោះខ្លាចរអាក្នុងការប្រព្រឹត្ត។

នៅប្រទេសកម្ពុជាសព្វថ្ងៃ យើងឃើញថា មានការបង្កើតច្បាប់ជាច្រើន ទាំងច្បាប់គោល និងច្បាប់ពិសេស សម្រាប់ធ្វើការអនុវត្ត ទៅលើបុគ្គលដែលបានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងនោះគឺរួមមាន ក្រមព្រហ្មទណ្ឌដែលចូលជាធរមាននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយបានធ្វើការបែងចែកជា៦គន្ថី ដែលបានកំណត់ពីគោលការណ៍ទូទៅ និងបទល្មើសមួយចំនួនធំទៀតដែលក្នុងនោះរួមមានដូចជា បទល្មើសប្រឆាំងបុគ្គល បទល្មើសប្រឆាំងទ្រព្យសម្បត្តិ និងបទល្មើសប្រឆាំងនឹងជាតិ។

ចំពោះគន្ថីដែលចែងអំពីបទល្មើសប្រឆាំងទៅនឹងទ្រព្យសម្បត្តិ បានកំណត់នូវបទល្មើសជាច្រើនដោយតម្រូវឲ្យដាក់ទណ្ឌកម្មតាមក្រមព្រហ្មទណ្ឌ។ ជាពិសេស មានបទល្មើសពីរដែលតែងតែកើតមានឡើងជារឿយៗក្នុងចំណោមបទល្មើសទាំងនោះ គឺបទលួច និងការកំហែងយក ដែលបណ្តាលឲ្យប៉ះពាល់ដល់បុគ្គលដទៃ។

នៅក្នុងសារណាយើងខ្ញុំនេះ បានលើកយកនូវបទល្មើសចំនួនពីរគឺ បទលួចដោយប្រើហិង្សា និងការកំហែងយក សម្រាប់មកធ្វើការសិក្សាឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ អំពើកំហែងយកនេះគឺជាបទល្មើសថ្មីស្រឡាងមួយនៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន ដែលជាចំណុចមួយ គួរតែធ្វើការពិចារណា ក៏ដូចជាវែកញែកឲ្យកាន់តែជាក់លាក់ថែមទៀត ហើយអំពើនេះបានក៏ធ្លាប់បានចែងនៅក្នុងក្រមព្រហ្មទណ្ឌអន្តរកាល ដែលផ្តល់ឈ្មោះបទល្មើសនោះថា បទប្លន់ ។ មួយវិញទៀត នៅក្នុងបទល្មើសលួចដោយហិង្សា និងការកំហែងយក គឺមានលក្ខណៈស្រដៀងគ្នាដែលអាចធ្វើឲ្យអ្នកសិក្សាផ្នែកច្បាប់មួយចំនួនមានការភ័ន្តច្រឡំទៅលើចំនុចខ្លះៗនៅក្នុងផ្នែកមួយនេះ។ មូលហេតុទាំង

នេះហើយដែលជម្រុញឲ្យយើងខ្ញុំ ខិតខំចងក្រងជាឯកសារនេះឡើង ដើម្បីជាទុនមួយ ឲ្យនិស្សិតផ្នែកច្បាប់ទាំងអស់ ធ្វើការស្វែងយល់បន្ថែម កុំឲ្យមានការច្រលំគ្នា រវាងបទល្មើសទាំងពីរនេះ។

ដូច្នេះហើយទើបយើងខ្ញុំខំព្យាយាម តាក់តែងនិងរៀបចំសារណានេះឡើង ដែលមានចំណងជើងនៃប្រធានបទថា “**ការប្រៀបធៀបបទល្មើសលួចដោយហិង្សា និងការកំហែងយក**”។

## ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំណុចសំខាន់ដែលគួរតែសិក្សាស្រាវជ្រាវ បានផ្តោតទៅលើចម្ងល់មួយចំនួនទាក់ទងទៅនឹងអត្ថន័យនៃបទល្មើស និងការប្រៀបធៀបលក្ខណៈដូច និងខុសគ្នា។យើងខ្ញុំសូមលើកយកនូវចំណោទបញ្ហាមួយចំនួនដែលមានអត្ថន័យដូចតទៅៈ

-តើអ្វីទៅជាបទល្មើសលួច? និងមានលក្ខណៈពិសេសអ្វីខ្លះ?

-តើការកំហែងយកមានលក្ខណៈយ៉ាងដូចម្ដេច?

-ប្រៀបធៀប បទលួចដោយហិង្សា និងការកំហែងយក ?

-តើមានវិធានការអ្វីខ្លះ ដើម្បីទប់ស្កាត់បទល្មើសទាំងនោះ។

## កម្មវត្ថុនៃការស្រាវជ្រាវ

ការសម្រេចជ្រើសយកប្រធានបទនេះមកសរសេរ ព្រោះយើងខ្ញុំយល់ឃើញថាប្រធានបទនេះវាមានសារៈសំខាន់សង្គមបច្ចុប្បន្ន ទាំងផ្នែកសិក្សា និងការអនុវត្ត។ មួយវិញទៀតកម្មវត្ថុនៃការស្រាវជ្រាវ នឹងលើកមកបង្ហាញដូចខាងក្រោមៈ

-ស្វែងយល់អំពីលក្ខណៈនៃបទលួច ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ចាប់ពីមាត្រា ៣៥៣ ដល់មាត្រា ៣៦២។

-ស្វែងយល់អំពីលក្ខណៈនៃការកំហែងយក ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ចាប់ពីមាត្រា ៣៦៣ ដល់មាត្រា ៣៧១។

-ធ្វើការប្រៀបធៀបបទលួចដោយហិង្សា និងការកំហែងយក រួចទាញនូវចំណុចដូចគ្នា និងខុសគ្នានៃបទល្មើសទាំងពីរ។

-បង្ហាញវិធានការ ដើម្បីទប់ស្កាត់ការកើនឡើងនៃបទល្មើសទាំងពីរ។

-ធ្វើសេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ដើម្បីរួមចំណែកក្នុងការកែលំអ។

**ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ការស្រាវជ្រាវទៅលើប្រធានបទនេះបានសង្កត់ធ្ងន់ទៅលើលក្ខណៈផ្ទាល់នៃបទល្មើសដូចជា និយមន័យ ធាតុផ្សំនៃបទល្មើសនីមួយៗ ទោសដែលត្រូវអនុវត្ត និងការប្រៀបធៀបរវាងបទល្មើសទាំងពីរ បញ្ចូលទាំងចំណុចដូច និងចំណុចខុសគ្នា។

**គម្រោងនៃការស្រាវជ្រាវ**

គម្រោងនៃការស្រាវជ្រាវ បានធ្វើឡើងជាច្រើនដំណាក់កាលដូចជា៖

- ដំណាក់កាលទី១៖ ស្វែងយល់ពីទ្រឹស្តីទូទៅនៃក្រមព្រហ្មទណ្ឌ ស្វែងរកឯកសារដែលបានសិក្សាកន្លងមក និងឯកសារតាមបណ្ណាល័យ
- ដំណាក់កាលទី២៖ ប្រើជំនួយតាមប្រព័ន្ធអេឡិចត្រូនិច ដូចជាការប្រើគេហទំព័រ ប្រព័ន្ធអិនធឺណេត ។
- ដំណាក់កាលទី៣៖ ស្វែងយល់ពីលក្ខណៈនៃបទល្មើសនីមួយៗតាមការសិក្សានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
- ដំណាក់កាលទី៤៖ ធ្វើការវិភាគ និងសំយោគលើការបកស្រាយតាមរយៈសៀវភៅរបស់នីតិនិពន្ធនានា
- ដំណាក់កាលទី៥៖ កែតម្រូវ និងបន្ថែមខ្លឹមសារនៃអត្ថបទ
- ដំណាក់កាលទី៦៖ ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ ដើម្បីរួមចំណែកក្នុងការកែលម្អ

**វិធីសាស្ត្រនៃការស្រាវជ្រាវ**

ដើម្បីឲ្យសារណានេះទទួលបានប្រសិទ្ធិភាព យើងខ្ញុំបានសិក្សាស្រាវជ្រាវទៅលើឯកសារដែលពាក់ព័ន្ធជាច្រើន និងបានប្រមូលពត៌មានផ្សេងៗមកជាមូលដ្ឋានផងដែរ។ ប្រភពនានាដែលទទួលបាន យើងបែងចែកជាពីរប្រភេទគឺ៖ ឯកសារចម្បង និងឯកសារបន្ទាប់បន្សំ។

ឯកសារចម្បង៖

-ច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ )

-ឯកសារច្បាប់ជាគោលធំបំផុតគឺ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល

ឯកសារបន្ទាប់បន្សំ៖

-ឯកសារមេរៀនដែលធ្លាប់បានសិក្សាជាមួយសាស្ត្រាចារ្យទាំងឡាយ

-ឯកសារដែលទទួលបានពីសៀវភៅនីតិព្រហ្មទណ្ឌពិសេស

-ឯកសារបានមកពីការស្រាវជ្រាវតាមប្រព័ន្ធអិនធឺណេត

-ឯកសារដែលបានមកពីការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ

-ឯកសារដែលបានមកពីការណែនាំ និងពិភាក្សាជាមួយសាស្ត្រាចារ្យជំនាញផ្សេងទៀត

**សារៈសំខាន់នៃការស្រាវជ្រាវ**

អត្ថប្រយោជន៍នៃការស្រាវជ្រាវប្រធានបទនេះមានដូចជា៖

-ជាភស្តុតាងដែលបញ្ជាក់ពីស្នាដៃ ដែលបានខំសិក្សាអស់រយៈពេល៤ឆ្នាំ

-បណ្តុះគំនិត និងចំណេះដឹងផ្ទាល់ខ្លួនផ្នែកព្រហ្មទណ្ឌ ទៅលើបទល្មើសដូចដែលបានលើកឡើង។

-ចេះប្រៀបធៀប និងវែកញែកគោលបំណងនៃបទល្មើសអោយដាច់ពីគ្នា បញ្ចៀសការភ័ន្តច្រឡំ

-ជាប្រភពឯកសារបន្ថែម ក្នុងការស្វែងយល់ក្នុងក្រមព្រហ្មទណ្ឌសម្រាប់សាធារណៈជនមិត្តនិស្សិតទាំងឡាយ និងប្អូនៗជំនាន់ក្រោយ

-ជាឯកសារជំនួយសម្រាប់ស្វែងយល់បន្ថែមអំពីចំណុចដូច និងចំណុចខុសគ្នានៃបទល្មើស

# ជំពូកទី១

# អំពើលួច

## កថាខណ្ឌទី១ សញ្ញាណទូទៅ

### ១. និយមន័យនៃអំពើលួច (ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)

អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន[1]។ ម្យ៉ាងទៀតនោះ គឺត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឲ្យខូចប្រយោជន៍ដល់អ្នកដទៃ។

### ២. និយមន័យក្នុងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល

កាលពីច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលបានហៅអំពើនេះថាជា អំពើចោរកម្ម។ អំពើចោរកម្មដែលបានបញ្ញត្តិនៅក្នុងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលមានអត្ថន័យថា គ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយពុំមានស្ថានទម្ងន់ទោសដូចដែលមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ដដែលត្រូវមានទោសពីបទលួច[2]។

## កថាខណ្ឌទី២ ធាតុផ្សំនៃអំពើលួច

នៅក្នុងធាតុផ្សំនៃបទល្មើសនេះ យើងនឹងលើកនូវធាតុផ្សំសំខាន់ៗទាំងបីនៃបទល្មើសចោរលួច គឺ ១.ធាតុផ្សំនីត្យានុកូលនៃអំពើលួច ២. ធាតុផ្សំសត្យានុម័តនៃអំពើលួច ២.ធាតុផ្សំអត្តនោម័តនៃអំពើលួច ដែលមានខ្លឹមសារលំអិតទាំងស្រុងនៅខាងក្រោមះ

### ១. ធាតុផ្សំនីត្យានុកូលនៃអំពើលួច

ជាពិសេស នៅមុនពេលក្រមព្រហ្មទណ្ឌថ្មីនេះចូលជាធរមាន យើងក៏ឃើញថាមានបទល្មើសដែលនិយាយអំពីអំពើលួចនៅក្នុងមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលបានចែងអំពីអំពើចោរកម្ម ៖ គ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដោយពុំមានស្ថានទម្ងន់ទោស ដូចដែលមានចែងនៅក្នុងមាត្រា ៣៤ ត្រូវមានទោសពីបទលួច ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ ៥ ឆ្នាំ។ ចំពោះមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌថ្មីបានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃតាមគ្រប់

[1] មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[2] មាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ បើយើងប្រៀបធៀប មាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ជាមួយមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ គឺមានចំណុចខុសគ្នាច្រើន។ មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌនេះគឺ មានលក្ខណៈទូលំទូលាយ និងពេញលេញ ហើយច្បាស់លាស់ ដែលជាមូលដ្ឋានចេញមកពីក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំង ជាមួយនឹងយុត្តិសាស្ត្របើនិយាយជារួមគឺការអនុវត្តរបស់គេចំនួន២ (ពីរ) សតវត្ស ដើម្បីអាចធ្វើជាពីរឃ្លានេះ យកមកគ្រប់ដណ្តប់នូវសកម្មភាពសត្យានុម័តនៅក្នុងសង្គមជាច្រើនឥតគណនា ដែលចាត់ទុកថាជាអំពើលួច។ តែបើយើងមើលទៅក្នុងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលត្រង់មាត្រា ៤៣ គឺពុំមាននិយាយពីអ្វីទៅជាអំពើលួចនោះទេ គ្រាន់តែថាគ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ ក៏ប៉ុន្តែងណាទៅគឺជាអំពើលួចនោះ? ហើយតើអំពើលួចស្តែងឡើងនូវរូបភាពជាអ្វី នៅក្នុងសកម្មភាពជាក់ស្តែងនោះ? ដូច្នេះអត់មានថែងលំអិតដូចមាត្រានៃក្រមព្រហ្មទណ្ឌឡើយ។

## ២. ធាតុផ្សំសត្យានុម័តនៃអំពើលួច

តើការដកហូតវត្ថុដែលគេដាក់លើតុ ហើយយកទៅដាក់កន្លែងផ្សេងគឺជាអំពើលួចដែរឬទេ។

តើសកម្មភាពយកទូរស័ព្ទទៅថតចម្លងឯកសាររបស់ក្រុមហ៊ុន ឬរបស់អ្នកដទៃគឺជាអំពើលួចដែរឬទេ?

ដូច្នេះយើងអាចពិភាក្សានៅក្នុងមាត្រា ៣៥៣ បានផ្តល់នូវសញ្ញាណជាមូលដ្ឋាននៃអំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។អញ្ចឹងចាប់ផ្តើមពីដំបូងគឺអំពើលួចមានដូចតទៅៈ

### ២.១ ស្តែងឡើងតាមរូបភាពជាការដកហូត

ការដកហូតនេះ បើសញ្ញាណពីបុរាណរហូតដល់ឆ្នាំ២០០០ ជាងនេះ យុត្តិសាស្ត្ររបស់តុលាការបារាំង ក៏ដូចជានៅអឺរ៉ុបភាគច្រើន គឺត្រូវមានការបំលាស់ទីវត្ថុ។ ដូចនេះមានអំពើលួចលុះត្រាតែមានការបំលាស់ទីវត្ថុ ឬក៏ទ្រព្យសម្បត្តិ។ ហើយគេថែមទាំងវិភាគទៅដល់ថា តើវត្ថុណាខ្លះ ឬក៏ទ្រព្យសម្បត្តិណាខ្លះដែលអាចបំលាស់ទីបាន? ឥឡូវយើងចាប់ផ្តើមផ្តោតសំខាន់អំពី ចលនវត្ថុ គឺជាទ្រព្យដែលអាចបំលាស់ទីបាន ដូចជាទូរស័ព្ទ ម៉ូតូ ឡាន សម្ភារៈអ្វីផ្សេងៗ ឬចលនទ្រព្យដែលមានអត្តសញ្ញាណ ដែលសុទ្ធជាចលនទ្រព្យ។ រីឯ អចលនទ្រព្យ គឺជាទ្រព្យដែលយើងមិនអាចបំលាស់ទីបាន។ អចលនទ្រព្យនេះគឺ មានចែកជា ៣ (បី) ប្រភេទគឺអចលនទ្រព្យពីធម្មជាតិ ដូចជាដីធ្លី អាគារ

ដែលមិនអាចបំលាស់ទីបាន ក្រៅពីនេះមាន អចលនទ្រព្យតាមភ័ព្វវាសនា គឺមានសារជាតិដើមរបស់វាជាចលនទ្រព្យទេ ក៏ប៉ុន្តែវាត្រូវក្លាយទៅជាអចលនទ្រព្យដោយសារវាបានភ្ជាប់ទៅនឹងអចលនទ្រព្យពីធម្មជាតិ ដូចជាភ្ជាប់ទៅនឹងអាគារ ឬលើកឡើងដើម្បីលម្អនូវអាគារជាដើម ករណីផ្ទាំងក្តារខៀន សម្រាប់សរសេរនៅសាលារៀនជាដើម បើតាមអត្ថន័យនៃអចលនទ្រព្យតាមភ័ព្វវាសនា គឺគេចាត់ទុកវាថាជាប្រភេទអចលនទ្រព្យហើយ និងចុងក្រោយនោះគឺ អចលនទ្រព្យតាមចំណាត់ថ្នាក់របស់ច្បាប់ មានដូចជានាវាដែលមានចំណុះប៉ុន្មានតោនឡើងទៅត្រូវកំណត់ថាជាអចលនទ្រព្យដែរ។

បើយោងតាមយុត្តិសាស្ត្ររបស់តុលាការប្រទេសបារាំង បានកំណត់ថា អចលនទ្រព្យតាមភ័ព្វវាសនា និងអចលនទ្រព្យតាមចំណាត់ថ្នាក់របស់ច្បាប់នេះ ក៏អាចជាកម្មវត្ថុនៃអំពើលួចដែរដោយសារតែពួកវាអាចបំលាស់ទីបាន។

ម្យ៉ាងវិញទៀត ចំពោះវត្ថុ គឺនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ ត្រង់មាត្រា ១១៩ បានឲ្យនិយមន័យយ៉ាងច្បាស់ថា វត្ថុសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង។ នៅក្នុងមាត្រាបន្ទាប់នោះ គឺមាត្រា២០០ បានបញ្ជាក់ថាវត្ថុត្រូវបានចែកជាពីរគឺ ចលនវត្ថុ និងអចលនវត្ថុ។

អចលនវត្ថុ សំដៅទៅលើដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ទីកន្លែងបានដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិជាអាទិ៍។ រីឯ ចលនវត្ថុ សំដៅលើវត្ថុក្រៅពីអចលនវត្ថុ។ នេះគឺជាចំណុចចាប់ផ្តើមទីមួយ ឬជាមូលដ្ឋានទីមួយ ដែលយើងពិភាក្សាអំពីការលួចគឺមានការបំលាស់ទីវត្ថុឬទ្រព្យសម្បត្តិ។ ហើយយើងត្រូវធ្វើការវិភាគទៅលើវត្ថុណាខ្លះដែលអាចបំលាស់ទីបាន និងត្រូវវិភាគទៅលើវត្ថុណាខ្លះ ដែលអាចចាប់កាន់ហើយបំលាស់ទីបាន។ តែវត្ថុខ្លះវាពុំមានរូបរាងទេ គឺយើងមិនអាចបំលាស់ទីបានឡើយ ដូច្នេះហើយបានជាទិន្នន័យនៅក្នុងកុំព្យូទ័រ ឬក៏ពត៌មានផ្សេងៗពុំមានអំពើលួចចំពោះអរូបទ្រព្យទេ ឬអរូបវត្ថុនោះឡើយ។ នៅក្នុងក្រមរដ្ឋប្បវេណីយើងគឺបានចែកជាវត្ថុ និងអរូបវត្ថុផងដែរ។ រូបវត្ថុគឺជាវត្ថុដែលមានរូបវន្តរបស់វាគឺអាចចាប់កាន់បាន ចំណែកឯអរូបវត្ថុ គឺជាសារជាតិរបស់វា គឺពុំមានរូបជាក់ស្តែងទេ ប៉ុន្តែវាជាប្រភេទនៃទ្រព្យសម្បត្តិដែលជាវត្ថុដូចជាទិន្នន័យនៅក្នុងកុំព្យូទ័រ ពត៌មាន កម្មសិទ្ធិបញ្ញាជាអាទិ៍ដែលយើងពុំអាចចាប់កាន់បាន។

ឧទាហរណ៍ ៖ រូបថតមួយនៅក្នុងប្រព័ន្ធទូរស័ព្ទ ដែលខ្ញុំបានថតឯកសារ ឬក៏រូបថតសម្ងាត់មួយចំនួនពាក់ព័ន្ធជាមួយនឹងអាជីពរបស់ខ្ញុំ ឬពាក់ព័ន្ធជាមួយសកម្មភាពនៃជីវភាព

ឯកជនរបស់ខ្ញុំ។ ស្រាប់តែមានអ្នកណាម្នាក់ គាត់មកដល់ ក៏បានយកទូរស័ព្ទ ដោយគ្មានការអនុញ្ញាតពីខ្ញុំទេ ហើយគាត់ក៏បញ្ជូនរូបថត និងឯកសារចេញពីទូរស័ព្ទរបស់ខ្ញុំ។

តើសកម្មភាពនេះគឺជាអំពើលួចដែរឬទេ។ ពីព្រោះបើយើងពិនិត្យទៅឃើញថារូបថត និងឯកសារ វាស្ថិតនៅក្នុងទូរស័ព្ទខ្ញុំដដែល ហើយពុំត្រូវបានបំលាស់ទីនោះទេ? បន្តិចទៀតយើងនឹងពិភាក្សាលំអិតចំពោះករណីនេះ។ រឿងនេះគឺផ្តើមចេញអំពីករណីដែលមានបុគ្គលិកក្រុមហ៊ុនម្នាក់បានថតចម្លងឯកសារពាក់ព័ន្ធជាមួយពត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ បើទាក់ទងជាមួយនឹងការដកហូតនេះ គឺយើងត្រូវពិនិត្យទៅលើពាក្យមួយទៀតគឺដោយទុច្ចរិត ការដកហូតដោយទុច្ចរិតនេះ មានន័យថា សំដៅដល់ពេលដែលចាប់កាន់វត្ថុ ឬបំលាស់ទីវត្ថុនោះ ជនល្មើសបានធ្វើសកម្មភាពដោយមិនស្របច្បាប់ គឺគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ឬដោយគ្មានសិទ្ធិតែម្តង។ ដូច្នេះ តើក្នុងស្ថានភាពណាដែលចាត់ទុកថាការដកហូតដោយទុច្ចរិតនោះ?

ឧទាហរណ៍ៈ យើងចូលទៅញុំាគុយទាវនៅហាងមួយ ហើយយើងភ្លេចទូរស័ព្ទនៅលើតុ ពេលដើរទៅដល់ឡានមួយសន្ទុះ ស្រាប់តែឃើញដល់ទូរស័ព្ទ ក៏ដឹងថាភ្លេចនៅលើតុ រួចក៏ត្រលប់មករកវិញ តែពេលមកដល់ក៏បាត់ទូរស័ព្ទនោះបាត់ទៅ។ ពេលទៅសួរកន្លែងអ្នកគេគិតលុយ គេប្រាប់ថា អ្នករត់តុគាត់រើសបាន ហើយយកមកទុកឲ្យយើងវិញ ពីព្រោះពេលនោះហៅយើងមិនទាន់។

សួរថាតើសកម្មភាពនេះគឺជាអំពើលួចដែរឬទេ? អត់មែនទេ ព្រោះគ្មានគំនិតទុច្ចរិត។ មានករណីមួយទៀត គឺអ្នកអង្គុយក្បែរតុយើងហូបគុយទាវនោះ គាត់បានយកដាក់ហោប៉ៅខោអាវរបស់គាត់ ពេលទៅដល់យើងសួរអ្នករត់តុ គេប្រាប់ថាអ្នកនោះបានយកដាក់ហោប៉ៅគាត់ហើយ។ ពេលយើងសួរ គាត់ឆ្លើយថាគាត់រើសបាន និងមិនឲ្យត្រលប់មកយើងវិញទេ នេះគឺជាអំពើលួចហើយពីព្រោះគាត់មានគំនិតទុច្ចរិតដកហូតនូវទ្រព្យសម្បត្តិរបស់គេ។

ដូច្នេះ សញ្ញាណនៃការដកហូតដោយទុច្ចរិតនេះ គឺមានសញ្ញាណនៃការដកហូតដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ និងសញ្ញាណនៃការដកហូតដោយគ្មានសិទ្ធិ។

### ២.១.១ សញ្ញាណនៃការដកហូតដោយគ្មានសិទ្ធិ

ឥឡូវយើងចាប់ផ្តើមសិក្សាអំពីសញ្ញាណនេះដូចតទៅ ៖ ក្នុងករណីមានដូចជា នៅភោជនីយដ្ឋានគេបានចាត់ទុកដោយបែងចែករវាងភ្ញៀវ ជាមួយនឹង អ្នកគ្រប់គ្រងទីកន្លែង។អ្នកគ្រប់គ្រងទីកន្លែងនេះ

អាចមានទាំងអ្នករត់តុ ឬក៏អ្នកគិតលុយនេះ គឺគេចាត់ទុកថាជាអ្នកគ្រប់គ្រងទីកន្លែងហើយ ជាធម្មតាគាត់មានសិទ្ធិយកវត្ថុរបស់ភ្ញៀវដែលភ្លេចនៅក្នុងហាងរបស់គាត់ដើម្បីរក្សាទុកជូនភ្ញៀវនោះវិញ នេះគឺដោយសារតែគាត់ជាអ្នកគ្រប់គ្រងហាងហ្នឹង។ ដូច្នេះគាត់អាចមានសិទ្ធិបំលាស់ទីវត្ថុបាន ហេតុនេះបើក្នុងសកម្មភាពដែលគ្រាន់តែគាត់យកមកទុកជូនភ្ញៀវនេះ គឺច្បាប់ពុំចាត់ទុកថាជាការដកហូតដោយទុច្ចរិតនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើអ្នករត់តុ គាត់ផ្តេសផ្តាស់គឺបន្ទាប់ពីយកទុកហើយក្រោយមកគាត់យកទៅផ្ទះរបស់គាត់ ដល់ពេលអញ្ចឹងគឺចេញទៅជាបទល្មើសនៃអំពើលួចហើយ គឺបានន័យថា មានគួបផ្សំនូវគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

### ២.១.២ សញ្ញាណនៃការដកហូតដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ

ចំណុចមួយទៀត គឺទាក់ទងជាមួយនឹងឧទាហរណ៍ខាងលើ ដែលពាក់ព័ន្ធទៅនឹងភ្ញៀវដែលនៅអង្គុយតុក្បែរគ្នានោះ បើកាលណាគេភ្លេចរបស់របរ ហើយគាត់យកទៅដាក់ក្នុងកាបូប ឬក្នុងហោប៉ៅ នេះគឺជាការដកហូតដោយទុច្ចរិត ពីព្រោះទីមួយ គាត់ពុំមានសិទ្ធិនៅក្នុងការបំលាស់ទីវត្ថុនៅលើតុ ឬវត្ថុផ្សេងៗរបស់ភ្ញៀវផ្សេងទៀតបានឡើយ ទីពីរប្រសិនបើម្ចាស់គេមកទារវិញ គាត់មិនឲ្យគេនោះមិនមែនជាការរើសបានវត្ថុនោះទេ វាគឺជាអំពើលួចតែម្តង។

ភ្ជាប់ជាមួយសញ្ញាណនេះ គឺមានសញ្ញាណ ២ (ពីរ) ទៀតដែលត្រូវពិភាក្សាអំពីវត្ថុដែលគេចាត់ទុកថាមានវត្ថុពីរទៀតគឺ វត្ថុដែលជ្រុះបាត់ និង វត្ថុដែលគេបោះបង់ចោល។ អញ្ចឹងដើម្បីអាចភ្ជាប់ជាមួយនឹងសញ្ញាណវត្ថុ ដែលយើងមាននៅក្នុងក្រមរដ្ឋប្បវេណីត្រង់មាត្រា១៩១ គឺវត្ថុដែលជ្រុះបាត់។ ក្នុងយុត្តិសាស្ត្ររបស់តុលាការបារាំងបានបកស្រាយថា ៖

**វត្ថុដែលជ្រុះបាត់** គឺជាវត្ថុដែលវង្វេងបាត់ពីកន្លែង បានន័យថា ម្ចាស់វត្ថុអត់ដឹងថាទុកនៅទីកន្លែងណា ឬជ្រុះនៅទីណាឡើយ ឬម្ចាស់វត្ថុមិនដឹងជាក់ពីកន្លែង ដែលខ្លួនបានទុកនូវវត្ថុរបស់ខ្លួនទេ។ ដូច្នេះកន្លែងនៅក្នុងតុគុយទារនេះ ប្រសិនបើជាម្ចាស់គាត់ដឹងថាគាត់បានទុកនៅលើតុគុយទារហើយគាត់ទៅបន្ទប់ទឹក ស្រាប់តែត្រឡប់មកវិញបាត់ ឬក៏គាត់ប្រញាប់ទៅជួបពិភាក្សាការងារសំខាន់ជាមួយអ្នកដទៃនៅក្រៅហាងមួយភ្លែត ពេលត្រឡប់មកវិញក៏បាត់ គឺមិនមែនជាករណីជ្រុះបាត់នោះទេ ពីព្រោះគាត់ដឹងថាគាត់ភ្លេចលើតុ។ ប៉ុន្តែសម្រាប់វត្ថុជ្រុះបាត់ គឺត្រូវជ្រុះនៅទីកន្លែងជាសាធារណៈ ដូចជានៅលើផ្លូវសាធារណៈ ឬក៏នៅសួនច្បារសាធារណៈជាដើម។ ហើយគេត្រូវបែង

ចែកទៀតថា ជាគោលការណ៍បើវត្ថុណាដែលម្ចាស់ដឹងកន្លែងទុក គេមិនចាត់ទុកថាជាវត្ថុជ្រុះបាត់នោះទេ។ មានការជជែកគ្នារវាងខ្មែរ និងបារាំង ខ្មែរយើងថានៅស្រុកខ្ញុំបើវាជ្រុះបាត់ ពេលគេរើសបានគេថារបស់គេហើយ។ ម៉្យាងទៀត បើអ្នកឯងភ្លេច ទោះស្គាល់កន្លែងក៏ដោយ មិនស្គាល់កន្លែងក៏ដោយឲ្យតែគេរើសបានគេថារបស់គេហើយ។ ឯខាងបារាំងគេបាននិយាយថា បើខ្មែរយើងគិតអំពីសញ្ញាណហ្នឹង យើងក៏អាចពិចារណាអំពីឡាន ម៉ូតូដែលគេចតនៅតាមផ្លូវសាធារណៈនោះ តើយើងអាចចាត់ទុកថាជារបស់ដែលគេជ្រុះបាត់បានដែរឬក៏អត់ បើពួកវាស្ថិតនៅលើផ្លូវសាធារណៈផងដែរ? ពីព្រោះនៅស្រុកគេ ភាគច្រើនឡាន ម៉ូតូ គឺមិនសូវមានកន្លែងផ្ទះទុកឲ្យចូលចតនោះទេ។ តាមពិតឡាន ម៉ូតូនោះមិនមែនជាវត្ថុដែលជ្រុះបាត់ទេ ដោយសារតែម្ចាស់ដឹងច្បាស់អំពីកន្លែងដែលគេចតទុកនោះ។

ជាគោលការណ៍ចំពោះវត្ថុដែលជ្រុះបាត់ អ្នកដែលរើសបានមានកាតព្វកិច្ចត្រូវយកទៅប្រគល់ឲ្យនៅកន្លែងសាលាឃុំ សាលាសង្កាត់ នៅប៉ុស្តិ៍នគរបាល ឬកន្លែងសាធារណៈផ្សេងៗដូចជានៅស្ថានីយ៍រថភ្លើង គឺគេមានការិយាល័យសម្រាប់ទទួលវត្ថុដែលរើសបានក្នុងរយៈពេល១សប្តាហ៍នេះគឺករណីនៅប្រទេសបារាំង។ ក៏ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីយើងបានប្រគល់សមត្ថកិច្ចនៅក្នុងការរក្សាទុកនូវវត្ថុដែលជ្រុះបាត់នេះ ទៅប៉ុស្តិ៍នគរបាលរដ្ឋបាលនេះ បើយោងតាមមាត្រា ១៩១។ ទាក់ទងនឹងមាត្រា១៩១ យើងសូមសរសេរជូនតែម្តង៖

១/ អ្នកដែលបានរើសវត្ថុដែលអ្នកដទៃបានបាត់ ប្រសិនបើដឹងកម្មសិទ្ធិករនៃវត្ថុនោះច្បាស់លាស់ត្រូវប្រគល់វត្ថុនោះឲ្យកម្មសិទ្ធិករវិញ ហើយប្រសិនបើមិនដឹងកម្មសិទ្ធិករនៃវត្ថុនោះច្បាស់លាស់ទេ ត្រូវប្រគល់វត្ថុនោះជូនប្រធានប៉ុស្តិ៍នគរបាល ក្នុងអំឡុងពេល៧ (ប្រាំពីរ)ថ្ងៃ ក្រោយពេលបានរើស។

២/ ប្រធានប៉ុស្តិ៍នគរបាល ត្រូវរក្សាទុកនូវវត្ថុរើសបាននោះ ហើយប្រកាសជាសាធារណៈ ហើយប្រសិនបើមិនឃើញមានកម្មសិទ្ធិករក្នុងអំឡុង ៦(ប្រាំមួយ)ខែ ទេ អ្នករើសត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ។ ប៉ុន្តែប្រសិនបើអ្នករើស មិនបានប្រគល់ជូនទៅប្រធានប៉ុស្តិ៍នគរបាល ក្នុងអំឡុងពេល៧(ប្រាំពីរ)ថ្ងៃ ក្រោយពេលបានរើសទេ អ្នករើសនោះ មិនអាចធ្វើលទ្ធកម្មលើវត្ថុបានទេ ហើយវត្ថុនោះត្រូវធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋ។បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែល

អ្នករើសមិនមកយកវត្ថុរើស ឬក្នុងអំឡុងពេល ២(ពីរ)ខែ ក្រោយពេលខ្លួនបានធ្វើលទ្ធកម្មកម្មសិទ្ធិទៅលើវត្ថុនោះ។

៣/ ប្រសិនបើវត្ថុរើសបាននោះជាវត្ថុដែលមិនអាចទុកយូរបាន ប្រធានប៉ុស្តិ៍នគរបាលអាចលក់វត្ថុនោះ ហើយរក្សាទុកនូវប្រាក់លក់នោះបាន។ ការចាត់ចែងប្រាក់លក់នេះ ត្រូវធ្វើដូចគ្នានឹងការចាត់ចែងវត្ថុរើស។

បមគាត់ហើយ។ ដូច្នេះនារីនោះចង់ពាក់សក់វែងរបស់គាត់វិញ ពេលមកជួបជាង គេប្រាប់ថាសក់នោះគេបានប្រមូលយកទៅលក់បាត់ហើយ។ ហេតុនេះ ក៏កើតមានការប្តឹងផ្តល់នៅតុលាការទៅ ដោយម្ចាស់សក់លើកឡើងថា សក់នេះគឺជាបំណែកចេញពីសក់គាត់ ហើយជាងយកទៅ ដោយមិនបានសុំគាត់ទេ។ អញ្ចឹងនៅកន្លែងកាត់សក់ ឬកន្លែងជាងផ្សេង ចំពោះវត្ថុដែលជាបំណែកចេញពីវត្ថុចម្បង ដូចជាសក់នេះ ពេលណាកាត់ចេញពីខ្លួនមនុស្សទៅ គេហៅថាជាវត្ថុធម្មតា ហើយមិនមែនជាសរីរាង្គនោះទេ។ ដូច្នេះប្រសិនបើជានៅពេលដែលទៅកាត់សក់ ម្ចាស់សក់មិនបានបង្ហាញឆន្ទៈថាសក់នោះត្រូវទុកអោយខ្ញុំវិញ។ បើមិនដូច្នេះទេ គឺសក់នោះត្រូវបានទៅជាកម្មសិទ្ធិរបស់ជាង។ មួយទៀត បើយើងយកក្រណាត់ទៅកាត់ ឬយកឈើទៅធ្វើ ហេតុនេះបំណែកក្រណាត់ បំណែកឈើ ត្រូវប្រាប់ជាងថាទុកអោយខ្ញុំវិញ។ បើមិនដូច្នេះទេ គឺអត់បានមកវិញដូចករណីសក់អញ្ចឹង។ ទាំងនេះគឺមានយុត្តិសាស្ត្រក្នុងករណីដែលទាក់ទងជាមួយនឹងវត្ថុដែលជាបំណែកនៃវត្ថុចម្បង។

សម្រាប់វត្ថុដែលគេរើសបាននៅក្នុងធុងសម្រាម ឬគំនរសម្រាម មានយុត្តិសាស្ត្រមួយទៀតទាក់ទងជាមួយនឹងការរើសបានទូរស័ព្ទចាស់ អត់មានស៊ីម។ គេថាទូរស័ព្ទដែលគ្មានស៊ីមនេះ គ្រប់ប្រព័ន្ធដំណើរការរបស់វា មិនមែនជាទូរស័ព្ទចល័តនោះទេ។ ដូច្នេះវាគ្រាន់តែជាប្រអប់ ឬរបស់ដែលគេបោះបង់ចោល ព្រោះមិនមានតម្លៃឡើយ ហេតុនេះទើបគេចាត់ទុកថាជារបស់ដែលបោះបង់ចោល។ ក្រោយមកក៏មានយុត្តិសាស្ត្រមួយផ្សេងទៀត គឺទាក់ទងជាមួយនឹងស្រោមសំបុត្រ ព្រោះក្រុមហ៊ុនខ្លះគាត់មើលស្រោមសំបុត្ររួច ជូនកាលគាត់ប្រមូលឯកសារនៅក្នុងស្រោមសំបុត្រទៅពេលខ្លះមាន

លុយ ជូនកាលមានសែក ហើយដាក់ចូលទៅធុងសម្រាម។ ដូច្នេះក៏មានយុត្តិសាស្រ្តថា នៅកន្លែងអាគាររបស់ក្រុមហ៊ុនមួយៗ គឺគេមានធុងសម្រាមសាធារណៈរបស់គេ។ ហេតុនេះ នៅក្នុងករណីដែលធុងសម្រាម អត់ទាន់មានបំលាស់ទីចេញ ទៅកន្លែងដើម្បីឲ្យក្រុមហ៊ុនប្រមូលសម្រាមយកចេញនោះទេ គឺជាចុងក្រោយ គេមិនទាន់ចាត់ទុកថាជាវត្ថុដែលគេបោះបង់ចោលឡើយ ពីព្រោះថាទុកសម្រាមនៅក្នុងអាគារ ឬនៅក្នុងផ្ទះរបស់គេ គឺម្ចាស់គេអាចផ្លាស់ប្តូរចិត្តវិញបាន។ ដូច្នេះគឺអាចទាក់ទងជាមួយនឹងការចោល ទៅច្រឡំចោលសែក ច្រឡំចោលលុយ ឬឯកសារសំខាន់ៗជាដើមនេះគឺទាក់ទងជាមួយនឹងវត្ថុ។

ឥឡូវចូលទៅដល់ ការដកហូតទុច្ចរិតវិញ គឺមានពេលខ្លះ ជនសង្ស័យពុំបានទៅដកហូតទ្រព្យសម្បត្តិដោយផ្ទាល់នោះទេ ពីព្រោះវត្ថុ ឬទ្រព្យសម្បត្តិនោះ ត្រូវបានមកដល់ដៃយើងដោយមានការភ័ន្តច្រឡំ។

ឧទាហរណ៍ ៖ ពេលដែលយើងទៅកន្លែងស្តាម៉ាតនៃស្ថានីយ៍ប្រេងឥន្ធនៈមួយ យើងចាក់សាំងរួចបញ្ឈោះឡានចោល ហើយដើរចូលស្តាម៉ាតនោះ និងទិញឥវ៉ាន់ រួចយកទៅកន្លែងអ្នកគិតលុយ គឺអស់២ដុល្លារ តែខ្ញុំច្រឡំឲ្យក្រដាស២០ដុល្លារទៅ ហើយដោយសារតែប្រញាប់ផងក៏ចេញទៅចូលក្នុងឡានបាត់។ ពេលនោះអ្នកគិតលុយឃើញខ្ញុំអោយលុយលើស គាត់អត់អាប់លុយឲ្យខ្ញុំវិញទេពីព្រោះពេលខ្ញុំរត់ចេញមក គាត់ក៏នូវស្ងៀមដោយអត់បានហៅខ្ញុំវិញទេ។ ក្រោយមកគាត់យក២ដុល្លារដាក់ចូលក្នុងហិបលុយរបស់ក្រុមហ៊ុន និងសល់ ១៨ដុល្លា គាត់ដាក់ក្នុងហោប៉ៅរបស់គាត់។

តើទង្វើនេះគឺជាអំពើលួចដែរឬទេ? យើងឃើញថាមានធាតុផ្សំក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនទៀតផង។ ភ្ជាប់ជាមួយឧទាហរណ៍ផ្សេងទៀត ស្រដៀងគ្នាដែរ៖

ឧទាហរណ៍៖ ករណីដែលយើងទៅដកលុយនៅតាមម៉ាស៊ីនATM ។ មានថ្ងៃមួយខ្ញុំទៅដកលុយនៅម៉ាស៊ីនATM ចំនួន ៥០ម៉ឺនរៀល ស្រាប់តែថ្ងៃនោះម៉ាស៊ីនវាមានបញ្ហា ឬអ៊ែររ៉ឺក៏ចេញលុយ៥លានរៀលមក ខ្ញុំក៏យកទាំង៥លានរៀលនោះទៅ តែម៉ាស៊ីននោះវាគិតដកលុយពីគណនេយ្យរបស់ខ្ញុំតែ៥០ម៉ឺនរៀលទេ។

តើសកម្មភាពនេះគឺជាអំពើលួចដែរឬអត់? ចំណុចទាំងអស់នេះ គឺអត់គ្រប់ធាតុផ្សំនៃបទល្មើសលួចនោះទេ ដោយសារខ្វះអំពោះដកហូតដោយទុច្ចរិត។ ដូច្នេះប្រសិនបើជាអត់មានក្រមព្រហ្មទណ្ឌនេះយកមកប្រើទេ ប្រាកដជាខាងមន្ត្រីអនុវត្តច្បាប់ ឬមន្ត្រីតុលាការថាគឺជាអំពើលួចបាត់ទៅហើយ ពីព្រោះនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល មិនដឹងច្បាស់ថាស្អីទេគឺជាអំពើលួចនោះ និងអត់មាននិយាយអំពីសកម្មភាពសត្យានុម័តឡើយថាតើលួចគឺធ្វើអ្វី? អញ្ចឹងយើងឃើញថាអំពើលួច ប្រសិនបើយើងវិភាគឲ្យជិតដល់ មិនមែនស្រួលដូចយើងគិតនោះទេ។ ដូច្នេះឧទាហរណ៍ពាក់ព័ន្ធនឹងការភ័ន្តច្រឡំដែលបានលើកឡើងអម្បាញ់មិញនេះ មិនមែនជាអំពើលួចទេ ដោយសារតែខ្វះធាតុផ្សំចម្បងមួយគឺការដកហូតដោយទុច្ចរិត។ នៅក្នុងករណីនេះ គឺវត្ថុត្រូវបានមកដល់ដៃជនដែលជាប់សង្ស័យដោយខ្លួនឯង ឬក៏ដោយការភ័ន្តច្រឡំរបស់ម្ចាស់ បានន័យថា ជនជាប់សង្ស័យ ឬអ្នកគិតលុយនោះ គឺគាត់មិនបានទៅដកលុយពីហោប៉ៅ ឬកន្លែងណាផ្សេងរបស់យើងទេ តែយើងឲ្យគាត់ដោយការភ័ន្តច្រឡំឯករណីរឿងម៉ាស៊ីនATM គឺខ្ញុំអត់បានប្រើមធ្យោបាយទុច្ចរិត ដើម្បីយកកាតរបស់ខ្ញុំទៅបន្លំប្រព័ន្ធនៃម៉ាស៊ីន ប្រើកាតក្លែងក្លាយ ឬក៏ប្រើឧបករណ៍ដែលជាមធ្យោបាយទុច្ចរិតដើម្បីឲ្យម៉ាស៊ីន ATM ភ័ន្តច្រឡំនោះទេ ប៉ុន្តែម៉ាស៊ីនភ័ន្តច្រឡំចេញលុយមកលើសដោយខ្លួនឯង។ ចំណែកសម្រាប់រឿងរដ្ឋប្បវេណី គឺទាំងអ្នកគិតលុយក្តី ទាំងខ្ញុំដែលបានលុយពីម៉ាស៊ីនក្តីគឺត្រូវឲ្យលុយទៅគេវិញ ពិតមែនតែការភ័ន្តច្រឡំមែន តែយើងគ្មានសិទ្ធិដើម្បីធ្វើលទ្ធកម្មលើទ្រព្យសម្បត្តិទាំងអស់នេះទេ។ សរុបមកវាមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយ។ តែក្នុងរឿងរដ្ឋប្បវេណីបើយើងមិនឲ្យលុយទៅគេវិញទេ បើមានបណ្តឹងគឺតុលាការកាត់ឲ្យសងហើយ។ មានករណីមួយទៀត គឺពេលខ្លះមិនមែនជាការដកហូតដោយទុច្ចរិត តែមានការដកហូតដោយភ័ន្តច្រឡំដែរ តែមិនមែនមកដៃយើងដោយភ័ន្តច្រឡំដូចអម្បាញ់មិញនោះទេ។ ករណីយើងច្រឡំវត្ថុ ព្រោះជួនកាលអាចអង្គុយតុគុយទាវក្បែរគ្នា និងមានទូរស័ព្ទស្រដៀងគ្នា តែដោយសារប្រញាប់ ក៏ទាញទូរស័ព្ទគេដាក់ហោប៉ៅខ្លួនឯងទៅបាត់។ ដូច្នេះនេះគឺជាបញ្ហា បើជាគោលការណ៍ច្បាប់ថា ការដកហូតដោយការភ័ន្តច្រឡំនេះគឺមិនមែនជាអំពើលួចទេ ព្រោះមិនមែនដកហូតដោយទុច្ចរិតឡើយ ហើយអំពើទុច្ចរិតនោះត្រូវកើតមាននៅពេលដែលមានការដកហូតនោះ។

ឧទាហរណ៍៖ អ៊ុំម្នាក់ នៅពេលដែលគាត់ទៅផ្សារថ្មីគឺជិះម៉ូតូកុបសាន់យ៉ាន់ទៅទេ តែនៅពេលគាត់មកវិញ ក៏ជិះម៉ូតូកុបជប៉ុនមកដល់ផ្ទះដោយសារតែសោរចាក់ត្រូវគ្នា។ ដូច្នេះបើសិនជាដូចអង្គហេតុ គាត់ពិតជាភ័ន្តច្រឡំប្រាកដមែន គឺមិនមែនជាបទល្មើសនោះទេ ពីព្រោះខ្វះធាតុផ្សំដោយទុច្ចរិត។ ក៏ប៉ុន្តែពិតជាមានការលំបាកនៅក្នុងការបញ្ជាក់ភស្តុតាងឬមធ្យោបាយនៃការបង្ហាញភស្តុតាងថាតើគាត់ភ័ន្តច្រឡំមែនឬក៏គាត់ធ្វើជាច្រឡំទេ? ចុះបើពាក់ស្បែកជើងផ្លាត់ទៅកន្លែងរោងការគេ តែពេលត្រឡប់មកវិញក៏ពាក់ស្បែកជើងខៀមក តើនេះភ័ន្តច្រឡំឬទេ? គឺអត់មែននោះទេដូច្នេះជាអំពើលួច។ អញ្ចឹងសកម្មភាពសត្យានុម័ត អាចស្តែងអំពីឆន្ទៈថាតើមនុស្សធ្វើដោយការភ័ន្តច្រឡំ ដោយអចេតនា ឬដោយមានចេតនាធ្វើជាច្រឡំតែម្តង? ដូច្នេះសម្រាប់អ្នកសិក្សាអំពីច្បាប់ ពិសេសមន្ត្រីអនុវត្តច្បាប់ត្រូវពិចារណា។

ខាងលើយើងបានវិភាគអំពីការដកហូតដោយទុច្ចរិត បានវិភាគអំពីប្រភេទនៃវត្ថុ និងទ្រព្យសម្បត្តិដោយបានវិភាគអំពីគោលការណ៍នៃទ្រព្យសម្បត្តិ គឺមានតែចលនទ្រព្យដែលអាចជាកម្មវត្ថុនៃអំពើលួច ហើយជាពិសេសគេផាត់ចេញតែអចលនទ្រព្យពីធម្មជាតិប៉ុណ្ណោះដែលមិនអាចជាកម្មវត្ថុនៃអំពើលួចបាន ដោយសារមិនអាចបំលាស់ទីបាន អញ្ចឹងអចលនទ្រព្យតាមភ័ព្វវាសនា ឬក៏អចលនទ្រព្យតាមចំណាត់ថ្នាក់នេះអាចជាកម្មវត្ថុនៃអំពើលួចដែរ។

មានករណីមួយទៀត តាមពិតយើងបានស្រាវជ្រាវបន្ថែមអំពីសំនួរនេះ ដោយសារមានសំណួរពីខាងតុលាការខេត្តព្រៃវែងគឺករណីទៅជីកយកអាចម៍ដី ពីដីដែលជាកម្មសិទ្ធិរបស់អ្នកដទៃយកមកចាក់ដីរបស់ខ្លួន។ តើការជីកយកអាចម៍ដីនេះអាចចាត់ទុកថាជាអំពើលួចដែលឬទេ? តើអាចម៍ដីនោះចាត់ទុកជាចលនទ្រព្យដែរឬទេ? ក្រែងបញ្ញាដីធ្លីគឺជាចលនទ្រព្យទេតើ? កាលដំបូងមុនមិនទាន់បានធ្វើការស្រាវជ្រាវ ខ្ញុំថាវាគឺជាទម្រង់មួយនៃការប៉ះពាល់ដល់ទ្រព្យសម្បត្តិ ដូច្នេះបើតាមក្រមព្រហ្មទណ្ឌ គឺជាបទល្មើសធ្វើឲ្យខូចខាតដោយចេតនា (មាត្រា៤១០)។ ប៉ុន្តែក្រោយពីការស្រាវជ្រាវ មានយុត្តិសាស្ត្ររបស់ប្រទេសអាល្លឺម៉ង់មួយ មានករណីស្រដៀងគ្នាហ្នឹងដែរគឺមានកម្មសិទ្ធិករម្នាក់ គាត់មានដីធ្លីរបស់គាត់នៅជាប់ស្ទឹង គូទដីខាងក្រោយនោះជាប់មាត់ស្ទឹង នៅពេលដែលទឹកស្ទឹងហូរមកក៏ដុះខ្សាច់ ហើយច្បាប់ភូមិបាលអាល្លឺម៉ង់ ក៏ដូចប្រព័ន្ធច្បាប់យើងទាំងចាស់

ទាំងថ្មីហ្នឹងបានចែងថាដីដែលដុះដោយសារទឹកស្ទឹងហូរមកនោះ ត្រូវក្លាយទៅជាកម្មសិទ្ធិរបស់អ្នកដែលមានកម្មសិទ្ធិនៅជាប់មាត់ស្ទឹង ស្រាប់តែមានក្រុមហ៊ុនគាត់មកជីកដីខ្សាច់នោះ។ ក្រោយមកក៏មានការប្តឹងផ្តល់ដល់តុលាការអាល្លឺម៉ង់ថា នេះគឺជាករណីអំពើលួច។ ដូច្នេះយើងអាចថា វាគឺជាករណីស្រដៀងគ្នា អញ្ចឹងវាគឺជាអំពើលួច ពីព្រោះនៅពេលដែលដីវាដាច់ចេញពីដីធ្លី ឬប្រព័ន្ធដីឡូតិ៍ទាំងមូលទៅ គឺត្រូវក្លាយជាចលនទ្រព្យដែរ ដោយសារអាចបំលាស់ទីបាន។

នៅក្នុងមាត្រា ៣៥៣ នេះគឺសរសេរតែពីរឃ្លាទេ ប៉ុន្តែពិតជាមានធាតុផ្សំច្រើនដើម្បីឲ្យយើងយកមកធ្វើការពិចារណាឲ្យបានលម្អិត និងស៊ីជម្រៅ។

ក្រោយពីបានវិភាគដល់បញ្ហាខាងលើអស់ហើយ យើងត្រូវសិក្សាលើពាក្យ៖

**២.២ ស្តែងឡើងតាមគ្រប់មធ្យោបាយ**

ក្រោយពីមានការដកហូតដោយទុច្ចរិតនូវវត្ថុ ឬទ្រព្យសម្បត្តិរបស់អ្នកដទៃរួចហើយគឺ ត្រូវប្រើតាមមធ្យោបាយទៀត ។ ករណីនេះ គឺមានបញ្ហាចោទឡើងចំពោះបុគ្គលិកក្រុមហ៊ុនម្នាក់ដែលគាត់បានថតចម្លងឯកសារអំពីពត៌មាន និងគណនេយ្យ ឬហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ក្នុងរឿងនេះគឺមានលេចចេញនូវសញ្ញាណមួយទៀត ដោយសារមានរឿងពីសាលាដំបូងរហូតទៅដល់សាលាឧទ្ធរណ៍នៃប្រទេសបារាំងថាមិនមែនអំពើលួច ពីព្រោះវត្ថុអត់ត្រូវបានបំលាស់ទីទេ ដូច្នេះនេះគឺជាករណីរំលោភទៅលើករណីយកិច្ចជាបុគ្គលិករបស់ក្រុមហ៊ុន តែមិនមែនជាអំពើលួចទេ។ ផ្ទុយទៅវិញ នៅពេលដែលរឿងនេះទៅដល់តុលាការកំពូល គឺបានពិចារណាទៅលើចំណុចមួយចំនួនដូចតទៅ៖

ទីមួយ ឯកសារជាទ្រព្យសម្បត្តិផ្តាច់មុខរបស់ក្រុមហ៊ុន។ ទីពីរ សិទ្ធិនៅក្នុងការថតចម្លង ការផលិតឡើងវិញ គឺជាបុព្វសិទ្ធិផ្តាច់មុខរបស់កម្មសិទ្ធិករ។ ក្នុងនាមជាបុគ្គលិកក្រុមហ៊ុន គេបានប្រគល់ឲ្យនូវសិទ្ធិប្រើប្រាស់ ដើម្បីប្រយោជន៍ក្រុមហ៊ុន តែមិនបានប្រគល់នូវសិទ្ធិក្នុងការថតចម្លង ហើយយកចេញទៅក្រៅនោះទេ។ ពេលខ្លះមានឯកសារមួយចំនួន គេឲ្យថតចម្លងដើម្បីមើលតែនៅក្នុងក្រុមហ៊ុនហ្នឹង ហើយអត់អាចយកចេញក្រៅបានឡើយ អញ្ចឹងការដែលប៉ះពាល់ដល់សកម្មភាពរបស់បុគ្គលិកក្រុមហ៊ុន ដោយសារតែថតចម្លងឯកសាររបស់ក្រុមហ៊ុនដោយគ្មានការអនុញ្ញាតនេះ គឺជាការរំលោភទៅលើសិទ្ធិក្នុងការចាត់ចែង ឬសិទ្ធិក្នុងការផលិតឡើងវិញ គឺជាបុព្វសិទ្ធិផ្តាច់មុខ ដែលនេះហើយគឺជាធាតុសំខាន់នៃកម្មសិទ្ធិ។ ជាចុងក្រោយ សកម្មភាពរបស់បុគ្គលិកក្រុមហ៊ុននេះ គឺជាអំពើលួចតាមរូបភាពថតចម្លង។ ទាក់ទងជាមួយនឹងករណីនេះ មានពេលខ្លះគេចោទប្រកាន់ពីបទលួច

ពេលខ្លះគេចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្ត។ ករណីខាងលើ គឺជាអំពើលួច ប៉ុន្តែបើសិនជាគាត់ថតចម្លងឯកសារហ្នឹងហើយ គាត់យកទៅផ្តល់ពត៌មានឲ្យអ្នកដទៃ ដែលធ្វើអោយខូចប្រយោជន៍របស់ក្រុមហ៊ុន តុលាការនឹងចោទប្រកាន់អំពីបទរំលោភលើសេចក្តីទុកចិត្ត បានន័យថាក្នុងនាមជាបុគ្គលិកក្រុមហ៊ុន គេបានប្រគល់ឲ្យគាត់នូវសិទ្ធិប្រើប្រាស់មានកម្រិតនូវឯកសារទាំងនេះ អញ្ចឹងការណ៍ដែលគាត់យកពត៌មានសម្ងាត់ ទៅផ្តល់ឲ្យអ្នកដទៃប្រើប្រាស់មានកម្រិតនូវឯកសារទាំងនេះ អញ្ចឹងការណ៍ដែលគាត់យកពត៌មានសម្ងាត់ ទៅផ្តល់អោយអ្នកដទៃប្រើប្រាស់ដោយគ្មានការអនុញ្ញាតក្រុមហ៊ុន គឺជាការរំលោភលើទំនុកចិត្ត ពីព្រោះលើសអំពីសិទ្ធិ គឺគាត់អត់មានសិទ្ធិនឹងធ្វើ ហើយសកម្មភាពនេះ ប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ក្រុមហ៊ុនផងដែរ។ នៅក្នុងប្រទេសកម្ពុជាយើង បើអនុវត្តច្បាប់អោយបានមែនទែន គឺពិតជាមានបទល្មើសច្រើនខ្លាំងណាស់ ជាពិសេសទាក់ទងនឹងប្រព័ន្ធធនាគារ ខ្ញុំសង្កេតឃើញនៅក្នុងប្រទេសកម្ពុជាយើងហ្នឹង ពួកបុគ្គលិករបស់ធនាគារច្រើនតែបិទមិនស្ងៀតទេ ពេលគាត់ដឹងពីស្ថានភាពអតិថិជនហើយ គាត់ទៅប្រាប់ក្រុមហ៊ុនមួយទៀត ឬក៏ក្រុមហ៊ុនខ្លួនឯងហ្នឹងយកពត៌មានអំពីអតិថិជនទៅលក់ឲ្យក្រុមហ៊ុនថ្មីទៀតដើម្បីគេធ្វើថាហេ្គតម៉ាឃីតធីង ផ្សព្វផ្សាយទាក់ទងទូរស័ព្ទយើងចុះឡើងៗ។ នៅក្នុងវិស័យសម័យទំនើបនេះ ពត៌មានអំពីក្រុមហ៊ុនជាធាតុសំខាន់បំផុតនៃកត្តាជោគជ័យរបស់ក្រុមហ៊ុន។

មានចំណុចមួយទៀតដែរ ករណីនៃរូបភាពជាអំពើលួចផ្សេងៗនោះ គឺដូចករណីក្រុមហ៊ុនវិស្វករមួយក្រុមទៅស្រាវជ្រាវរូបមន្ត ឬក៏ពិនិត្យឯកសារជាយុត្តិសាស្ត្រ ផែនការ ឬក៏រូបមន្តដើម្បីផលិតអ្វីមួយ។ ដល់ពេលបានជាលទ្ធផលសម្រេចហើយ ក្រុមហ៊ុនក៏សម្រេចយកគម្រោងនៃរូបមន្តនេះ អញ្ចឹងរូបមន្តនេះក្លាយទៅជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។ បើទោះបីជាក្រុមវិស្វករជាអ្នកបង្កើត ប៉ុន្តែពួកគាត់ស៊ីប្រាក់ខែក្រុមហ៊ុន។ មានវិស្វករម្នាក់នោះគាត់ចាំនៅក្នុងខួរក្បាលរបស់គាត់ ពេលយកទៅផ្ទះគាត់ក៏សរសេរឡើងវិញ ដូច្នេះពេលមានអ្នកខ្លះគ្រាន់តែបើកសៀវភៅភ្លេតៗ ក៏ចាំក្នុងខួរក្បាល តើការដែលចាំនៅក្នុងខួរក្បាល ឬទន្ទេញចាំមាត់បែបនេះ សួរថាតើជាអំពើលួចដែរឬទេ? យើងអត់យកម៉ាស៊ីនទៅថតនោះទេ ប៉ុន្តែយើងយកភ្នែកទៅថតចម្លង។ ចុះកាមេរ៉ាទូរស័ព្ទមិនដូចភ្នែកយើងដែរ ព្រោះវាថតចូលខួរក្បាលវា យើងយកភ្នែកថតចូលក្នុងខួរក្បាលយើង។ នៅក្នុងបញ្ហានេះ គឺមានយុត្តិសាស្ត្រមួយដែលទាក់ទងថា បើសិនជាយើងគ្រាន់ទន្ទេញចាំមាត់ ហើយជាប់នៅក្នុងខួរក្បាល

យើង គឺមិនមែនជាអំពើលួចនោះទេ។ ក៏ប៉ុន្តែនៅពេលដែលយើងសរសេរនូវរូបមន្តនោះចេញមកទេ គឺមិនមែនជាអំពើលួចនោះទេ ពីព្រោះវាអត់មានប៉ះពាល់ ឬខូចប្រយោជន៍របស់គេឡើយ។

**២.៣ ស្តែងឡើងតាមការប្រើប្រាស់ថាមពលទុច្ចរិត**

យោងតាមមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ ស្តីពីអំពើលួចថាមពល គឺបានបញ្ជាក់ច្បាស់ថា តាមរូបភាពនៃការប្រើប្រាស់ថាមពលដោយទុច្ចរិត ដែលនាំឲ្យខូចប្រយោជន៍អ្នកដទៃ ក្នុងគោលដៅដើម្បីបញ្ចៀសការបង់ថ្លៃតែម្តងគឺឥតបង់ថ្លៃតែម្តង ឬក៏ការបង់ថ្លៃតិចគឺបង់ថ្លៃមិនគ្រប់ចំនួនជាដើម ក៏ជារូបភាពនៃបទលួច។ ចំណាំ ៖ អំពើប្រើប្រាស់ (មាត្រា៣៥៤) ផ្ទុយពីការដកហូត (មាត្រា៣៥៣) ពីព្រោះទឹក និងភ្លើងមិនអាចទៅដកហូតវាបាននោះទេ។

ឧទាហរណ៍ ៖ ដាក់កុងទ័រទឹក ឲ្យដើរយឺតជាងធម្មតាជាដើម។

ចុះសួរថាតើទូរស័ព្ទ និងអិនធឺណេតវិញ គឺជាថាមពលដែរឬទេ? ដើម្បីដឹងច្បាស់ពីរឿងនេះ សូមមើលព្រះរាជក្រម នស/រកម/០៧០២/០១២ ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២វិញ។

**៣. ធាតុផ្សំអត្តនោម័តនៃអំពើលួច**

ធាតុផ្សំចិត្តសាស្ត្រនៃអំពើលួច រួមមាននូវកត្តា ២(ពីរ)យ៉ាងគឺ៖

**៣.១ ចេតនាទុច្ចរិតទូទៅ**

ជនល្មើសដឹងច្បាស់ថាវត្ថុដែលខ្លួនយកមកនោះមិនមែនជារបស់ខ្លួននោះឡើយ។ ហេតុនេះ បើជនណាម្នាក់ដែលស្មានច្រឡំថាជារបស់ខ្លួន ហើយយករបស់នោះ ដូច្នេះមិនអាចចាត់ទុកថាជាអំពើលួចបានឡើយ។

**៣.២ ចេតនាទុច្ចរិតពិសេស**

ក្រោយពីបានយល់ចំណុចទាំងអស់ខាងលើ ឥឡូវនេះយើងបន្តទៅដល់ករណីមានគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

ជនល្មើសមានបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយគាត់អាចយកវត្ថុដែលបានលួចបានមកនោះ ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ឬដើម្បីយកទៅចាត់ចែងតាមបំណងប្រាថ្នារបស់ខ្លួនដូចជាទុកចោល ឬយកទៅបោះបង់ចោលជាដើម។ ឯការទាមទារថ្នូរដើម្បីប្រគលវត្ថុក៏ជាករណីលួចផងដែរ (សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត)។

រីឯមាត្រា៣៥៤ គឺជនល្មើសចង់បានប្រើប្រាស់ថាមពលអគ្គិសនី ឬថាមពលទឹកដោយមិនបង់ថ្លៃ ឬដោយបង់ថ្លៃតិចជាងតម្លៃដែលបានប្រើប្រាស់។

មួយវិញទៀត ករណីដែលស្តែងឡើងក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន គឺមានករណីមួយនៅអឺរ៉ុបកាលពីឆ្នាំ២០០០ជាង មានព្រឹត្តិការណ៍កើតឡើងអំពើពួកក្មេងទំនើង នៅពេលរដូវវិស្សមកាលម្តងៗ វាច្រើនតែយកឡាន ម៉ូតូ កង់របស់អ្នកដទៃជិះ ជួនកាលវាចង់ទៅលេងមាត់សមុទ្រ ពេលអត់ឡានជិះហើយខ្ជិលទិញសំបុត្រដើម្បីជិះរថភ្លើងផង ព្រោះខ្លាចអស់លុយ ស្រាប់តែវាឆ្លឹះសោរឡានរបស់សាធារណៈជនដែលចតនៅតាមផ្លូវនោះក៏បើកឱបស្រីដើលេងតាមមាត់សមុទ្រហើយក៏បោះចោលនៅតាមមាត់សមុទ្រទៅ ជួនកាលនៅតាមផ្លូវហាយវេ៉ ពេលដែលឡានអស់សាំងវាក៏បោះក្រវាត់ចោលទៅ។ កាលពីដំបូងតុលាការនៅអឺរ៉ុបមានការលំបាកថាតើជាអំពើលួចឬក៏អត់? ដោយសារក្នុងនេះ យើងឃើញថាមានពាក់ព័ន្ធនឹងរឿង គោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន អញ្ចឹងពីដើមដំបូង បំណងរបស់វាគឺពុំមានចង់យកមកធ្វើជាកម្មសិទ្ធិនោះទេ គ្រាន់តែចង់ប្រើមួយរយៈពេល ដើម្បីដឹកគ្នាដើរលេងនៅឆ្នេរសមុទ្រតែប៉ុណ្ណោះ។ បញ្ហានេះគឺមានបំលាស់ទីដោយទុច្ចរិត ឬដកហូតដោយទុច្ចរិតដោយគ្មានសិទ្ធិដូចគ្នា តើគឺជាអំពើលួចឬអត់? នេះបើតាមសម្មតិកម្មបានរៀបរាប់អញ្ចឹង ប៉ុន្តែនៅក្នុងពេលប្រើនីតិវិធីជាក់ស្តែង គឺមានការលំបាកត្រង់ថា តើវាចង់យកមកធ្វើជាកម្មសិទ្ធិឬអត់? តែអ្វីដែលខ្ញុំចង់លើកនៅទីនេះ គឺពាក់ព័ន្ធអំពីយុត្តិសាស្ត្រមួយនាពេលឆ្នាំ២០០០ជាងថ្មីៗនេះ ដែលគេបានអភិវឌ្ឍន៍នូវសញ្ញាណមួយ ដោយចាប់ពីសាលាដំបូងដល់សាលាឧទ្ធរណ៍ គឺថាមិនមែនលួចនោះទេ ព្រោះគ្មានគោលបំណងយកមកធ្វើជាកម្មសិទ្ធិវាទេ គឺគ្រាន់តែចង់យកមកដើរលេង ឬខ្ចីប្រើប្រាស់តែមួយរយៈពេលប៉ុណ្ណោះ។ ដូច្នេះនៅពេលដែលធ្វើការវិភាគទៅ ឃើញថាមានការដកហូតដោយទុច្ចរិត ឬដោយគ្មានសិទ្ធិ ឬដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ហើយក្នុងករណីនេះគេបានធ្វើការវិភាគទៅលើចំណុចមួយចំនួនដូចជា ដោយសារមានការដកហូតដោយទុច្ចរិតនាំឲ្យម្ចាស់កម្មសិទ្ធិករបាត់បង់នូវការកាន់កាប់មួយរយៈ និងជនជាប់ចោទបានយកមធ្យោបាយនេះទៅប្រើប្រាស់មួយរយៈ។ អញ្ចឹងគេចាត់ទុកថា នៅក្នុងសមាសភាគនៃកម្មសិទ្ធិនោះគឺមាន សិទ្ធិប្រើប្រាស់ សិទ្ធិចាត់ចែង និងសិទ្ធិអាស្រ័យផល ហើយសមាសភាគទាំងបីនេះ គឺជាសិទ្ធិផ្តាច់មុខរបស់កម្មសិទ្ធិករ។ ហេតុនេះការណ៍ដែលប្រើប្រាស់ទ្រព្យសម្បត្តិរបស់អ្នកដទៃដោយគ្មានការអនុញ្ញាតពីកម្មសិទ្ធិករគឺប៉ះពាល់លើសមាសភាគសំខាន់មួយនៃកម្មសិទ្ធិនេះទី១។ ទី២ នៅពេលដែលពួកក្មេងទំនើង យកឡាននោះទៅ គឺវាបានតាំងខ្លួនជាកម្មសិទ្ធិករហើយពិតមែន

តែជាបណ្តោះអាសន្នក៏ដោយ ប៉ុន្តែវាយកទៅឧបត្ថាដើរលេង ហើយវាបោះបង់ចោលនេះបានន័យថាវាបានតាំងខ្លួនជាកម្មសិទ្ធិករ។ ដូច្នេះសកម្មភាពពីរនេះ នៅពេលដែលយកមកផ្គុំគ្នាទៅជាចំណុចរួមរួចហើយ តុលាការបារាំងថាគឺជាអំពើលួច តែការប្រើប្រាស់ឬរូបភាពនៃការលួច គឺលួចការប្រើប្រាស់នេះ បានយកទៅពន្លាតដែនអនុវត្តនៅក្នុងវិស័យផ្សេងៗទៀតដូចជា វិស័យថាមពល វិស័យទូរគមនាគមន៍ សោតទស្សន៍ផ្សេងៗទៀត។ អញ្ចឹងវាអាចមានលួចថាមពល លួចប្រព័ន្ធទូរស័ព្ទ ប្រព័ន្ធអិនធើណេត លួចប្រព័ន្ធទូរទស្សន៍។

យើងឃើញនៅក្នុងមាត្រា ៣៥៤ គឺមានបង្កប់នូវពាក្យ "ត្រូវចាត់ទុកជាអំពើលួច គឺអំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំអោយខូចប្រយោជន៍ដល់អ្នកដ៏ទៃ[3]។"

ពាក្យដែលថា "ប្រើប្រាស់ដោយទុច្ចរិត" មានន័យស្មើនឹង ប្រើប្រាស់ដោយគ្មានសិទ្ធិ ឬដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ហើយនាំអោយខូចប្រយោជន៍ដល់ម្ចាស់សិទ្ធិ គឺចាត់ទុកជាអំពើលួចដែរ តែជាអំពើលួចការប្រើប្រាស់។

នៅក្នុងក្រមព្រហ្មទណ្ឌបារាំង ពុំមានមាត្រា ៣៥៤ នេះដូចកម្ពុជាទេ តែគេបានយកបញ្ញត្តិនៃមាត្រា ៣៥៣ ដូចក្រមព្រហ្មទណ្ឌយើងនោះទៅពន្លាតនៅក្នុងគ្រប់វិស័យទាំងអស់ដូចជាវិស័យទាំងអស់ដូចជាវិស័យខាងប្រព័ន្ធទូរទស្សន៍ខ្សែកាប មានប៉ុស្ត៍ខ្លះគេអ៊ីនស្រ្គីវា លុះត្រាតែយើងទិញឧបករណ៍វាមួយហើយដាក់លេខកូដ ឬក៏ដាក់កាតបានអាចមើលវាបាន ។ នៅពេលដែលមានអ្នកខ្លះយកប្រព័ន្ធដេកូឌឺមកដោះទៅគឺអាចមើលប្រព័ន្ធទូរទស្សន៍ខ្សែកាបគេបានហើយនេះគឺជាអំពើលួចការប្រើប្រាស់ ។ អញ្ចឹងយើងឃើញថានៅក្នុងករណីនេះ យើងអត់មានសញ្ញាណនៃវត្ថុថ្មីនេះ ឃ្លាតឆ្ងាយពីការបំលាស់ទីវត្ថុនោះទេ ហើយវាជាវត្ថុដែលមិនអាចចាប់កាន់បាន មិនអាចមើលឃើញបានដូចជាប្រព័ន្ធទូរស័ព្ទ ដូចជាប្រព័ន្ធទូរទស្សន៍ ហេតុនេះហើយទើបគេអភិវឌ្ឍន៍ទៅលើសញ្ញាណនៃការលួចការប្រើប្រាស់ ។ ម៉្យាងថាមពលនៅក្នុងមាត្រានេះក៏មាន អគ្គិសនី ហ្គាស ទឹក ។ ក្រៅពីនេះគឺលួចប្រព័ន្ធទូរស័ព្ទ លួចប្រព័ន្ធអ៊ីនធើណែត លួចប្រព័ន្ធទូរទស្សន៍ តើចូលមាត្រា ៣៥៤ ខាងលើឬទេ? ដូចបានលើកឡើងគឺករណីទូរទស្សន៍ខ្សែកាប ត្រូវមានម៉ាស៊ីនរបស់គេ ហើយយើងដាក់កាតចូលទើបបានមើលកើត តែយើងទៅទិញម៉ាស៊ីនពីផ្សារងងឹតមក រួចដោះលេខកូដហើយមើលរបស់

[3] មាត្រា ៣៥៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

គេដោយឥតគិតថ្លៃ និងប្រព័ន្ធអ៊ីនធើណែតគេដាក់លេខកូដ រួចក៏ទៅលួចលេខកូដគេបានយកទៅប្រើដោយឥតគិតថ្លៃ និងប្រព័ន្ធទូរស័ព្ទលួចប្រើ free free នេះហើយគឺជាអំពើលួចការប្រើប្រាស់ ។

ទាំងអស់ខាងលើនេះ គឺជាឧទាហរណ៍មួយចំនួនសម្រាប់ជាមូលដ្ឋាននៃការវិភាគលើអំពើលួច ឬបទល្មើសលួច ។ មុននឹងឆ្លងដល់មាត្រា ៣៥៥ យើងនៅមានឧទាហរណ៍មួយទៀតដែលខ្ញុំយល់ឃើញថាជាមូលដ្ឋានក្នុងការពិចារណាដែរ ។ ករណីអ្នកលក់វត្ថុផ្ទាល់ដៃ ឧទាហរណ៍៖ តាមរយៈអ្នកដាក់ឡានលក់ទំនិញ ឬទៅកន្លែងមជ្ឈមណ្ឌលពិពណ៌ពាណិជ្ជកម្មតាមយុត្តិសាស្ត្ររបស់តុលាការបារាំង នៅក្នុងច្បាប់ពាណិជ្ជកម្មបារាំង គេថាជាប្រភេទនៃការដោះដូរឬក៏ការលក់ដូរដោយផ្ទាល់ដៃមានន័យថា ហុចលុយហុចរបស់ៗ ស្រាប់តែមានករណីមួយកើតឡើងនៅក្នុងពិពណ៌ពាណិជ្ជកម្ម យើងដើរទៅដល់ស្តង់លក់ស្បែកជើងមួយពេលមើលឃើញស្បែកជើងស្អាត យើងសួរអ្នកលក់ថាមួយគូរប៉ុន្មាន ? មួយគូរ ៩៩ ដុល្លារ ពេលមើលឃើញគុណភាពល្អ និងតម្លៃគួរសម យើងក៏ទិញវាយក ។ ដល់ពេលដែលយើងកាន់ស្បែកជើងមើលរួច មានភ្ញៀវទៀតមកសួរច្រើនក៏នាំឲ្យអ្នកលក់នោះរវល់ យើងក៏ដើរកាន់ស្បែកជើងនោះចេញទៅដោយអត់ឲ្យលុយគាត់ទេ ។

ចំណោទសំណួរសួរថា តើករណីនេះជារឿងរដ្ឋប្បវេណីឬជាការមិនអនុវត្តនូវកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យារដ្ឋប្បវេណី (កិច្ចសន្យាលក់ទិញ) ឬមួយក៏អាចជារឿងព្រហ្មទណ្ឌ ។ បើយើងពិនិត្យមើលអំពីគោលការណ៍រដ្ឋប្បវេណីថា កិច្ចសន្យាលក់ទិញត្រូវបានបង្កើតឡើងដោយសារទីមួយគឺអ្នកលក់បានដាក់ជាតម្លៃ អ្នកទិញបានពិនិត្យទំនិញហើយយល់ព្រមទិញ ដូច្នេះកិច្ចសន្យាទិញលក់ត្រូវបានបង្កើតឡើង ទោះបីជាក្នុងក្របខ័ណ្ឌផ្ទាល់មាត់ក៏ដោយ បើយោងតាមក្រមរដ្ឋប្បវេណី មិនសំខាន់ត្រង់ផ្ទាល់មាត់ ឬមិនផ្ទាល់មាត់(លាយលក្ខណ៍អក្សរ)នោះទេ ។ បើកិច្ចសន្យាលក់ត្រូវបានបង្កើតឡើង អញ្ចឹងបើយើងវិភាគទៅតាមគោលការណ៍រដ្ឋប្បវេណីនោះ ប្រហែលជាថាចូលទៅក្នុងករណីមិនអនុវត្តកាតព្វកិច្ចរដ្ឋប្បវេណី ព្រោះយើងទិញរបស់គេហើយអត់បង់លុយឲ្យគេគឺជឿសិន ។ ពីព្រោះនៅក្នុងបញ្ហានៃការវិភាគនេះបើយោងតាមយុត្តិសាស្ត្ររបស់តុលាការបារាំង គឺមានការវិភាគច្បាស់ថា ហាក់ដូចជាមានភាពប្រឆាំងគ្នាជាមួយនឹងគោលការណ៍នៅក្នុងនីតិរដ្ឋប្បវេណីត្រង់ថានៅក្នុងកិច្ចសន្យាលក់ទិញគឺមានការផ្ទេរឬកម្មសិទ្ធិនូវវត្ថុដែលលក់ ដូចនេះអ្នកដែលទិញ គាត់មានសិទ្ធិចាត់ចែងដោយសេរីទៅលើវត្ថុដែលគាត់បានទិញនោះ ព្រោះគាត់ជាកម្មសិទ្ធិករហើយ ទោះបីជាគាត់មិនទាន់បង់លុយក្តីឬគាត់បង់លុយមិនទាន់គ្រប់ក្តី ក៏គាត់ក្លាយទៅជាកម្មសិទ្ធិករស្របច្បាប់នៃ

វត្ថុនោះដែរ ។ នេះបើយើងវិភាគទៅលើគោលការណ៍នៃនីតិរដ្ឋប្បវេណី និងនេះគ្រាន់តែជាឧទាហរណ៍នៅតុលាការបារាំងទេ ឯនៅតុលាការកម្ពុជាអាចនឹងមានទាក់ទងជាមួយករណីនេះពីព្រោះយើងមានពិពណ៌ពាណិជ្ជកម្មច្រើនឥឡូវនេះ ។ ម្យ៉ាងទៀត តុលាការបារាំងគេបានគួបជាមួយនយោបាយពាណិជ្ជកម្មនៅក្នុងគោលដៅការពារពាណិជ្ជករតូចតាច ឬអាជីវករតូចតាចដែលរកស៊ីលក់ផ្ទាល់ដៃនោះ គេក៏មានចេញជាយុត្តិសាស្ត្រមួយថាពិតមែនតែនៅក្នុងករណីបែបនេះកិច្ចសន្យាលក់ទិញ ត្រូវបានបង្កើតឡើង ទី១ ។ ទី២ អ្នកលក់ដែលជាម្ចាស់វត្ថុ បានប្រគល់វត្ថុទៅដល់ដៃរបស់អ្នកទិញ និងម្ចាស់វត្ថុបាត់បង់នូវការកាន់កាប់វត្ថុរបស់ខ្លួន តែបាត់បង់ត្រឹមមួយរយៈប៉ុណ្ណោះហើយពុំទាន់មានការផ្ទេរកម្មសិទ្ធិពេញលេញទៅលើវត្ថុនោះទេ ឯការផ្ទេរកម្មសិទ្ធិពេញលេញនៃវត្ថុនេះជាប់ជាមួយនឹងលក្ខខណ្ឌនៃការបង់ប្រាក់ ដោយសារតែវាជាប្រភេទនៃការលក់ទិញផ្ទាល់ដៃគឺត្រូវបង់លុយផ្ទាល់ដៃដែរ ។ អញ្ចឹងក្នុងឋានៈដែលអ្នកទិញពុំទាន់បង់ប្រាក់គ្រប់ចំនួនដល់អ្នកលក់នោះទេ ស្មើនឹង ពុំទាន់មានការផ្ទេរកម្មសិទ្ធិពេញលេញទៅលើវត្ថុនោះទេ ពិតមែនតែអ្នកលក់បាត់បង់នៅការកាន់កាប់វត្ថុមួយរយៈ ឬមានការប្រគល់ទៅដល់អ្នកទិញក៏ដោយ ។ ការផ្ទេរកម្មសិទ្ធិពេញលេញ ត្រូវភ្ជាប់ជាមួយនឹងលក្ខខណ្ឌនៃការបំពេញរបស់អ្នកទិញគឺបង់លុយផ្ទាល់ដៃ ។

ដូច្នេះករណីខាងលើអម្បាញ់មិញនេះគឺ ជាអំពើលួច ដោយសារតែកម្មសិទ្ធិនៃវត្ថុនេះនៅតែជារបស់អ្នកទិញដដែល សរុបមកវាគឺជាអំពើលួច ។ ប៉ុន្តែគេបានបញ្ជាក់ថាបានតែក្នុងករណីនៃការលក់ដូរផ្ទាល់ដៃ នៅក្នុងក្របខ័ណ្ឌនៃការធ្វើអាជីវកម្មចល័តតែប៉ុណ្ណោះ ។

មានការបញ្ជាក់ពីរឿងនេះថា ចំណែកឯការលក់ទិញដែលការបង់ប្រាក់ត្រូវកំណត់ទៅតាមកាលបរិច្ឆេទ ឬបង់ជាដំណាក់កាល ទោះបីជាក្នុងករណីណាក៏ដោយ ក៏មិនបង្កើតជាបទលួច បទឆបោកនោះទេ ។ ចំណុចនេះសំខាន់ទុកជាមូលដ្ឋាននៅក្នុងការវិភាគ ៖

ឧទាហរណ៍ ៖ អ្នកលក់ទំនិញនៅឯខេត្ត គាត់កាម៉ង់ទំនិញពីអ្នកភ្នំពេញ ពួកគេរកស៊ីជាមួយគ្នាជូនកាលទំនិញទៅហើយ កន្លះខែក្រោយបានបង់លុយ ឬក៏ទៅមុនបង់ពាក់កណ្តាលដល់ពេលក្រោយមកគាត់បង់ជាដំណាក់កាល ។ បន្ទាប់មក អ្នកនៅខេត្តគាត់អស់លុយសង ករណីរឿងនេះតុលាការបានបញ្ជាក់ថា ការលក់ទិញដែលការបង់ប្រាក់ត្រូវបានកំណត់ដោយមានកាលបរិច្ឆេទច្បាស់លាស់ឬជាដំណាក់កាលនោះទោះបីជាក្នុងករណីណាក៏ដោយ មិនបានបង្កើតជាបទលួច ឬក៏ឆបោកនោះទេ

ដោយសារតែនៅក្នុងរឿងនេះជាប្រភេទនៃកិច្ចសន្យាមួយដែលមានការផ្ទេរកម្មសិទ្ធិពេញលេញ ទោះបីជាអ្នកទិញមិនទាន់បង់លុយឬក៏បង់លុយមិនទាន់គ្រប់ចំនួន ឬមួយមិនទាន់ដល់ពេលបង់លុយក៏ដោយ ។ បើកាលណាមានការផ្ទេរកម្មសិទ្ធិពេញលេញទៅលើវត្ថុដែលលក់ អ្នកទិញអាចចាត់ចែងបានដោយសេរី ។ បញ្ហានេះមានឧទាហរណ៍មួយនៅខាងថៅក្រមកោះកុងបានឡើងសួរថា "មានអ្នកលក់គ្រឿងសំណង់ម្នាក់ជាអ្នកកោះកុងរកស៊ីជាមួយអ្នកភ្នំពេញ គាត់ឧស្សាហ៍យកគ្រឿងសំណង់ស៊ីម៉ង់ឬដែកពីភ្នំពេញ ដល់ពេលថ្ងៃមួយនោះគាត់បានកាម៉្ញង់ច្រើនមែនទែន គឺវាលើសអំពីបរិមាណដែលគាត់កាម៉្ញងជារៀងរាល់ដងមានតាំងពីស៊ីម៉ង់ តាំងពីដែក តាំងពីឥដ្ឋឬគ្រឿងសំណង់ផ្សេងៗ ហើយក្រៅពីលក់គាត់យកទៅសង់ផ្ទះវីឡាគាត់មួយទៀត ។ ក្រោយមកអ្នកនៅភ្នំពេញយូរខ្លាំងពេកថាអត់ឃើញគាត់បង់លុយ ហើយទៅតាមទារលុយគាត់ ហើយគាត់ប្រាប់ថាឥលូវអត់ទាន់មានលុយបង់ទេ ព្រោះសង់វីឡាអស់ហើយ" សួរថាតើជាបទល្មើសព្រហ្មទណ្ឌដែរឬទេ? ករណីទិញដូរដោយកាម៉្ញងទំនិញនេះ គឺអត់បានបង្កើតជាអំពើឆបោក ឬអំពើលួចដែលជាបទល្មើសព្រហ្មទណ្ឌនោះទេ ដោយសារទីមួយៈ កិច្ចសន្យារដ្ឋប្បវេណីត្រូវបានបង្កើតឡើងហើយទាក់ទងនឹងការទូទាត់អាចទូទាត់តាមដំណាក់កាល ឬក៏ទូទាត់តាមកាលបរិច្ឆេទអាចបង់មុន ឬមួយខែក្រោយបង់ទាំងអស់តែម្តងៗ ទីពីរ បើកិច្ចសន្យានេះកើតឡើងហើយគឺមានការផ្ទេរកម្មសិទ្ធិដោយពេញលេញទៅលើវត្ថុលក់ ដូច្នេះអ្នកទិញគាត់អាចយកវត្ថុនោះទៅដុតចោលឬទៅលក់បន្តទៀតឬធ្វើអ្វីផ្សេង វាជាសិទ្ធិរបស់គាត់ព្រោះគាត់គឺជាកម្មសិទ្ធិករ គាត់មានកាតព្វកិច្ចមួយបង់តែលុយអោយម្ចាស់ ដែលជាអ្នកលក់តែប៉ុណ្ណោះ ហើយក្នុងករណីដែលគាត់អលទ្ធភាពនៅក្នុងការបង់លុយនោះ គឺវាមិនមែនជារឿងឆបោក មិនមែនជារឿងរំលោភសេចក្តីទុកចិត្ត មិនមែនជារឿងលួចទេ តែវាគ្រាន់តែជារឿងអលទ្ធភាពនៅក្នុងការអនុវត្តកាតព្វកិច្ចរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ ដូច្នេះ មេរៀនខាងក្រោមយើងនឹងភ្ជាប់ថាតើកិច្ចសន្យារដ្ឋប្បវេណីណា

ខ្លះ ដែលអាចបង្កើតជាអំពើរំលោភលើសេចក្ដីទុកចិត្ត ពីព្រោះសព្វថ្ងៃយើងមិនមានភាពច្បាស់លាស់ រវាងព្រំដែនរដ្ឋប្បវេណីនិងព្រំដែនព្រហ្មទណ្ឌទើបធ្វើអោយមានការភ័ន្តច្រឡំមែនទែន ។ ប៉ុន្តែពេលខ្លះយើងសង្កេតឃើញថាខាងមន្ត្រីអនុវត្តច្បាប់ យើងដឹងដែលថាជារឿងរដ្ឋប្បវេណីប៉ុន្តែចោទប្រកាន់យកទៅឃុំសិនចុះ ចាំដោះលែងក្រោយ ដោយសារតែមូលហេតុថាមានការអនុវត្តមាត្រានៃក្រមនេះមិនទាន់ត្រឹមត្រូវទាំងអស់គ្នា ។ ហើយសូមឈប់ប្រើទ្រឹស្ដីថា "**សុខចិត្តឃុំខុសដប់ កុំអោយតែលែងច្រឡំមួយ**" នេះគឺជាទ្រឹស្ដីរបស់ពួកកុំម្មុយនីស្តតែប៉ុណ្ណោះ គឺគេ "**សុខចិត្តលែងច្រឡំដប់ កុំអោយតែឃុំច្រឡំ**" ពីព្រោះនៅក្នុងលទ្ធិប្រជាធិបតេយ្យគឺគេត្រូវគោរពសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ដោយសារតែគោលការណ៍នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាយើងក៏មានចែងផងដែរថា "ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ" ។ ក៏ប៉ុន្តែនៅមានអ្នកអនុវត្តខ្លះនៅតែលួចអនុវត្តទាំងខុស ទាំងសុខចិត្តឃុំសិនទៅ ចាំដោះចេញតាមក្រោយទៀត ។ ចំណុចទាំងអស់នេះសូមប្រយ័ត្នប្រយែងអោយមែនទែន ព្រោះវាធ្វើអោយកគេមានការឈឺចាប់យ៉ាងខ្លាំង និងប្រយ័ត្នភ្លាត់ស្នៀតខ្លួនឯង ក៏ចូលទៅក្នុងបទល្មើសនៃក្រមព្រហ្មទណ្ឌដែលអាចជាប់គុកតាមមាត្រា ២៥៣ "**បទចាប់ ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់**" ។

## កថាខណ្ឌទី៣ ទោសដែលត្រូវអនុវត្ត

យើងសាកល្បងញែកជា ករណីស្ថានទម្ងន់ទោស និងករណីមានស្ថានទម្ងន់ទោស៖

### ១. ករណីគ្មានស្ថានទម្ងន់ទោស

អ្វីដែលឃើញនេះគឺជាអំពើលួចដោយគ្មានស្ថានទម្ងន់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយ លាន) រៀល[4]។

[4] មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

បើយើងប្រៀបធៀបជាមួយនឹង ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឃើញថាគឺហាក់ដូចជាស្រាលជាងមាត្រា ៤៣ ស្តីពីអំពើ "អំពើចោរកម្ម" ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ គឺខុសគ្នាត្រង់អតិបរមានៃទោសគុក ចំណែកអប្បរមាគឺដូចគ្នា[5] ។

ភ្ជាប់ជាមួយនឹងទោសនេះ មុននឹងបន្តទៅទៀតយើងសូមពន្យល់អោយបានក្បោះក្បាយអំពីរឿងទោសដាក់ពន្ធនាគារនេះបន្តិច ដោយយើងនឹងទុកជាជំនួយស្មារតីដូចខាងក្រោមៈ

អំពើលួចនេះគឺជាបទមជ្ឈឹម ដោយពុំមានចែងអំពីបទលហុទេ ដើម្បីអោយតុលាការគាត់ងាយស្រួលក្នុងការអនុវត្តក្នុងករណីអំពើលួចតូចតាចដូចជាលួចមាន់ លួចកង់ លួចផ្លែដូង ផ្លែក្រូច ឬផ្លែស្វាយអ្នកជិតខាង ។ ក្រមព្រហ្មទណ្ឌពុំបានចែងអំពីករណីបទល្មើសលួចតូចតាចតិចតួចនោះទេ ព្រោះគោលការណ៍នៃការបង្កើតក្រមរបស់យើងគឺអត់សំដៅកម្មវត្ថុនៃអំពើលួចថាតើវាមានតម្លៃប៉ុន្មាននោះទេ តែអ្វីដែលយើងចង់ផ្តន្ទាទោសនោះគឺគេហៅថាចេតនាទុច្ចរិតរបស់បុគ្គល ដែលចង់យកទ្រព្យសម្បត្តិរបស់អ្នកដទៃទៅធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន ចំណែកឯតម្លៃនៃកម្មវត្ថុរបស់អំពើលួចនេះវាជាមូលដ្ឋានតូចមួយសំរាប់តុលាការដើម្បីយកមកធ្វើការពិចារណាក្នុងការកំណត់ទោសថា តើមានអប្បបរមាចាប់ពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ គួរតុលាការយក ៣ឆ្នាំ ២ឆ្នាំ ១ឆ្នាំ ៦ខែ ឬ ៣ខែមកប្រកាសនេះគឺជាគោលការណ៍ទូទៅ ។ ក៏ប៉ុន្តែគោលការណ៍នេះត្រូវបានគេសម្រាល បានន័យថាត្រូវធ្វើអោយមានលក្ខណៈទន់ភ្លន់ ដើម្បីអោយស្របទៅនឹងគោលការណ៍ឯកត្តកម្មនៃទោសដូចមានចែងនៅក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ។ ដូច្នេះយើងមានគោលការណ៍នេះដើម្បីសម្រាលនិងងាយស្រួលដល់តុលាការនៅក្នុងការអនុវត្ត ។ ទាំងនេះគឺមាននៅក្នុងគោលការណ៍ទូទៅស្តីពីរបបនៃការចោទប្រកាន់ ការផ្តន្ទាទោស និងការប្រកាសទោស ។ យើងលើកយកមាត្រា ៩៦ គោលការណ៍ឯកត្តកម្មនៃទោស ចែងថា "តុលាការប្រកាសទោសផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ចំពោះជនរងគ្រោះ [6]"។ ដូច្នេះជាគោលការណ៍ គឺតុលាការពិចារណាក្នុងការផ្តន្ទាទោសបទល្មើស

[5] មាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

[6] មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ទៅលើទីមួយ-ស្ថានភាពសង្គមនៃជនល្មើស, បុគ្គលភាពនៃជនល្មើស និង ទីពីរ-គឺទៅលើផលប៉ះពាល់នៃអំពើល្មើស តើវាបង្កអោយមានចលាចល អសន្តិសុខ អសណ្តាប់ធ្នាប់ ឬ ប៉ះពាល់ដល់ផ្លូវចិត្តនៅក្នុងសង្គមខ្លាំងក្លា? ឬតើត្រឹមតែជាបទល្មើសមួយដែលមានអានុភាពស្រាលហើយឆាប់រលត់ទៅវិញ? ដូចករណីលួចបេះផ្លែស្វាយ ផ្លែក្រូច ផ្លែដូងរបស់អ្នកជិតខាងជាដើម ដែលនៅក្នុងភូមិខ្លះគេមិនសូវយកចិត្តទុកដាក់ ដោយគិតថាជាសកម្មភាពធម្មតាដែលវាតែងតែកើតឡើងចំពោះក្មេងៗ ហេតុនេះវាគឺពុំសូវមានអានុភាពអ្វីធ្វើអោយមានការខ្លាចរអារ ឬក៏ភ័យព្រួយនៅក្នុងភូមិនោះទេ ប៉ុន្តែបើមានការចាប់កូនក្រមុំអ្នកនៅក្នុងភូមិ ប្រហែលជាធ្វើអោយគ្រួសារដែលមានកូនក្រមុំ កូនស្រី ឬមួយក៏មានប្រពន្ធនោះភ័យ ហើយប៉ះពាល់ដល់សណ្តាប់ធ្នាប់ សន្តិសុខ ស្ថេរភាព និងចិត្តសាស្ត្រនៅក្នុងភូមិឬឃុំ-សង្កាត់-ស្រុក-ខណ្ឌ-ខេត្តហ្នឹង អញ្ចឹងជាបទល្មើស ដែលតុលាការត្រូវការពិចារណាដើម្បីផ្តន្ទាទោសអោយសមស្របទៅតាមទម្ងន់នៃបទល្មើសដែលនេះគឺជាគោលការណ៍មួយគួរពិចារណា ។ បើក្នុងករណីគាត់ពិចារណាឃើញថាករណីលួចមាន់ លួចនំប៉ុងនេះ គាត់អាចផ្តល់នូវស្ថានសម្រាលទោសតាមមាត្រា ៩៣ បើកាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទតម្រូវ តុលាការអាចសម្រេចអោយជនជាប់ចោទទទួលបានស្ថានសម្រាលទោស[7]។ ដូច្នេះនៅពេលដែលឈានទៅដល់ការប្រកាសពិរុទ្ធភាព តុលាការពិចារណាថា តើត្រូវប្រកាសទោសបែបណា? តើត្រូវកាត់ទោសដោយគ្មានស្ថានសម្រាល ? ដោយអនុវត្តគោលការណ៍ធម្មតា ឬប្រកាសទោសដោយយកស្ថានទម្ងន់ឬស្ថានសម្រាលមកពិចារណាជាមូលដ្ឋាន ? ដូច្នេះករណីដែលលួចតូចតាចបែបនេះ គឺតុលាការអាចប្រកាសនូវស្ថានសម្រាលទោស កាលណាតុលាការផ្តល់ស្ថានសម្រាលទោសតាមមាត្រា ៩៣ អានុភាពនៃស្ថានសម្រាលទោសនាំអោយកើតមានអានុភាពបន្ថយនូវអប្បបរមានៃទោសដែលច្បាប់កំណត់ ។ ពិសេសនៅក្នុងមាត្រា ៩៤ ករណីនៃអំពើលួចនេះគឺចូលនៅក្នុងចំណុចទី៤ ព្រោះបើសិនជាអប្បបរមានៃទោសដាក់ពន្ធនាគារស្មើឬលើសពី ៦ ថ្ងៃ ហើយតិចជាង ២ ឆ្នាំ អប្បបរមានៃទោសនោះត្រូវបន្ថយត្រឹម ១ ថ្ងៃ ។ បើបទល្មើសលួចមានអប្បបរមាត្រឹមតែ ៦ ខែ គឺចូលទៅក្នុងចំណុចទី៤ នៃមាត្រា ៩៤ ហើយពីព្រោះវានៅចន្លោះពី ៦ ថ្ងៃ ទៅ ២ ឆ្នាំ ។ អញ្ចឹងតុលាការបន្ថយអប្បរមាមកនៅត្រឹម ១ ថ្ងៃ សរុបមកនៅពេលដែលតុលាការប្រកាសទោស

[7] មាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

តុលាការនឹងមានមូលដ្ឋានច្បាស់លាស់នៅក្នុងការប្រកាសទោសតាមបច្ចេកទេសថ្មីគឺពី ១ ថ្ងៃ ទៅ ៣ ឆ្នាំ បានន័យថា បទល្មើសលួចដែលមានស្ថានសម្រាលគឺទោសថ្មីដែលតុលាការយកមកពិចារណាស្មើពី ១ ថ្ងៃ ទៅ ៣ ឆ្នាំ ។ អញ្ចឹងតុលាការអាចប្រកាសនូវទោសដាក់ពន្ធនាគារត្រឹមតែ ១ ថ្ងៃ ក៏ប៉ុន្តែទោស ១ ថ្ងៃនេះគឺជាទោសមជ្ឈិមដដែល ថ្វីត្បិតតែយើងមើលឃើញថាតិចជាង ៦ ថ្ងៃក៏ដោយ ពីព្រោះជាធម្មជាតិនៃបទមជ្ឈិមក្នុងអំពើលួចតាមមាត្រា ៣៥៦ មិនមែនចេញមកអំពីលហុនោះទេគឺចេញមកពីបទមជ្ឈិមដដែល ពីព្រោះយើងត្រូវមើលតែទៅលើទោសដែលដាក់ពន្ធនាគារកំណត់នៅក្នុងច្បាប់ឬចែងដោយច្បាប់តែប៉ុណ្ណោះ ។ ចំណែកឯប្រាក់ពិន័យក៏ត្រូវបន្ថយពាក់កណ្ដាលនៃអប្បបរមាដែរ ដូច្នេះកម្រិតទោសថ្មីសម្រាប់ទោសពិន័យជាប្រាក់គឺពី ៥០០.០០០ (ហាសិបម៉ឺន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អញ្ចឹងតុលាការអាចប្រកាស ៥០.០០០ (ហាសិបម៉ឺន) រៀលបាន ។ នេះគឺជាគោលការណ៍ ដែលថាបើសិនជាតុលាការឈានទៅដល់ការប្រកាសទោសអំពីបទល្មើសលួចដែរតែតូចតាចតិចតួច។ មួយទៀត គឺមានយន្តការនៃការប្រកាសទោសផ្សេងៗទៀត ករណីនេះតុលាការមិនប្រកាសមូលទោសទេ តែគាត់ប្រកាសទោសជំនួសមានទោសការងារសហគមន៍ ឬក៏ទោសស្តីបន្ទោសជាដើម ។ ក្រៅពីនេះគឺមានយន្តការផ្សេងទៀតដូចជា របបនៃការព្យួរទោស ( ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង) ដែលតុលាការអាចប្រើដោយឈរទៅលើគោលការណ៍ឯកត្តកម្មនៃទោស មានន័យថា យកទោសទៅអនុវត្តអោយសមជាមួយនឹងស្ថានភាពនៃបុគ្គលិកលក្ខណៈរបស់បុគ្គល ហើយមានអានុភាពអាចអប់រំកែប្រែបុគ្គលនោះ ក្រោយពេលបុគ្គលនោះបានអនុវត្តទោសរួច នេះហើយជាគោលការណ៍សំរាប់តុលាការប្រើប្រាស់ ។ រីឯប្រព័ន្ធទី ២ ៖ ប្រព័ន្ធដែលគេផ្តល់អំណាចដល់ព្រះរាជអាជ្ញាក្នុងកិច្ចចោទប្រកាន់របស់ខ្លួនគឺ “កាលានុវត្តភាពនៃការចោទប្រកាន់” ដែលមានចែងនៅក្នុងមាត្រា ៤០ និងមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ យោងតាមមាត្រាទាំងនេះគឺ ព្រះរាជអាជ្ញាមានអំណាចតម្កល់រឿងទុកឥតចាត់ការ បើទោះបីជាអំពើដែលប្តឹងមកនោះជាបទល្មើសក៏ដោយ តែត្រូវពិចារណាទៅលើបុគ្គលភាពនៃជនល្មើស ស្ថានភាពនៃការប្រព្រឹត្តបទល្មើស និងផលប៉ះពាល់ដែលបង្កដោយបទល្មើស។

អញ្ចឹងបើចូលទៅក្នុងលក្ខណៈនេះ ព្រះរាជអាជ្ញាបានយល់ឃើញថាពុំចាំបាច់ធ្វើការចោទប្រកាន់ នាំអោយតុលាការកកស្ទះដោយសារសំណុំរឿងគ្រាន់តែលួចមាន់ លួចទាកំប៉ិកំប៉ុក គាត់

មានសិទ្ធិតម្កល់រឿងទុកឥតចាត់ការ។ ប៉ុន្តែមិនបានន័យថាអ្នកនោះរួចខ្លួននោះទេ ពីព្រោះដីកាតម្កល់រឿងទុកឥតចាត់ការពុំមានអាជ្ញាអស់ជំនុំនោះឡើយ ដូច្នេះអយ្យការអាចកែប្រែ សើរើគ្រប់ពេលវេលា និងមានតែលក្ខខណ្ឌតែមួយគត់ដែលព្រះរាជអាជ្ញាត្រូវតែគោរពគឺអាជ្ញាយុកាល ដែលអាជ្ញាយុកាលចំពោះបទមជ្ឈិម ៥ ឆ្នាំ ហើយចាប់រាប់ពីដីកាតម្កល់រឿងទុកឥតចាត់ការបានសញ្ញេវាយត្រាចេញ ។ ស្រាប់តែ ២ ឆ្នាំក្រោយមកវាទៅលួចមាន់ ឬលួចទំប៉ុងទៀត ពេលនោះតុលាការអាចធ្វើការចោទប្រកាន់ទាំងពីរបទល្មើសតែម្តង ។ បែបនេះគឺជាយន្តការនៃប្រព័ន្ធក្នុងការកម្រិតទោសមួយដែលមានភាពច្បាស់លាស់ ហើយត្រូវកែសម្រួលដោយប្រព័ន្ធនៃអំណាចដ៏ទូលំទូលាយដែលផ្តល់ទៅអោយព្រះរាជអាជ្ញា និងចៅក្រម ។ ឥឡូវយើងសុំបញ្ចប់នៅបញ្ហាផ្សេងៗដែលជាជំនួយស្មារតីតែត្រឹមប៉ុណ្ណឹង ។ ឥឡូវយើងចូលមាត្រាដែលមានចែងនូវស្ថានទម្ងន់វិញម្តង ៖

**២. ករណីមានស្ថានទម្ងន់ទោស**

មានចំនួន ៤ សណ្ឋានចាប់ពីមាត្រា ៣៥៧ ដល់ មាត្រា ៣៦០ ដូចក្នុងការសម្រាយជូន

**២.១ ប្រព្រឹត្តអំពើហិង្សា**

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចខាងក្រោម៖

១.អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលហិង្សា ។

២.អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ[៩] ។

បើកាលណាយើងផ្គុំមាត្រា ៣៥៣ និងមាត្រា ៣៥៧ បានទៅជាបទល្មើសមួយហៅថា "អំពើលួចដោយសារការប្រព្រឹត្តអំពើហិង្សា" ដែលត្រូវផ្តន្ទាទោសដូចខាងលើ លើសពីទោសក្នុងមាត្រា ៣៥៦ ហើយ ។ នេះបើយើងគិតទៅតាមគោលការណ៍ដែលកំណត់នៅក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា ៤៦ (និយមន័យនៃបទឧក្រិដ្ឋ) សម្រាប់បទល្មើសដែលមានចែងនៅក្នុងមាត្រា ៣៥៧ ត្រូវដាក់ពន្ធនាគារចំនួន ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ នោះគឺជាបទឧក្រិដ្ឋដោយសារតែអតិបរមានៃទោសដាក់ពន្ធនាគារដែលចែងនៅក្នុងច្បាប់នេះលើសពី ៥ ឆ្នាំ ។

យើងមើលឃើញនៅក្នុងក្រមព្រហ្មទណ្ឌនេះ ពុំមាន **បទប្លន់** នោះទេ និងពុំមានសកម្មភាពឆក់នោះទេ ចំណែកឯនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលក៏ពុំមានបទឆក់ដែរ ប៉ុន្តែនៅក្នុងករណីជាក់ស្តែង

[៩] មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ប្រចាំថ្ងៃយើងមានអំពើឆក់ ។ តើអំពើឆក់កាបូបលុយ ឆក់គ្រឿងអលង្ការជាអំពើលួចធម្មតា ឬលួចដោយហិង្សា ? នៅក្នុងប្រព័ន្ធច្បាប់របស់យើងនេះអត់បានវិភាគដូចករណីប្រព័ន្ធអង់គ្លូសាក់សុង គឺបែងចែកលួចដោយមានវត្តមានរបស់ម្ចាស់ និងលួចនៅពីក្រោយខ្នងម្ចាស់បានន័យថាម្ចាស់អត់ដឹងដែលគេចែករវាង ឡាសិននី និងរ៉បបឺរី ។ ឡាសិននី គឺជាអំពើលួចដែលអវត្តមានរបស់ម្ចាស់ ចំណែកឯ រ៉បបឺរី គឺជាអំពើលួចដែលអាចមានពេលខ្លះមានវត្តមានរបស់ម្ចាស់ហើយពេលខ្លះទៀតមានអំពើហិង្សាផងដែរ ។ នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌខ្មែរ គឺអត់ខ្វល់ពីរឿងលួចអោយម្ចាស់ដឹងឬមិនដឹងនោះទេ តែអ្វីដែលយើងចាប់អារម្មណ៍នោះ គឺមធ្យោបាយក្នុងការដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃ ជាការដកហូតដោយពុំមានការប្រើអំពើហិង្សា នាំឲ្យប៉ះពាល់ដល់បូរណភាពរូបរាងកាយនិងអាយុជីវិតរបស់ជនរងគ្រោះ ឬក៏ការដកហូតដោយប្រើមធ្យោបាយដោយប្រើអំពើហិង្សាអំពើដែលគ្រោះថ្នាក់ទៅដល់អាយុជីវិត ឬទៅដល់បូរណភាពបុគ្គលរងគ្រោះ នេះគឺជាចំណុចដ៏សំខាន់ដែលយើងគួរគិតគូរ ។ អញ្ចឹងបើការដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃដោយមិនបានប៉ះពាល់ទៅដល់បូរណភាពរបស់បុគ្គល ទៅដល់អាយុជីវិតរបស់ជននោះ ឬក៏សកម្មភាពដកហូតនេះនៅពេលដែលយើងពិចារណាទៅមិនមែនជាសកម្មភាពដែលប្រកបដោយភាពគ្រោះថ្នាក់នោះទេ ដូច្នេះជាគោលការណ៍យើងផ្តន្ទាទោសតាមមាត្រា ៣៥៦ ដែលជាទោសធម្មតា ។ ក៏ប៉ុន្តែ បើក្នុងពេលជនល្មើសបានប្រើមធ្យោបាយដែលមានលក្ខណៈគ្រោះថ្នាក់ដើម្បីដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ហេតុនេះវាអាចមានរូបភាពនៃបទល្មើសមួយទៀតដែលនាំឲ្យក្លាយជាបទឧក្រិដ្ឋ (អំពើលួចដោយប្រើហិង្សា) ។

ចំណុចមួយទៀត ដែលពាក់ព័ន្ធនឹងគោលគំនិតនៃហិង្សានេះ គឺហិង្សាអាចអនុវត្តទៅលើបុគ្គលនៃជនរងគ្រោះ ឬហិង្សាទៅលើទ្រព្យសម្បត្តិ ។ តែគំនិតដែលតាមការអនុវត្តកន្លងមកនៅក្នុងប្រទេសកម្ពុជាយើងនេះ គឺផ្តោតសំខាន់ទៅលើតែបុគ្គលនៃជនរងគ្រោះ ។

ចំពោះការកាប់គាស់ទម្លុះទំលាយ គឺជាអំពើបង្ខំធ្វើឲ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬរបងទោះបីមានប្រភេទយ៉ាងណាក៏ដោយ[៩]។ ប្រសិនបើមានបទល្មើសលួច ដែលមានការកាប់គាស់ទម្លុះទម្លាយនេះ ក៏គេចាត់ទុកចូលក្នុងការលួចដោយប្រើប្រាស់ហិង្សាផងដែរ។

[៩] សន្ទានុក្រមពាក្យច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ២០១១

ឧទាហរណ៍៖ ថាមានអ្នកដំណើរម្នាក់គាត់កំពុងតែជិះម៉ូតូកាន់កាបូប នៅពេលដែលពួកក្មេងៗ មកដល់ក៏ឆក់កាបូបយកទៅបាត់ ដោយមិនមានដាច់ស្បែក ឬក៏អ្នកដំណើរហ្នឹង អត់ធ្លាក់ពីលើម៉ូតូនោះទេ ។ តើអង្គហេតុនេះ ត្រូវចោទប្រកាន់ពីបទអ្វី ?

ឧទាហរណ៍៖ មួយទៀតគឺឆក់ខ្សែក មុននឹងដាច់ខ្សែក មានរលាត់ស្បែក ហើយធ្លាក់ពីលើម៉ូតូ និងពេលខ្លះទៀតមានរហូតដល់អ្នកអង្គុយពីលើម៉ូតូធ្លាក់បោកក្បាលនឹងជុំថ្មស្លាប់ បាត់ទៅ ? តាមដែលក្រុមការងាររបស់ក្រសួងយុត្តិធម៌ បានចុះទៅផ្សព្វផ្សាយ សឹងតែគ្រប់ខេត្តទៅហើយ និងបានដកស្រង់នូវគំនិតក៏ដូចជាការអនុវត្តរបស់ តុលាការនៅតាមគ្រប់ខេត្ត ឃើញថាអំពើឆក់នេះ នៅក្នុងករណីដែលពុំមានប៉ះ ពាល់ទៅដល់បូរណភាព(ភាពពេញបរិបូរណ៍)របស់បុគ្គលដែលជាជនរងគ្រោះ គឺ គេចោទប្រកាន់មាត្រា ៣៥៦ ។ ប៉ុន្តែប្រសិនបើមានការប៉ះពាល់ទៅដល់ បូរណភាពបុគ្គលជាជនរងគ្រោះ ឬក៏ប្រើវិធីដែលមានគ្រោះថ្នាក់នោះនឹងចូលទៅ មាត្រា ៣៥៧ វិញម្តង ។ ម្យ៉ាងទៀតបើពេលចូលទៅលួចមានការកាប់គាស់ទម្លុះ ទម្លាយស្របតាមមាត្រា ៧៩ នៃក្រមព្រហ្មទណ្ឌ ក៏ចូលជា(អំពើលួចដោយប្រើ ហិង្សា)ដែរ ដូច្នេះជាបទឧក្រិដ្ឋដូចគ្នា ។

ក្រៅពីនេះ បើសិនជាលួចដោយសារការប្រព្រឹត្តអំពើហិង្សារួចហើយ ថែមទាំងមានការកាត់ អវយវៈ ឬពិការភាព ,ដោយប្រើទារុណកម្ម ឬអំពើឃោរឃៅ, ដោយសារមរណភាពនៃជនរងគ្រោះ ដូច្នេះវានឹងមានស្ថានទម្ងន់ទោសកាន់តែកើនឡើងជាលំដាប់គឺ៖

### ២.២ ការកាត់អវយវៈ ឬពិការភាព

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ប្រសិនបើអំពើនេះ ប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ដែលនាំឲ្យមានការកាត់អវយវៈ ឬពិការភាពជា អចិន្ត្រៃយ៍[10]។

ទាក់ទងជាមួយនឹងការកាត់អវយវៈនេះ ខ្ញុំសូមបញ្ជាក់បន្តិចនូវពាក្យអវយវៈនេះគឺនៅក្រមព្រហ្មទណ្ឌ មិនមែនមានតែមាត្រា ៣៥៨មួយទេ។ នៅត្រង់កន្លែងបទល្មើសពាក់ព័ន្ធជាមួយនឹងអំពើហិង្សា បទល្មើសពាក់ព័ន្ធជាមួយអំពើទារុណកម្ម និងអំពើឃោរឃៅក៏មានប្រើពាក្យថា អវយវៈ ផងដែរ។

[10] មាត្រា ៣៥៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

អវយវៈ បើតាមន័យក្នុងវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត គឺបានប្រើនៅក្នុងន័យទូលាយ ឬន័យទូទៅដែលប្រើច្រើនបំផុតនោះគឺសំដៅលើសរីរាង្គកាយយើងទាំងមូល ស្បែក ត្រចៀក ច្រមុះ ភ្នែក មាត់ និងកន្លែងណាក៏ជាអវយៈដែរ ហើយអវយវៈនេះក៏អាចបែងចែកបន្តទៅទៀតមាន អវយវៈចម្បង ឬសំខាន់ មានដៃ ជើង ច្រមុះ ត្រចៀក មាត់ ភ្នែក ដូច្នេះទើបមានសំណួរថា ចុះបើឆក់ខ្សែក មានដាច់ស្បែកបន្តិចបន្តួច តើជាកាត់អវយវៈដែរឬទេ? អញ្ចឹងអវយវៈនៅក្នុងន័យទូលាយនេះ គឺប្រើសំដៅដល់បូរណភាពបុគ្គល ដូច្នេះ បើកាលណាប៉ះពាល់ដល់បូរណភាពបុគ្គល ដូចជាមានដាច់ ឬមានកាត់ត្រង់ណាមួយនោះគឺ ចូលក្នុងន័យ នៃការកាត់អវយវៈហើយ។

នៅក្នុងអំពើទារុណកម្ម គឺមានការចាប់ធ្វើទារុណកម្មហើយក៏យកកាំបិតមកអាស្បែកម្តងបន្តិច ឬអង្កន់យកស្បែកម្តងបន្តិចៗ ក៏ប៉ុន្តែអត់មានដាច់ដៃ ឬដាច់ម្រាមដៃនោះទេ តើចាត់ទុកជាការកាត់អវយវៈដែរឬទេ? នេះគឺមិនបាច់ចាំតែដាច់ម្រាមដៃនោះទេ ឲ្យតែមានអាសាច់នៅត្រង់កន្លែងណាបន្តិចក៏គេហៅថាជាការកាត់អវយវៈដែរ។

### ២.៣ ការធ្វើទារុណកម្ម និងអំពើឃោរឃៅ

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើទារុណកម្ម ឬអំពើឃោរឃៅ[11]។

ទារុណកម្មខ្លះមិនមានការកាត់អវយវៈ ឯទារុណកម្មខ្លះទៀត នាំឲ្យមានពិការភាព ឬមានការកាត់នូវអវយវៈ ដែលនាំឲ្យមានទោសខុសគ្នា។

### ២.៤ មរណភាពនៃជនរងគ្រោះ

អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ដែលបណ្តាលឲ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់[12]។

ឧទាហរណ៍ទី១៖ ជនរងគ្រោះមកដដែល ចោរមកស្ទាត់ដណ្តើមយកម៉ូតូ តែម្ចាស់មិនអោយក៏មានការវាយប្រតប់គ្នា រួចចោរក៏ដាក់មួយស្វ័យកាំភ្លើងទៅ ក៏ត្រូវរបួសធ្ងន់នៅពេលទៅដល់មន្ទីរពេទ្យក៏ស្លាប់បាត់ទៅ។

---

[11] មាត្រា ៣៥៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[12] មាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ឧទាហរណ៍ទី២៖ មានករណីដដែលមួយទៀតគឺគាត់ដកកាំភ្លើងភ្ជង់ ឲ្យជនរងគ្រោះប្រគល់ម៉ូតូ រួចចោរនោះក៏យកម៉ូតូជិះចេញទៅបាត់ដោយសុវត្ថិភាព។

ឧទាហរណ៍ទី៣៖ មានជនល្មើស ២ នាក់ គាត់ពួននៅចាំកន្លែងផ្លូវមួយ នៅពេលដែលមានអ្នកដំណើរជិះម៉ូតូមកដល់គាត់ដកកាំភ្លើងបាញ់ផ្ទងស្លាប់បាត់រួចក៏យកម៉ូតូទៅបាត់ទៅ។

សួរថា៖ តើករណីទាំង៣នេះ ជាបទល្មើសអ្វីខ្លះ?

ករណីទីមួយ៖ គឺចូលក្នុងមាត្រា ៣៦០ មានន័យថា មានការប្រើហិង្សាដោយប្រវាយប្រតប់គ្នាទៅវិញទៅមក ហើយបណ្តាលអោយជនរងគ្រោះស្លាប់នៅពេលដល់មន្ទីរពេទ្យងណោះ រីឯជនល្មើសអត់មានចេតនាសម្លាប់ឬចង់ឲ្យជនរងគ្រោះស្លាប់ទេ គឺមានចេតនាចង់តែបានម៉ូតូ ផ្ទុយទៅវិញបើជនល្មើសមានចេតនាសម្លាប់វិញ គឺវាត្រូវចូលទៅក្នុងឃាតកម្មងណោះ ។ តែបើគ្មានចេតនាសម្លាប់ ហើយមានការវាយប្រតប់គ្នារហូតធ្វើអោយជនរងគ្រោះស្លាប់ គឺត្រូវចូលទៅក្នុងមាត្រា ៣៦០ (ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ) ។

ករណីទីពីរ៖ កាលពីមុនយើងហៅថាប្លន់ ពីព្រោះភ្ជង់ដើម្បីអោយអ្នកជិះម៉ូតូប្រគល់មកអោយខ្លួនប្រគល់សោរមកអោយខ្លួន រួចចោរជិះម៉ូតូចេញទៅដោយសុវត្ថិភាព។ ចំណែកឯក្រមព្រហ្មទណ្ឌរបស់យើងគឺមិនចូលទៅក្នុងមាត្រា ៣៥៧ ទេ ពីព្រោះមិនបានប្រើហិង្សាទាំងមុនពេល ទាំងក្នុងពេល និងទាំងក្រោយពេល ។ តែត្រូវចូលមាត្រា ៣៦៣ គឺបទកំហែងយក ពីព្រោះមានការគំរាមគំហែងថានឹងប្រើហិង្សាដែលត្រូវពន្យល់ផ្គុំគ្នាជាមួយនឹងមាត្រា ៣៧២។

ករណីទីបី៖ គឺជាបទឃាតកម្ម ដោយសារជនរងគ្រោះមកដល់គឺមានកាក់ម៉ូតូហើយក៏ដកកាំភ្លើងបាញ់បណ្តាលអោយស្លាប់ ។ ដូច្នេះ សកម្មភាពបន្ទាប់ដែលជាមូលហេតុនៃការប្រព្រឹត្តបទល្មើសមិនសំខាន់ទេ តែសំខាន់គឺត្រង់ថាចេតនារបស់វាគឺចេតនាសម្លាប់មនុស្ស ។ ឯត្រង់ថាគោលបំណងនៃការសម្លាប់នេះ ដើម្បីយកវត្ថុ ឬរំលោភ ឬយកអ្វីផ្សេងៗគឺអត់សំខាន់ទេ ។ អញ្ចឹងអ្វីដែលសំខាន់នោះគឺចេតនាប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោស ដូចមានចែងនៅក្នុងមាត្រា ៤ ថា “ពុំមានបទល្មើសទេ ប្រសិនគ្មានចេតនាប្រព្រឹត្ត” នេះជាគោលការណ៍ ។ ដូច្នេះគេយកចេតនាប្រព្រឹត្តបទល្មើសនេះដើម្បីជាមូលដ្ឋាននៅក្នុងការប្រព្រឹត្តបទល្មើស ។ សរុបមក ករណីនេះគឺជាអំពើឃាតកម្ម (មាត្រា ១៩៩) មិនមែនគិតទុកជាមុន (មាត្រា ២០០) នោះទេ ពីព្រោះមិនចូលក្នុងការពួនស្ទាក់ឡើយ ។ សញ្ញាណដែលយើងចង់បញ្ជាក់នៅទីនេះគឺមានការពួនស្ទាក់នោះ លុះត្រាតែជនល្មើសមានស្គាល់

អត្តសញ្ញាណរបស់ជនរងគ្រោះដែរទើបអាចហៅថាជាការពួនស្ទាក់បាន” ។ ដូចជាការដឹងថាលោក ក ច្រើនតែចេញពីធ្វើការនៅម៉ោង៥.៣០ ល្ងាច ជិះកាត់ផ្លូវមុន្នីវង្ស រួចបត់ចូលទៅកន្លែងមេភ្លើង ហើយចោរក៏រកឱកាសពេលណាដែលស្ងាត់ ដើម្បីធ្វើសកម្មភាពដោយប្រើហិង្សាទៅលើជនរងគ្រោះ ដោយស្គាល់អត្តសញ្ញាណជនរងគ្រោះ នេះបានទៅពួនស្ទាក់។ ឯករណីអម្បាញ់មិញនេះ គឺចោរអត់មានចាប់អារម្មណ៍អំពីអត្តសញ្ញាណរបស់ជនរងគ្រោះនោះទេ មានន័យថា អោយតែម៉ូតូណាល្អៗមកដល់ទើបបាញ់តែម្តង ។ ដូច្នេះមានសេចក្តីថាពួកចោរអត់បានគិតចម្បងទៅលើអត្តសញ្ញាណរបស់ជនរងគ្រោះនោះទេ ហេតុនេះអត់ចូលទៅក្នុងសញ្ញាណនៃការពួកស្ទាក់ទេ ។ នេះគឺជាសញ្ញាណមួយដែលនៅក្នុងយុត្តិសាស្ត្ររបស់តុលាការបារាំង គេមានពិចារណាដល់ហើយទុកអោយតុលាការខ្មែរត្រិះរិះពិចារណាអំពីសញ្ញាណថ្មីមួយនេះផងដែរនៅកម្ពុជា ។

**៣. ទោសបន្ថែម**

មានចែងចំនួន១៦ចំណុច ក្នុងចំណោម១៩ចំណុចនៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) ក្នុងក្រមព្រហ្មទណ្ឌ) ដូច្នេះបើមាត្រា ៣៦២ ចែងនូវទោសបន្ទាប់បន្សំនេះតែប៉ុណ្ណឹងបានសេចក្តីថាទោសបន្ថែមចំនួន ៣ ផ្សេងទៀតដែលមិនបានចែង គឺចៅក្រមមិនត្រូវយកមកប្រកាសកើតនោះទេ។ សរុបមកចៅក្រមគឺអាច (មិនចងកាតព្វកិច្ចចំពោះចៅក្រមទេ) ប្រកាសក៏បាន មិនប្រកាសក៏បាន ក្នុងចំណោម១៦ខាងលើ ហើយបើសម្រេចប្រកាសទៅហើយ គឺត្រូវយកមកដាក់ឲ្យត្រូវនឹងស្ថានភាព ឬសាច់រឿងនីមួយផង។

**៤. អភ័យឯកសិទ្ធិគ្រួសារ**

ទាក់ទងជាមួយនឹងអភ័យឯកសិទ្ធិគ្រួសារ នៅក្នុងមាត្រា ៣៥៥ នេះបើនិយាយជារួមវាគឺជាមរតកគតិយុត្តនៃប្រព័ន្ធព្រហ្មទណ្ឌរបស់យើង ពីព្រោះនៅក្នុងក្រមព្រហ្មទណ្ឌសង្គមចាស់ក៏មាននិយាយអំពី អភ័យឯកសិទ្ធិគ្រួសារ នេះផង។ មាត្រាលើនេះបានចែងថា មិនអាចផ្តន្ទាទោសព្រហ្មទណ្ឌបានទេ៖

-អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ

-អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ[13]។

[13] មាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

មាត្រានេះគឺគេការពារតែក្នុងគ្រួសារមួយតែប៉ុណ្ណោះ បើសិនជាអ្នកដែលប្រព្រឹត្តបទល្មើសនោះមិនមែនជាអ្នកនៅក្នុងគ្រួសារនោះទេ គឺអ្នកនោះគ្មានអភ័យឯកសិទ្ធិ ឬការលើកលែងមិនឲ្យផ្តន្ទាសទោសព្រហ្មទណ្ឌតាមមាត្រា៣៥៥នេះឡើយ។ ម្យ៉ាងទៀត ចំពោះកូនសុំគេ តើក្រមយើងត្រង់មាត្រានេះ ការពារគាត់ដែរឬទេ? បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចាប់ពីមាត្រា ១០០៧ ដល់មាត្រា ១០៣៣ មានចែងអំពីសុំកូនពេញលេញ និងសុំកូនធម្មតា។ ដូច្នេះគាត់ក៏ជាកូនដែរ ស្មើនឹងគាត់ក៏ជាញាតិដែរ ហើយបើគាត់ជាញាតិដែរ មាត្រា ៣៥៥ ក៏បានការពារដល់គាត់ដែរ លើកលែងតែត្រូវបានកាត់កាលគាត់ចោលដូចក្រមរដ្ឋប្បវេណី។

ចំណាំ៖ បើយោងតាមមាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់អំពីទំហំរបស់ញាតិថាបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះគឺជាញាតិ៖

ក.ញាតិលោហិតក្នុង៦(ប្រាំមួយ)ថ្នាក់។ ខ.សហព័ទ្ធ។ គ.ញាតិពន្ធក្នុង៣(បី)ថ្នាក់។

*សហព័ទ្ធ* មានន័យថា ប្តី ឬប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

*ញាតិលោហិត* គឺញាតិដែលមានឈាមជ័រជាមួយគ្នាដូចជាឪពុក និងកូន ឬម្តាយ និងកូនជាដើម[14]។

### ៥. ការប៉ុនប៉ងក្នុងបទលួច

ដោយសារតែបទលួចជាបទមជ្ឈឹម ហេតុនេះ ការប៉ុនប៉ងក្នុងបទលួចទាមទារឲ្យមានមាត្រាច្បាប់ចែងយ៉ាងជាក់លាក់ទុកជាមុន ទើបចៅក្រមអាចប្រកាសបាន (យោងតាមទ្រឹស្តីដែលមានចែងនៅក្នុងមាត្រា ២៧) ។ ជាពិសេស ដោយសារតែយើងពិនិត្យលើមាត្រា ៣៦១ បានឃើញថាមានចែងអំពី ការប៉ុនប៉ង ពិតប្រាកដមែន។ ដូច្នេះក្នុងបទលួច ចៅក្រមអាចប្រកាសអំពីការប៉ុនប៉ងក្នុងបទលួចបាន ប្រសិនជាអំពើលួចមិនបានសម្រេចនោះទេ។

[14] មាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី២

# ការកំហែងយក

## កថាខណ្ឌទី១ សញ្ញាណទូទៅ

### ១. និយមន័យ (ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)

អំពើកំហែងយក គឺជាអំពើដែលប្រព្រឹត្តដោយការប្រើហិង្សា ការគំរាមថានឹងប្រើហិង្សា ឬដោយការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ ៖

-ហត្ថលេខា ឬស្នាមមេដៃ

-ការសន្យា ឬការបោះបង់ចោលអ្វីមួយ

-ការបង្ហាញអាថ៌កំបាំងណាមួយ

-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ[15]

### ២. និយមន័យក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល

ដោយយោងតាមច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល នៅត្រង់មាត្រា ៣៤ បានបញ្ញត្តិអំពើនេះថាជា អំពើប្លន់។ អំពើប្លន់ គឺជាការប្លន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ហើយអំពើដែលជនណាបានលួច ឬប៉ុនប៉ង លួចជនណាម្នាក់ទៀតដោយមានស្ថានទម្ងន់ទោសទាំងនេះ ៖

-ការលួចធ្វើដោយហិង្សា មានអាវុធ ឬឥតអាវុធ បណ្តាល ឬមិនបណ្តាលឲ្យមានរបួស

-ការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬដោយគ្មានការគាស់ទម្លុះទម្លាយ[16]

## កថាខណ្ឌទី២ ធាតុផ្សំនៃការកំហែងយក

### ១. ធាតុផ្សំនីត្យានុកូល

បទល្មើសនេះមានចែងយ៉ាងច្បាស់លាស់នៅក្នុងមាត្រា៣៦៣,៣៦៤,៣៦៥,៣៦៦,៣៦៧,៣៦៨,៣៦៩,៣៧០,៣៧១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ រីឯនៅក្នុងក្រមព្រហ្មទណ្ឌអន្តកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ចែងនៅត្រង់មាត្រា ៣៤ ចែងថា ជនណាដែលបានលួច ឬប៉ុនប៉ងនឹងលួចជនណាម្នាក់ទៀត ដោយមានស្ថានទម្ងន់ទោសទាំងនេះដែលរួមមាន ការលួចធ្វើដោយអំពើហិង្សា មានអាវុធ ឬឥតអាវុធ បណ្តាលឬមិនបណ្តាលឲ្យមានរបួស ឬក៏ការលួចនោះបានធ្វើឡើង

[15] មាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[16] មាត្រា ៩៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

ដោយមានគ្នាច្រើន ឬដោយមានការគាស់ទំលុះទម្លាយ ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ម៉្យាងវិញទៀត អំពើប្លន់នេះ គឺជាការបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ អំពើប្លន់នេះ ត្រូវផ្តន្ទាទោសដាក់គុក ជាបទឧក្រិដ្ឋពី ៣ (បី) ឆ្នាំ ទៅ១០ (ដប់) ឆ្នាំ។

ខាងលើនេះ ជាខ្លឹមសារតាមច្បាប់ចាស់ដែលត្រូវបាននិរាករណ៍ហើយ គឺគ្រាន់តែយកមកសិក្សាតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ចំពោះការអនុវត្តនាពេលបច្ចុប្បន្ន ត្រូវអនុលោមតាមក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ នៅត្រង់មាត្រា ៣៦៣។

យោងតាមមាត្រា ៣៦៣ គេឲ្យអត្ថន័យនៃការកំហែងយកថាជា អំពើប្រព្រឹត្តដោយការប្រើហិង្សា ការគម្រាមកំហែងថានឹងប្រើហិង្សា ឬដោយការការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ ហត្ថលេខា ឬស្នាមម្រាមដៃ ការសន្យា ឬការបោះបង់ចោលអ្វីមួយ ការបង្ហាញអាថ៌កំបាំងណាមួយ និងការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

អំពើកំហែងយកនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល។ នៅក្នុងបទល្មើសនេះ ក៏មានកំណត់អំពីស្ថានទម្ងន់ទោសផងដែរ ដែលមានដូចជា៖

-ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

-ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ

-ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព

-ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

-ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

## ២. ធាតុផ្សំសត្យានុម័ត

### ២.១ រូបភាពនៃការព្រមព្រៀងប្រគល់

ជាសកម្មភាពដែលស្តែងឡើងតាមរយៈការព្រមព្រៀងប្រគល់នូវកម្មវត្ថុនៃបទល្មើសពីជនរងគ្រោះទៅឲ្យជនល្មើសដែលបានធ្វើការកំហែងយកនោះ។ យើងអាចចោទជាសំណួរថា "មានការព្រមព្រៀងប្រគល់ហើយ ហេតុអ្វីបានជាវានៅតែជាបទល្មើស? ទោះបីជាមានការព្រមព្រៀងនេះក៏ដោយរូបភាពនៃការព្រមព្រៀង គឺកើតឡើងដោយអឆន្ទៈ និងដោយមិនសេរីនៃការប្រគល់ មានន័យថា ជនរងគ្រោះពុំមានឆន្ទៈពិតប្រាកដណាមួយដែលបង្ហាញថាខ្លួនចង់ប្រគល់ឲ្យជនល្មើសនោះទេ ប៉ុន្តែ

ដោយសារតែមានអំពើកំហែងយកពីជនល្មើស ដូចជាការប្រើហិង្សា ឬគំរាមកំហែងថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំណាមួយទើបធ្វើឲ្យជនរងគ្រោះយល់ព្រមប្រគល់ឲ្យ។ ប្រសិនបើ គ្មានការលេចចេញនៃការប្រគល់ពីជនរងគ្រោះ តែជនល្មើសធ្វើការដកហូតទុច្ចរិតដោយផ្ទាល់ នូវកម្មវត្ថុនៃបទល្មើសអំពើនោះគេមិនចាត់ទុកជាការកំហែងយកនោះទេ វាជា "អំពើលួច" ។

ឧទាហរណ៍៖ ក្មេងប្រុសម្នាក់ កំពុងអង្គុយនៅលើម៉ូតូម្នាក់ឯងកន្លែងស្ងាត់មួយ រង់ចាំមិត្តភក្តិ។ ស្រាប់តែមានជនម្នាក់បានឃើញក្មេងនោះកំពុងកាន់សោរម៉ូតូ ក៏បានចូលវៃក្មេងនោះ ដើម្បីអោយក្មេងប្រុសនោះប្រគល់សោរម៉ូតូមកឲ្យខ្លួន។ ដោយមានការភិតភ័យពេក ក្មេងប្រុសនោះក៏បានប្រគល់សោរម៉ូតូទៅឲ្យជនល្មើស រួចជននោះក៏បានជិះចេញទៅបាត់ទៅ។ នៅក្នុងករណីនេះផងដែរ គេចាត់ទុកអំពើនេះ ជាការកំហែងយក ដោយមានការព្រមព្រងប្រគល់សោរម៉ូតូពីជនរងគ្រោះ ទៅឲ្យជនល្មើស ដើម្បីសម្រេចនូវបទល្មើស។ ផ្ទុយទៅវិញ ប្រសិនបើក្មេងប្រុសនោះមិនបានប្រគល់សោរម៉ូតូនោះទេ ហើយជនល្មើសបានដកហូតម៉ូតូតាមគ្រប់មធ្យោបាយរបស់ខ្លួន ដូចជា ការកាច់កម៉ូតូដោយខ្លួនឯង ឬក៏កញ្ឆក់សោរពីដៃក្មេង នោះគេចាត់ទុកជាអំពើលួច ដោយសារតែសកម្មភាពនេះ គឺក្មេងប្រុសនោះពុំបានប្រគល់ ឬព្រមព្រៀមណាមួយនោះទេ។

**២.២ កម្មវត្ថុនៃការកំហែងយក**

ការកំហែងយក គឺស្តែងឡើងក្នុងគោលបំណងទទួលបាននូវកម្មវត្ថុមួយចំនួន ដែលបានបញ្ញត្តិយ៉ាងច្បាស់ក្នុងមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ជាគោលការណ៍ចំពោះកម្មវត្ថុនៃការកំហែងយករួមមានដូចជា៖

- ហត្ថលេខា ឬ ស្នាមម្រាមដៃ
- ការសន្យា ឬ ការបោះបង់ចោលអ្វីមួយ
- ការបង្ហាញអាថ៌កំបាំងណាមួយ
- ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ។

**២.៣ រូបរាងនៃអំពើ**

រូបរាងនៃអំពើកំហែងយក សំដៅទៅលើសកម្មភាពណាមួយរបស់ជនល្មើសដែលបានប្រព្រឹត្តទៅលើជនរងគ្រោះ មានន័យថា ជនល្មើសបានធ្វើការកំហែងយក ដែលបានប្រព្រឹត្តអំពើដូចជា ការប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំ។

**ការប្រើហិង្សា** គឺជាអំពើបៀតបៀនលើបូរណភាពលើរូបរាងកាយ តាមគ្រប់មធ្យោបាយ ឬអាចជាការធ្វើឲ្យខូចសុខភាពដោយសារតែសកម្មភាពណាមួយ។ ការប្រើហិង្សា ពេលខ្លះអាចមានស្លាកស្នាម ពេលខ្លះពុំមាននោះទេ។ ហិង្សា គឺខុសពីទារុណកម្ម ត្រង់ថាហិង្សាមានលក្ខណៈស្រាលជាង និងមិនមានសកម្មភាពប្រព្រឹត្តច្រំដែលៗនោះទេ។ ប្រសិនបើ សកម្មភាពនោះជាការប្រើហិង្សាមែន តែសកម្មភាពហិង្សានោះប្រព្រឹត្តដដែលៗ គេចាត់ទុកថាជាអំពើឃោរឃៅ។

**គំរាមកំហែងថានឹងប្រើហិង្សា** មានន័យថា មិនទាន់មានលេចចេញអំពើដែលចាត់ទុកជាអំពើហិង្សានោះទេ ប៉ុន្តែវាអាចជាការប្រើតាមរយៈពាក្យសម្ដីមកគំរាមថានឹងប្រព្រឹត្តអំពើហិង្សាណាមួយដែលប៉ះពាល់ដល់ជនរងគ្រោះ ដើម្បីឲ្យជនមានការភិតភ័យជាដើម។

**ការបង្ខិតបង្ខំ** វាជាផ្នែកមួយ ធ្វើឲ្យប៉ះពាល់ទៅដល់ផ្លូវចិត្តចំពោះជនរងគ្រោះ វាអាចជាការសម្លុត ដើម្បីបំបាក់ស្មារតីជនម្ខាងទៀត។

**៣. ធាតុផ្សំអត្តនោម័ត**

គ្រប់បទល្មើសទាំងអស់ សុទ្ធតែមានចេតនាទុច្ចរិតពីសំណាក់ជនល្មើស ក្នុងនោះមានចេតនាទុច្ចរិតទូទៅដែលជនល្មើសចង់ឲ្យជនរងគ្រោះទទួលរងនូវផលវិបាកនៃអំពើរបស់ខ្លួន។ នៅក្នុងបទល្មើសកំហែងយក គឺជនល្មើសមានចេតនាចង់បានកម្មវត្ថុទាំងនោះមកជាកម្មសិទ្ធិរបស់ខ្លួន ដោយឲ្យជនរងគ្រោះធ្វើការប្រគល់ ទាំងដឹងថាកម្មវត្ថុនោះជាកម្មសិទ្ធិរបស់ជនរងគ្រោះ។

ជនល្មើស គឺមានចេតនាចង់ឲ្យបទល្មើសដែលខ្លួនប្រព្រឹត្តផ្តល់នូវផលពិសេសណាមួយ ហើយវាក៏អាចកើតចេញពីអំពើមួយទៀតដែលជនល្មើសគ្រោងទុក។ ពេលខ្លះជនល្មើស អាចស្គាល់ពីអត្តសញ្ញាណរបស់ជនរងគ្រោះច្បាស់លាស់។

ឧទាហរណ៍៖ ជនល្មើសបានទុកកាំបិតនៅក្នុងកៃបម៉ូតូ ដោយមានគំនិតចង់ប្រព្រឹត្តបទល្មើសស្រាប់តែបានឃើញនារីម្នាក់ គាត់តែងតែដើរទៅផ្សារម្នាក់ឯងដែលតែងតែឆ្លងកាត់ផ្លូវស្ងាត់នោះជារៀងរាល់ថ្ងៃ ដែលធ្វើអោយជនល្មើសបាន ធ្វើការកំហែងយកលុយដែលក្នុងកាបូបនោះ តែនារីរងគ្រោះមិនព្រម ដែលធ្វើឲ្យជនល្មើសប្រព្រឹត្តហិង្សាដោយបានប្រើទារុណកម្មទៀតផងដែលធ្វើឲ្យនារីរងគ្រោះប្រគល់លុយនៅក្នុងកាបូបទាំងអស់។ នៅក្នុងចំណុចនេះ ចេតនារបស់ជនល្មើសគឺចង់បានទ្រព្យសម្បត្តិរបស់នារីរងគ្រោះតែប៉ុណ្ណោះ តែដោយសារនារីរងគ្រោះមិនព្រម

ប្រគល់លុយទើបធ្វើឲ្យជនល្មើសប្រព្រឹត្តទារុណកម្ម ដើម្បីឲ្យនារីនោះប្រគល់។ ត្រង់ចំណុចនេះ ជនល្មើសបានបង្កប់នូវអំពើមួយដែលជាលក្ខណៈពិសេស ក្រៅពីឆន្ទៈរបស់គាត់ចង់បានកម្មវត្ថុដែលជាទ្រព្យសម្បត្តិ គឺគាត់បានលាក់ទុកនូវកាំបិតរបស់ខ្លួន ដោយមានចេតនាពិសេសមួយចង់ឲ្យបទល្មើសដែលខ្លួនប្រព្រឹត្តនោះបានសម្រេច។

## កថាខណ្ឌទី៣ ទោសដែលត្រូវអនុវត្ត

នៅក្នុងបទល្មើសនេះ យើងសង្កេតឃើញថា មានការបែងចែកជាករណីគ្មានស្ថានទម្ងន់ទោស និងមានស្ថានទម្ងន់ទោស ។ ដើម្បីធ្វើការវែកញែក ក៏ដូចជាឲ្យដឹងថារូបភាពមួយណាជាបទល្មើសដែលគ្មានស្ថានទម្ងន់ទោស និងមានស្ថានទម្ងន់ទោសគឺវាអាស្រ័យទៅលើសកម្មភាពនៃការប្រព្រឹត្តបទល្មើស។

ដូច្នេះ ដើម្បីឲ្យបានជ្រាបច្បាស់ យើងនឹងធ្វើការបកស្រាយនៅខាងក្រោមនេះ។

### ១. ករណីគ្មានស្ថានទម្ងន់ទោស

អំពើកំហែងយកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ (បួន)លានរៀល ទៅ ១០ (ដប់)លានរៀល[17] ចំពោះករណីដែលបទល្មើសបានប្រព្រឹត្តដោយប្រើហិង្សា ការគំរាមថានឹងប្រើហិង្សា ឬដោយការបង្ខិតបង្ខំផ្សេងៗ ក្នុងគោលដៅទទួលបាននូវ ហត្ថលេខាឬស្នាមមេដៃ ការសន្យាឬការបោះបង់ចោលអ្វីមួយ ការបង្ហាញអាថិកំបាំងណាមួយ ការប្រគល់មូលនិធិ តម្លៃឬទ្រព្យសម្បត្តិអ្វីមួយ។

បើយើងក្រលេកមើល ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ គឺមានលក្ខណៈដាក់ទណ្ឌកម្មទៅលើជនល្មើសធ្ងន់ធ្ងរជាងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន ដោយធ្វើការផ្តន្ទាទោសពី ៣ (បី)ឆ្នាំ ទៅ ១០ (ដប់)ឆ្នាំ ដែលអនុលោមទៅតាមមាត្រា៣៩ ដែលច្បាប់ចាស់បានចែងបទល្មើសនោះថាជា “អំពើប្លន់” ។ យើងដឹងហើយថា ក្រមព្រហ្មទណ្ឌបច្ចុប្បន្នបានចែងអំពីការផ្តន្ទាទោសមានលក្ខណៈស្រាលជាង ក៏ដោយសារគេចង់ឲ្យបុគ្គលនោះមានការកែប្រែខ្លួន និងអាចវិលមករស់នៅក្នុងសង្គមវិញ។

លើសពីនេះទៅទៀត អំពើកំហែងយក នៅក្នុងសកម្មភាពខ្លះ តុលាការអាចធ្វើការសម្រាលទៅលើជនដែលបានប្រព្រឹត្តបទល្មើសនេះផងដែរ។ ចំពោះការសម្រាលទោសនោះ គឺអាស្រ័យទៅ

[17] មាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

តាមចៅក្រមជាអ្នកកាត់សេចក្តី ពេលខ្លះ តុលាការអាចធ្វើការពិចារណាដោយមិនឲ្យជននោះជាប់ពន្ធនាគារ ឬក៏ពិន័យជាប្រាក់ទេ ដោយគ្រាន់តែទទួលនូវទោសបន្ថែមផ្សេងៗ ឬក៏អនុវត្តទោសសហគមន៍ឬការស្តីបន្ទោសជាដើម ដោយយោងតាមមាត្រា ១០០, មាត្រា ៧២, មាត្រា ៧៦ ។ មួយវិញទៀត តុលាការមានវិធីសាស្ត្រផ្សេងៗ ដើម្បីសម្រាលទៅលើជននោះដែលបានបង្កព្យសនកម្មតិចតួចផងដែរដូចជាការព្យួរទោស (ទោះជាការព្យួរទោសធម្មតា ឬសាកល្បង) ការផ្អាកការប្រកាសទោស (ដើម្បីសង្កេតថាជននោះអាចជួសជុលព្យសនកម្មការខូចខាតដែលជននោះបានបង្កឡើង ហើយអាចធានាថាជននោះអាចចូលរួមរស់នៅក្នុងសង្គមវិញបាន)។

សរុបមកវិញមិនមែនអំពើដែលបានប្រព្រឹត្តដែលជាបទល្មើស សុទ្ធសឹងតែសម្រាលទៅលើបុគ្គលដែលបានធ្វើសកម្មភាពបទល្មើសនោះទេ គឺអាស្រ័យទៅលើតុលាការដែលត្រូវអនុលោមតាមគោលការណ៍ឯកត្តកម្មនៃទោស ដែលមានចែងនៅត្រង់មាត្រា ៩៦ ដែលផ្តល់អត្ថន័យដូចតទៅ "តុលាការប្រកាសទោសផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ចំពោះជនរងគ្រោះ[18]។

ទាំងអស់នេះគឺសម្រាប់អនុវត្តទៅលើនីតិជន ប៉ុន្តែសម្រាប់អនីតិជនវិញ ចំពោះការអនុវត្តទោសវិញ គឺមានការបន្ថយពាក់កណ្តាលនៃអតិបរិមាដែលត្រូវផ្តន្ទាទោស។ បើយើងប្រៀបធៀបរវាងនីតិជន និងអនីតិជន យើងឃើញថា ការអនុវត្តលើអនីតិជន មានលក្ខណៈស្រាលជាង ព្រោះថាអនីតិជនមានការយល់ដឹងតិចតួចជាងមនុស្សធំពេញវ័យ ឆាប់ជឿ និងងាយក្នុងការអូសទាញឲ្យប្រព្រឹត្តបទល្មើស។

**២. ករណីមានស្ថានទម្ងន់ទោស**

ប្រសិនបើមានការប្រព្រឹត្តបទល្មើសកំហែងយករួចហើយ បានបំពេញលក្ខខណ្ឌណាមួយដែលមានចែងចាប់ពីមាត្រា ៣៦៥ ដល់មាត្រា ៣៦៩ នោះជនល្មើសនឹងត្រូវទទួលនូវស្ថានទម្ងន់ទោសដូចខាងក្រោម៖

**២.១ ស្ថានទម្ងន់ទោសទាក់ទងជនរងគ្រោះ**

នៅក្នុងអំពើនេះ គឺជាការកំហែងយកទៅលើជនរងគ្រោះមួយចំនួនដែលច្បាប់កំណត់ថាត្រូវទទួលស្ថានទម្ងន់ទោស នៅក្នុងបញ្ញត្តិមាត្រា៣៦៥ បានចែងអំពីជនរងគ្រោះទាំងនោះដូចជា៖

[18] មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ

-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង

-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាព បុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង[19]។

### ២.១.១ បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុ

ក្នុងការថែងទាក់ទងនឹងបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុ យើងឃើញថា ការកំណត់លើអាយុ អាចសិក្សាទៅលើអនីតិជន និងជនចាស់ជរា។ នៅក្នុងលក្ខខណ្ឌនេះ យើងមិនអាចកំណត់អំពីតួលេខនៃអាយុបានច្បាស់លាស់នោះទេ ថាតើប្រភេទនៃជនទាំងពីរ ស្ថិតនៅក្នុងស្ថានភាពទន់ខ្សោយពិសេសចាប់ពីអាយុប៉ុន្មាន?

ក្នុងចំណុចនេះ មូលហេតុនៃអាយុវាមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់នោះទេ ប៉ុន្តែមូលដ្ឋានដែលសំខាន់មួយទៀតនោះគឺ ភាពទន់ខ្សោយពិសេសរបស់ជនរងគ្រោះ។ នៅក្នុងសង្គមបច្ចុប្បន្ន ករណីជនរងគ្រោះជាអនីតិជន ពេលខ្លះគាត់មានសមត្ថភាព កម្លាំងពេញលេញ ទោះក្នុងនាមជាអនីតិជនក៏ដោយ ក៏គេមិនចាត់ទុកជាភាពខ្សោយពិសេសនោះទេ ប៉ុន្តែអនីតិជនខ្លះមានសមត្ថភាពចុះខ្សោយ ដោយកំណើតពីក្មេង ធ្វើឲ្យស្គមស្គាំង ដើរញើរញ័រ ចំណុចនេះ ទើបគេចាត់ទុកថាប្រភេទមនុស្សទន់ខ្សោយពិសេស។

ឧទាហរណ៍ ៖ បុគ្គល “ក” បានឃើញក្មេងប្រុសម្នាក់ អាយុ៨ឆ្នាំដែលអង្គុយចាំឪពុកនៅលើម៉ូតូនៅមុខរបងផ្ទះ។ នៅពេលដែលឪកាសល្អ ដោយបុគ្គល “ក” បានឃើញក្មេងនោះកំពុងកាន់សោរម៉ូតូនៅនឹងដៃ ជននោះក៏ធ្វើការកំហែងយកម៉ូតូពីក្មេងប្រុសនោះ។ នៅពេលនោះ បុគ្គលនោះបានវៃទៅលើក្មេងប្រុស ហើយទាមទារប្រគល់សោរមកឲ្យខ្លួន ដោយការភ័យពេក និងគ្មានកម្លាំងតបត ទើបធ្វើឲ្យក្មេងប្រុសនោះប្រគល់សោរទៅឲ្យបុគ្គល “ក” ។ តើករណីនេះ យើងអាចធ្វើការចោទប្រកាន់ទៅលើបទល្មើសអ្វី?

ដំណោះស្រាយ៖ យោងតាមមាត្រា ៣៦៣ និង មាត្រា ៣៦៥ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ អំពើខាងលើនេះ ចាត់ចូលជាការ “កំហែង

[19] មាត្រា ៣៦៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

យកមានស្ថានទម្ងន់ទាក់ទងនឹងជនរងគ្រោះ”។ បើយើងមើលទៅករណីខាងលើ បុគ្គល “ក” បានប្រើហិង្សាដោយវៃទៅលើក្មេងប្រុសនោះដែលមានអាយុត្រឹមតែ ៨ឆ្នាំប៉ុណ្ណោះ រួមផ្សំទាំងខ្សោយនូវកម្លាំងពុំអាចធ្វើការតបតទៅលើបុគ្គលនោះបាន ទើបធ្វើអោយក្មេងប្រុសនោះប្រគល់សោរម៉ូតូឲ្យបុគ្គល “ក”។ ក្នុងមាត្រា ៣៦៥ ចំណុចទី១ បានបញ្ញត្តិអំពីស្ថានទម្ងន់ទោសប្រព្រឹត្តលើបុគ្គលទន់ខ្សោយពិសេសដោយសារមូលហេតុអាយុ។ ដូចនេះ បុគ្គល “ក” ត្រូវជាប់បទល្មើសកំហែងយក ដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ។

ចំពោះជនចាស់ជរា យើងក៏មិនអាចសន្និដ្ឋានលើគោលការណ៍អាយុ របស់ពួកគាត់នោះទេ ប៉ុន្តែយើងអាចសិក្សាទៅលើកម្លាំងនៃការតបត ចំពោះបទល្មើសដែលបានប្រព្រឹត្តមកលើពួកគាត់។ ពាក្យថា ចាស់ជរា យើងអាចសន្មតអាយុពីចន្លោះ ៧៥ឆ្នាំឡើងទៅ ប៉ុន្តែ យើងអាចពិចារណាទៅលើសភាពជាក់ស្តែង ភាពខ្វះលទ្ធភាពទប់ទល់នៃការការពារខ្លួនរបស់ជននោះ។

ឧទាហរណ៍ ៖ លោកយាយចំណាស់ម្នាក់ បានដើរសំដៅទៅផ្សារដើម្បីទៅទិញឥវ៉ាន់។ ស្របពេលនោះ លោកយាយដែលមានអាយុ៧៧ឆ្នាំ ដើរឆ្លងកាត់ផ្លូវស្ងាត់មួយ ហើយបានជួបនឹងបុរស “ក” ដែលឈរនៅទីនោះ។ ភ្លាមៗនោះ បុរស “ក” បានដើរទៅរកគាត់ ហើយច្របាច់ករបស់គាត់ និងឲ្យគាត់ប្រគល់ប្រាក់ទាំងអស់មកឲ្យខ្លួន។ ដោយទ្រាំពុំបាននឹងការប្រើហិង្សាទៅលើគាត់ និងភាពចាស់ជរាដែលពុំអាចមានកម្លាំងតបតបាន ស្ត្រីចំណាស់នោះក៏បានប្រគល់ប្រាក់ទាំងអស់ទៅឲ្យបុរស “ក” ។ តើអំពើនេះ អាចមានស្ថានទម្ងន់ទោសដែរឬទេ?

ដំណោះស្រាយ ៖ លោកយាយចំណាស់ មានអាយុ ៧៧ឆ្នាំ ត្រូវបានបុគ្គល “ក” ច្របាច់ក ដើម្បីឲ្យលោកយាយនោះ ប្រគល់ប្រាក់ទាំងអស់មកឲ្យខ្លួន ដោយភាពចាស់ជរាពុំអាចតដៃទៅលើបុរសនោះ គាត់ក៏បានប្រគល់ប្រាក់ទាំងអស់មកឲ្យបុរស “ក” ។ យោងតាមមាត្រា ៣៦៣ និង ៣៦៥ ចំណុចទី១ យើងឃើញថា ជននោះបានធ្វើការប្រើហិង្សាទៅលើលោកយាយចំណាស់នោះ ដែលគេចាត់ទុកជាប្រភេទបុគ្គលទន់ខ្សោយពិសេស ដោយអាយុរបស់គាត់ស្ថិតក្នុងភាពចាស់ជរា គ្មានសមត្ថភាពក្នុងតបតទៅលើអំពើដែលបានប្រព្រឹត្តមកលើខ្លួន ទើបបុគ្គល “ក” អាចប្រើហិង្សា ក្នុងការ

កំហែងយកទ្រព្យសម្បត្តិរបស់គាត់បាន។ ដូចនេះ បុគ្គល "ក" ត្រូវជាប់ពីបទល្មើសកំហែងយក ដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ។

**២.១.២ បុគ្គលដែលជានារីមានគភ៌**

ការប្រព្រឹត្តបទល្មើសកំហែងយក ដោយមានស្ថានទម្ងន់ទោស ទៅលើស្ត្រីមានគភ៌ត្រូវគេវែកញែកជា២ករណី៖

ករណីទី១៖ ជនល្មើសប្រព្រឹត្តការកំហែងយកលើស្ត្រីដែលមានផ្ទៃពោះលេចចេញយ៉ាងជាក់ស្តែង ដោយជនដទៃអាចធ្វើការសន្មតយល់ដឹងពីការមានផ្ទៃពោះរបស់ជនរងគ្រោះនោះបាន។

ករណីទី២៖ ជនល្មើសប្រពឹត្តការកំហែងយកលើស្ត្រីដែលមានផ្ទៃពោះ ដោយជននោះបានដឹងច្បាស់អំពីការមានគភ៌របស់ជនរងគ្រោះ ទោះបីការមានគភ៌នោះ មិនបានស្តែងចេញមកក្រៅដោយជាក់លាក់ក៏ដោយ។ ដូច្នេះជននោះត្រូវបានច្បាប់កំណត់ចូលថាមានស្ថានទម្ងន់ទោស។

ឧទាហរណ៍៖ បុរស "ក" និង នារី "ខ" ដែលមានផ្ទៃពោះចំនួន៣ខែ ត្រូវជាបងប្អូនជីដូនមួយនឹងគ្នា។ ថ្ងៃមួយ ពួកគាត់មានវិវាទនឹងគ្នាពាក់ព័ន្ធនឹងរឿងដីធ្លី ដោយបុរស "ក" បានចាញ់ល្បែងអស់ពីខ្លួន ទើបបែកគំនិតចង់បានដីពីបងស្រីរបស់ខ្លួន។ ថ្ងៃមួយ បុរស "ក" ក៏បានជូន នារី "ខ" ទៅពិនិត្យផ្ទៃពោះ បន្ទាប់ពីត្រលប់មកផ្ទះវិញ បុរស "ក" ក៏បានសុំឲ្យនារីនោះប្រគល់ដីមកឲ្យខ្លួន តែត្រូវនាងបដិសេធ ក៏មានការឈ្លោះប្រកែកគ្នា។ បុរស "ក" ក៏បានគំរាមកំហែងថានឹងធ្វើឲ្យរលូតកូនក្នុងផ្ទៃ ប្រសិនបើមិនព្រមចុះហត្ថលេខាប្រគល់ដីនោះទេ។ ដោយសារការខ្លាចបាត់បង់កូននៅក្នុងផ្ទៃ គាត់ក៏ព្រមធ្វើតាម។ នៅក្នុងករណីនេះ តើបុរស "ក" ត្រូវជាប់ទោសពីបទល្មើសអ្វី?

ដំណោះស្រាយ ៖ បុរស "ក" បានគំរាមកំហែងទៅលើនារី "ខ" ដែលមានផ្ទៃពោះ ដោយចង់រំលូតកូននារី នោះប្រសិនបើមិនប្រគល់ដីអោយនោះទេ បន្ទាប់មកដោយការភ័យខ្លាចនារី "ខ" ក៏ព្រមបចុះហត្ថលេខាអោយ។ យោងទៅតាមមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌ អាចបញ្ជាក់ថាអំពើរបស់បុគ្គល "ក" ជាការកំហែងយក ដោយគាត់បានគំរាមកំហែងទៅលើនារីនោះថានឹងរំលូតកូនរបស់គាត់ចេញ ប្រសិនបើមិនប្រគល់ហត្ថលេខានោះទេ។ ដូច្នេះអំពើរបស់បុគ្គល "ក" គេចាត់ទុកថា ជាការ

គំរាមកំហែងនឹងប្រើហិង្សាចង់អោយនារីនោះប្រគល់ហត្ថលេខា ដែលជាបទល្មើសកំហែងយក។ លើសពីនេះទៀតបើយើងក្រលេកទៅមើល មាត្រា ៣៦៥ នៃក្រមព្រហ្មទណ្ឌ បញ្ញត្តិអំពីស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ នៅចំណុច ២ អាចបញ្ជាក់ថា បុគ្គល “ក” គាត់ត្រូវទទួលរងនៅស្ថានទម្ងន់ទោសបន្ថែម ពីព្រោះគាត់បានប្រព្រឹត្តការកំហែងយកទៅលើនារីមានគភ៌ ។ ទោះបីការមានគភ៌របស់នារី “ខ” ទើបតែរយៈពេល ៣ ខែ ដោយមិនអាចមើលដឹងជាទូទៅក៏ដោយ ប៉ុន្តែបុរស “ក” គាត់បានដឹងច្បាស់ណាស់ថានារីនោះមានផ្ទៃពោះ ដោយសារគាត់ជាអ្នកជូននារីនោះទៅពិនិត្យផ្ទៃពោះដោយផ្ទាល់ ។ ដូច្នេះ យើងអាចធ្វើការចោទប្រកាន់បុរស “ក” ពីបទល្មើសកំហែងយកដោយមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ។

### ២.១.៣ បុគ្គលទន់ខ្សោយពិសេស ដោយមូលហេតុជម្ងឺ ឬពិការភាព

ករណីមូលហេតុនៃជម្ងឺ សួរថាតើជម្ងឺដល់កម្រិតណាដែលធ្វើអោយគាត់ទន់ខ្សោយ? នៅក្នុងចំណុចនេះ គឺគេសំដៅទៅលើប្រភេទជម្ងឺដែលមាសភាពធ្ងន់ធ្ងរខ្លាំង ពុំរ៉ៃ បណ្តាលឲ្យជនរងគ្រោះបាត់បង់សមត្ថភាព និងលទ្ធភាពទប់ទល់អំពើដែលកើតមានឡើងមកលើខ្លួន។ ដើម្បីអនុវត្តស្ថានទម្ងន់ទោសទៅលើជនល្មើសបាន លុះត្រាតែជម្ងឺនោះមានសញ្ញាណបញ្ជាក់ជាក់ស្តែងចេញមកក្រៅ ឬក៏ជនល្មើសបានដឹងពីស្ថានភាពធ្ងន់ធ្ងរនៃជម្ងឺរបស់ជនរងគ្រោះ។ ប្រសិនបើជនល្មើសបានប្រព្រឹត្តអំពើកំហែងយក ដោយមិនបានដឹងពីសភាពជម្ងឺរបស់ជនរងគ្រោះនោះទេ យើងមិនអាចយកមាត្រា៣៦៥ ចំណុច៣ មកអនុវត្តនោះទេ។ មួយវិញទៀត យើងក៏មិនអាចអនុវត្តវិធាននេះផងដែរ ចំពោះជម្ងឺដែលមានលក្ខណៈស្រាល ដូចជា ជម្ងឺក្អក ឬផ្តាសាយជាដើម។

ឧទាហរណ៍៖ ធីតាមានជម្ងឺប្រចាំកាយ ធ្ងន់ធ្ងររហូតដល់សន្លប់ ដែលត្រូវនាំទៅមន្ទីរពេទ្យជាបន្ទាន់។ ពេលដល់មន្ទីរពេទ្យ បន្ទាប់ពីវេជ្ជបណ្ឌិតបានពិនិត្យរួច ធីតាក៏បានដឹងខ្លួនវិញ ប៉ុន្តែសភាពរបស់នាងពុំមានកម្លាំងពេញលេញនោះទេ ដែលធ្វើឲ្យនាងត្រូវសម្រាកនៅមន្ទីរពេទ្យមួយរយៈជាមួយអ្នកជម្ងឺដទៃទៀតក្នុងបន្ទប់តែមួយ។ ដល់ពេលមួយ លោកសុខ ដែលត្រូវជាសាច់ញាតិរបស់អ្នកជម្ងឺផ្សេងទៀត បានមកសួរសុខទុក ក៏បានប្រទះឃើញធីតាកំពុងកាន់ទូរស័ព្ទជាប់នឹងដៃ។ ភ្លាមៗនោះ

ឃើញឪកាសអំណោយផល ដោយសារធីតាមានសភាពទន់ខ្សោយ និង បរិយាកាសក្នុងបន្ទប់ស្ងប់ស្ងាត់ លោកក៏បានទៅខ្ទប់មាត់ធីតា ហើយឲ្យនាងហុច ទូរស័ព្ទមកឲ្យខ្លួន។ ដោយសារតែជម្ងឺរបស់នាងធ្វើឲ្យទន់ខ្សោយពេក ទើបនាង ប្រគល់ទូរស័ព្ទឲ្យតែម្តងទៅ។

ដំណោះស្រាយ ៖ ធីតាមានជម្ងឺធ្ងន់ធ្ងរ បានស្នាក់នៅមន្ទីរពេទ្យមួយរយៈជាមួយអ្នកជម្ងឺដទៃ ដែល ពេលនោះលោកសុខដែលទៅសួរសុខទុក្ខអ្នកជម្ងឺបន្ទប់ជាមួយ ក៏បានយកដៃខ្ទប់ មាត់ធីតាពេលដែលនាងកំពុងកាន់ទូរស័ព្ទជាមួយនឹងសភាពខ្សោយកម្លាំង មិន អាចតដៃបាន នាងក៏បានប្រគល់ទូរស័ព្ទមកឲ្យលោកសុខ។ យោងតាមមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ អំពើរបស់លោកសុខ គឺជាការកំហែងយក ដោយគាត់បានធ្វើការប្រើហិង្សាទៅលើធីតាដែលជាជនរងគ្រោះដើម្បីចង់បាន ទ្រព្យសម្បត្តិដែលជាទូរស័ព្ទនោះ។ម្យ៉ាងវិញទៀត យោងតាមសម្មតិកម្មខាងលើ អំពើរបស់លោកសុខក៏ត្រូវមានស្ថានទម្ងន់ទោសបន្ថែម ដែលមានចែងក្នុងមាត្រា ៣៦៥ ចំណុចទី៣ នៃច្បាប់ដដែលផងដែរ អំពើរបស់លោកសុខបានប្រើហិង្សា ដោយធ្វើការខ្ទប់មាត់ទៅលើនារីរងគ្រោះដែលគាត់កំពុងមានជម្ងឺធ្ងន់ធ្ងរ និងពុំ អាចធ្វើការតបតវិញបានដែលកំពុងសម្រាកនៅក្នុងមន្ទីរពេទ្យ។ ដូចនេះ លោក សុខត្រូវជាប់ពីបទកំហែងយកដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ។

ករណីពិការភាព គឺជាមនុស្សដែលទន់ខ្សោយពិសេស ដោយសារតែជនរងគ្រោះ គ្មានអវយវៈ ពេញលេញ ដែលហៅថា ពិការភាព។ រាល់ពិការភាពរបស់បុគ្គលរងគ្រោះ មិនមែនសុទ្ធតែចាត់ ចូលក្នុងស្ថានទម្ងន់ទោសនោះទេ វាទាមទារអោយមានការស្តែងនូវចំណុចនៃភាពទន់ខ្សោយ ពិសេសរបស់ជនរងគ្រោះផងដែរ។ តើពិការភាពកម្រិតណា ទើបគេចាត់ទុកថាជាប្រភេទទន់ខ្សោយ ពិសេស ដែលស្ថិតក្នុងស្ថានទម្ងន់ទោស?

ពិការភាពនេះត្រូវពិនិត្យមើល ទៅលើស្ថានភាពបុគ្គលនីមួយៗ ដោយសង្កត់ធ្ងន់ទៅលើ លទ្ធភាព និងសមត្ថភាពជាក់ស្តែងនៃការទប់ទល់ជាមួយនឹងបទល្មើសដែលកើតមានឡើង។ យើង អាចសិក្សាលើចំណុច២ធំៗ ៖

•ពិការភាព ជាមូលហេតុធ្វើអោយជនរងគ្រោះខ្សោយពិសេស៖ បុគ្គលដែលជាជនរងគ្រោះ អាចពិការអវយវៈ ណាមួយរបស់គាត់ ហើយភាពពិការនេះបណ្តាលអោយមានកង្វះខាតនូវកម្លាំងថាមពលដូចមនុស្សផ្សេងទៀត។ ភាពកង្វះខាតនេះហើយ ដែលគេសន្មតថាជាភាពទន់ខ្សោយពិសេស។

ឧទាហរណ៍៖ លោក សៅ ជាបុគ្គលិកក្រុមហ៊ុនឯកជន បានដាច់ដៃម្ខាង ដោយសារការធ្វេសប្រហែសរបស់លោក ធ្វើឲ្យដៃមួយកំណាត់ត្រូវបានចូលក្នុងម៉ាស៊ីន ។ ថ្ងៃមួយលោកសៅក៏បានដើរចេញពីកន្លែងធ្វើការរបស់លោក អំឡុងពាក់កណ្តាលអធ្រាត្រដែលគាត់កំពុងឈរតេទៅប្អូនរបស់លោកឲ្យមកទទួលនៅឯមុខក្រុមហ៊ុន។ ភ្លាមៗនោះស្រាប់តែមានក្រុមក្មេងទំនើង២នាក់ ឃើញលោកសៅ ឈរកាន់ទូរស័ព្ទម្នាក់ឯង ហើយឃើញលោកមានដៃតែម្ខាង និងសភាពមិនទាន់ជាសះស្បើយ ក៏បានគំរាមលោកសុខឲ្យហុចទូរស័ព្ទមកឲ្យខ្លួន តែគាត់មិនព្រម ស្រាប់តែក្មេងទំនើងទាំង២អ្នកនោះ បានវៃគាត់ឡើងទ្រោមខ្លួន ហើយធ្វើឲ្យដៃដែលពិការនោះហូរឈាមយ៉ាងខ្លាំង។ ដោយទ្រាំនឹងភាពឈឺចាប់មិនបាន លោកសៅក៏ប្រគល់ទូរស័ព្ទទៅឲ្យពួកគេ។ តើក្មេងទំនើងទាំង២អ្នកនោះ ត្រូវជាប់ស្ថានទម្ងន់ទោសនៃបទល្មើសកំហែងយកដែរឬទេ?

ដំណោះស្រាយ៖ លោកសៅជាជនពិការដៃម្ខាង ត្រូវបានក្មេងទំនើង២អ្នកធ្វើការកំហែងយក ទូរស័ព្ទរបស់លោក និងបានវៃទៅលើលោកសៅ ធ្វើឲ្យដៃម្ខាងដែលដាច់នោះហូរឈាមយ៉ាងខ្លាំង ដោយទ្រាំនឹងការឈឺចាប់មិនបាន លោកក៏បានប្រគល់ទូរស័ព្ទទៅឲ្យក្មេងទំនើងទាំង២អ្នកនោះ។ យោងតាមមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ អំពើរបស់ក្មេងទំនើងនោះត្រូវចាត់ចូលជាបទល្មើសកំហែងយក ព្រោះជនល្មើសបានធ្វើការកំហែងយក ដោយបានប្រើប្រាស់អំពើហិង្សាទៅលើលោកសៅ ដោយវៃទៅលើរូបគាត់ ដើម្បីឲ្យលោកប្រគល់ទូរស័ព្ទដែលកាន់នឹងដៃមកឲ្យខ្លួន។ ម្យ៉ាងវិញទៀត មាត្រា ៣៦៥ ចំណុចទី៣ ក៏បានដាក់ស្ថានទម្ងន់ទោសបន្ថែមផងដែរ ទៅលើករណីដែលបានប្រព្រឹត្តទៅលើជនរងគ្រោះដែលជាជនពិការ។ តាមសម្មតិកម្មខាងលើ យើងឃើញថា ក្មេងទំនើងទាំង២នាក់ បានប្រើហិង្សាទៅ

លើលោកសៅដែលជាជនពិការដៃម្ខាង ព្រមទាំងធ្វើឲ្យដៃពិការរបស់គាត់ហូរឈាមខ្លាំងទៀតផង។ ដូច្នេះ ក្មេងទំនើងទាំង២អ្នកនោះ ត្រូវជាប់ពីបទល្មើសកំហែងយកដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ។

• ពិការភាព មិនមែនជាមូលហេតុនៃការថមថយនូវលទ្ធភាពតបតះ ប្រសិនបើបុគ្គលនោះបាត់បង់អវយវៈ ដែលមិនមែនជាចំណុចសំខាន់នៃការទប់ទល់ហេតុការណ៍កើតមានឡើង វាមិនមែនជាភាពទន់ខ្សោយពិសេសនោះទេ។

ឧទាហរណ៍៖ ដាច់ស្លឹកត្រចៀក

មួយវិញទៀត ទោះក្នុងករណីគាត់ដាច់អវយវៈ ដែលជាមូលហេតុ ធ្វើអោយបុគ្គលនោះ មានភាពទន់ខ្សោយក៏ពិតមែន ប៉ុន្តែគាត់នៅតែមានសមត្ថភាពក្នុងការទប់ទល់លើសកម្មភាពដែលបានប្រព្រឹត្តនោះ ក៏គេមិនអាចចាត់ទុកជាជនទន់ខ្សោយពិសេសទេ។

ឧទាហរណ៍៖ អ្នកប្រដាល់

### ២.២ ស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ

យោងតាមមាត្រា ៣៦៦នៃក្រមព្រហ្មទណ្ឌ ជនដែលកំហែងយកដោយមានការប្រើប្រាស់អាវុធ ឬគំរាមកំហែងនឹងប្រើអាវុធ ត្រូវផ្តន្ទាទោស ពី ៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥(ដប់ប្រាំ)ឆ្នាំ[20]។ តាមនិយមន័យរបស់សម្តេចសង្ឃរាជជួនណាត ពាក្យថា អាវុធ មានន័យថា គ្រឿងប្រហារ ឬគ្រឿងចំបាំងផ្សេងៗ ដែលទីទៃពីស្ត្រា[21]។ឧទាហរណ៍ ធ្នូ ស្នា កាំភ្លើង ជាដើម។ ចំពោះក្រមព្រហ្មទណ្ឌវិញ បានបញ្ញត្តិពាក្យថា អាវុធ នៅមាត្រា ៨១ អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើអោយមានរបួស។ មួយវិញទៀត ក៏អាចសន្មតវត្ថុមួយចំនួនថាជាអាវុធផងដែរ ប្រសិនបើវត្ថុទាំងនោះបានប្រើប្រាស់សម្រាប់ ៖

-វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើអោយរបួស ឬគំរាមកំហែង។

-វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឲ្យមានរបួស ឬគំរាមកំហែង[22]។

**ចំណាំ ៖** ការប្រើប្រាស់អាវុធជាបទល្មើសមួយទៀត ចែងក្នុងច្បាប់ពិសេស (ច្បាប់ស្តីពី ការគ្រប់គ្រងអាវុធ )

[20] មាត្រា ៣៦៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[21] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត របស់វិទ្យាស្ថានសាសនបណ្ឌិត ឆ្នាំ២០០៩

[22] មាត្រា ៨១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ឧទាហរណ៍៖ លោក “ខ” ជានាយកក្រុមហ៊ុនឯកជនមួយ ដែលមានលោក “គ” ជានាយករង។ ថ្ងៃមួយ លោក “គ” មានគំនិតចង់បានក្រុមហ៊ុននោះ ដោយអោយលោក “ខ” ចុះហត្ថលេខាផ្ទេរតំណែងមកឲ្យខ្លួន។ ប៉ុន្តែ លោក “ខ” បានបដិសេធមិនព្រមផ្ទេរនោះទេ នៅពេលនោះ លោក “គ” បានទាញកាំភ្លើង យកមកភ្ជង់លោក “ខ” ដោយបង្ខំឲ្យចុះហត្ថលេខា។ បន្ទាប់មក ដោយតក់ស្លុតនឹងការគំរាម លោក “ខ” ក៏បានចុះហត្ថលេខាឲ្យ។ តើលោក “គ” ត្រូវជាប់ទោសពីបទល្មើសអ្វី?

ដំណោះស្រាយ៖ លោក “ខ” ត្រូវបានលោក “គ” ទាមទារឲ្យផ្ទេរតំណែងក្រុមហ៊ុនមកឲ្យខ្លួន ដោយបានប្រើប្រាស់កាំភ្លើងភ្ជង់លោក “ខ” និងបង្ខំឲ្យលោកចុះហត្ថលេខាឲ្យ។ យោងតាមមាត្រា ៣៦៣ អំពើរបស់លោក “គ” ត្រូវចាត់ចូលជាបទល្មើសកំហែងយក ដោយសារតែគាត់បានធ្វើការបង្ខំទៅលើលោក “ខ” ដើម្បីទាមទារឲ្យចុះហត្ថលេខា។ លើសពីនេះទៀត បើយើងមើលទៅលើមាត្រា ៣៦៦ គាត់ត្រូវទទួលស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ ពីព្រោះតែគាត់បានប្រព្រឹត្តអំពើកំហែងយកដោយបានយកកាំភ្លើងមកធ្វើការគំរាមកំហែងបុគ្គលម្នាក់ទៀត។ ដូចនេះ លោក “គ” ត្រូវជាប់ទោសពីបទល្មើសកំហែងយកមានស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ។

### ២.៣ ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវ ឬពិការភាព

អំពើកំហែងយកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ប្រសិនបើអំពើនេះត្រូវបានប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយប្រើហិង្សាដែលនាំឲ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍[23]។ ចំពោះនិយមន័យ អវយវៈវិញ គឺគេសំដៅតាមន័យក្នុងវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត គឺបានប្រើនៅក្នុងន័យទូលាយ ឬន័យទូទៅដែលប្រើច្រើនបំផុតនោះគឺសំដៅលើសរីរាង្គកាយយើងទាំងមូល ស្បែក ត្រចៀក ច្រមុះ ភ្នែក មាត់ និងកន្លែងណាក៏ជាអវយៈដែរ។ ដូច្នេះប្រសិនការកំហែងនោះមានការកាត់អវយវៈ ឬសរីរាង្គណាមួយរបស់ជនរងគ្រោះ អំពើនោះត្រូវចាត់ទុកថាមានស្ថានទម្ងន់ទោស។

[23] មាត្រា ៣៦៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

មួយវិញទៀត ប្រសិនបើការកំហែងយកបណ្តាលអោយពិការភាពអចិន្ត្រៃយ៍ ក៏មានស្ថានទម្ងន់ទោសផងដែរ។ ពាក្យថាពិការភាពអចិន្ត្រៃយ៍ សំដៅលើ ភាពពិការរហូតដោយមិនអាចព្យាបាល ឬដូចសភាពដើមវិញបាន។ ប្រសិនបើភាពពិការក្នុងរយៈពេលមួយរយៈដែលអាចព្យាបាលបានដូចដើមនោះ មិនចាត់ទុកជាស្ថានទម្ងន់ពិការភាពអចិន្ត្រៃយ៍នោះទេ។ សកម្មភាពដែលធ្វើអោយពិការ វាអាចបណ្តាលមកពីការផ្តាច់អវយវៈ ឬការប្រព្រឹត្តអំពើហិង្សាធ្ងន់ធ្ងរប៉ះពាល់ដល់សរីរាង្គកាយរបស់ជនរងគ្រោះ ផ្តល់ជាហេតុមិនអាចដំណើរបានទៀត។

ឧទាហរណ៍៖ ក្រុមចោរមួយក្រុម ប្រដាប់ដោយដាវស៊ាំម៉ារៃ បានចូលទៅផ្ទះលោក “ក” អំឡុងម៉ោង ១២អាធ្រាត្រ។ នៅពេលដែលក្រុមចោរនោះចូលទៅដល់ លោក “ក” ក៏បានធ្វើការប្រតាយប្រតប់គ្នាជាមួយចោរ តែត្រូវចោរនោះវៃឡើងទ្រោមខ្លួនទៅវិញ ហើយចោរនោះក៏បានប្រាប់អោយលោក “ក”ប្រគល់ប្រាក់ដែលមានក្នុងទូរដែករបស់លោកទាំងអស់មកឲ្យរូបគេ។ ពេលនោះ លោក “ក” បានបដិសេធ ហើយក៏បានស្រែកអោយអ្នកជិតខាងជួយ ភ្លាមៗនោះ ក្រុមចោរមានការស្លន់ស្លោខ្លាចមានអ្នកលឺ ក៏បានយកដាវស៊ាំម៉ារៃនោះ កាប់ចំជើងរបស់ លោក “ក” បណ្តាលដាច់ជើងស្តាំម្ខាងត្រឹមជង្គង់ នឹងបានគំរាមទៀតថា បើនៅតែស្រែកគេនឹងកាត់ជើងម្ខាងទៀត។ ដោយភ័យពេក លោក “ក” ក៏បានសម្រេចចិត្ត ប្រគល់ទ្រព្យសម្បត្តិដែលមាននៅក្នុងទូរដែកទាំងអស់ទៅឲ្យពួកគេ។

ដំណោះស្រាយ៖ លោក “ក” ត្រូវបានចោរមួយក្រុមចូលទៅផ្ទះរបស់ខ្លួនដើម្បីមកយកទ្រព្យសម្បត្តិដែលមាននៅក្នុងទូរដែក ក្រោយមកលោក “ក” ក៏បានស្រែកអោយគេជួយ តែត្រូវចោរប្រដាប់ដោយស៊ាំម៉ារៃ កាប់ដាច់ជើងស្តាំត្រឹមជង្គង់រួចគំរាមកុំឲ្យស្រែកទៀត ហើយលោក “ក”ភ័យពេកក៏ប្រគល់ទ្រព្យសម្បត្តិដែលមានក្នុងទូរដែកទាំងអស់។ យោងតាមមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានបញ្ញត្តិយ៉ាងជាក់លាក់ អំពើរបស់ក្រុមចោរទាំងនោះជា ការកំហែងយក ដោយបានប្រើប្រាស់ហិង្សាទៅលើលោក “ក” ទៀតផង ដើម្បីឲ្យលោក “ក” ប្រគល់ទ្រព្យសម្បត្តិដែលមាននៅក្នុងទូរដែកទាំងអស់មកឲ្យខ្លួន។ មួយវិញទៀត ក្រុមចោរនោះបានកាប់ដាច់ជើងស្តាំម្ខាង ដែលច្បាប់បានបញ្ញត្តិបន្ថែមស្ថានទម្ងន់ទោសទៅលើជន

ល្មើសដែលបានកាត់អវយវៈជនរងគ្រោះ នៅក្នុងមាត្រា ៣៦៧ នៃច្បាប់ដដែល ។ ដូចនេះ ក្រុមចោរនោះ ត្រូវជាប់ពីបទកំហែងយកដែលមានស្ថានទម្ងន់ទោស ដោយសារការកាត់អវយវៈ ឬពិការភាព។

### ២.៤ ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើទារុណកម្ម ឬអំពើឃោរឃៅ[24]។

ការធ្វើទារុណកម្ម ឬអំពើឃោរឃៅ សំដៅលើការប្រព្រឹត្តអំពើ បំពានលើរូបរាងកាយបុគ្គលដ៏ទៃទៀតដោយចេតនា រួមទាំងប្រើប្រាស់វិធីសាស្ត្រគ្រប់បែបយ៉ាង ដើម្បីបង្កើតការឈឺចាប់។ អំពើនេះ ប្រព្រឹត្តច្រំដែល ម្តងហើយម្តងទៀត និងមានលក្ខណៈ អមនុស្សធម៌ កាចសាហាវ ធ្វើឲ្យមនុស្សបាត់បង់តម្លៃមនុស្សជាតិ។

ឧទាហរណ៍៖ មីងកុលាប ជាម្ចាស់អាជីវកម្មផ្ទេរប្រាក់ និងប្តូរប្រាក់តាមផ្ទះ។ នាពេលយប់មួយគាត់នៅផ្ទះម្នាក់ឯង ស្រាប់តែមានបុគ្គល២នាក់ បានដើរចូលមកផ្ទះរបស់គាត់ ហើយបានយកខ្សែមកចាប់គាត់ចងព័ទ្ធដៃទៅក្រោយ និងបង្ខំឲ្យគាត់ប្រាប់លេខសម្ងាត់ទូរលុយរបស់គាត់។ ភ្លាមៗនោះគាត់បានបដិសេធ ស្រាប់តែជននោះយកកាំបិតមកចាក់ចំដៃរបស់គាត់ទាំងសងខាង ហើយបង្ខំប្រាប់លេខសម្ងាត់នោះ។ ប៉ុន្តែគាត់នៅតែមិនប្រាប់ ជននោះក៏បានយកកាំបិតអារដៃគាត់ជាច្រើនជំរៀក ដោយទ្រាំនឹងការឈឺចាប់ពុំបាន គាត់ក៏បានប្រាប់លេខសម្ងាត់នោះទៅ។

តើករណីនេះ ត្រូវចាត់ទុកជាបទល្មើសអ្វី?

ដំណោះស្រាយ៖ មីងកុលាប ត្រូវបានជន២នាក់បង្ខំឲ្យប្រាប់លេខសម្ងាត់ទូរលុយរបស់គាត់ ដោយបានយកកាំបិតមកចាក់ចំដៃទាំងសងខាង។ ក្រោយមកទៀតមីងកុលាបនៅតែមិនប្រាប់លេខសម្ងាត់នោះទៀតធ្វើឲ្យជននោះ យកកាំបិតអារដៃបន្ថែមជាច្រើនជំរៀកទៀត ទើបគាត់ព្រមប្រាប់លេខសម្ងាត់នោះ។ យោងតាមមាត្រា ៣៦៣ អំពើខាងលើ ជាបទល្មើសកំហែងយក ព្រោះថាជនទាំង២ បានប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះ ដោយទាមទារឲ្យគាត់ប្រាប់លេខសម្ងាត់ទូរប្រាក់របស់

[24] មាត្រា ៣៦៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

គាត់ ដែលគេចាត់ទុកជាការបង្ហាញអាថ៌កំបាំង។ មួយវិញទៀត ជនទាំង២បាន ប្រព្រឹត្តទារុណកម្មទៅលើមីងកុលាប ដោយបានយកកាំបិតមកចាក់លើរូបកាយ និងបានអារដៃគាត់ជាច្រើនដងថែមទៀត ដែលជាហេតុ ធ្វើឲ្យជនរងគ្រោះមាន ការឈឺចាប់លើរូបរាងកាយជាខ្លាំង បើយោងតាមមាត្រា ៣៦៨ បញ្ជាក់បានថា អំពើជនទាំង២នេះ ចាត់ចូលមានស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម។ ដូចនេះ ជនទាំង២នាក់ ត្រូវជាប់បទល្មើសកំហែងយកដែលមានស្ថានទម្ងន់ទោស ដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ។

**ចំណាំ៖** អំពើទារុណកម្ម និងអំពើឃោរឃៅ ធ្វើបាបចំពោះរូបរាងកាយ មិនសំដៅទៅលើការធ្វើបាប ផ្នែកស្មារតីនោះទេ។

**២.៥ ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ**

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ដែលបណ្តាលឲ្យជន រងគ្រោះស្លាប់ដោយគ្មានចេតនា[25]។

មរណៈភាពនៃជនរងគ្រោះ ត្រូវកើតឡើងដោយអំពើគ្មានចេតនាសម្លាប់ជនរងគ្រោះ មាន ន័យថា ការស្លាប់នោះជាអំពើក្រៅចេតនារបស់ជនល្មើស។ ដើម្បីដឹងអំពីចេតនា ឬគ្មានចេតនា យើងអាចសិក្សាទៅលើ រូបរាងនៃអំពើ របៀបនៃការប្រព្រឹត្ត ឧបករណ៍ មធ្យោបាយ និង ស្លាកស្នាមរបួស។ ការកំហែងយកដែលបណ្តាលឲ្យជនរងគ្រោះស្លាប់ មានគោលដៅតែមួយគត់ គឺ ចង់ឲ្យជនរងគ្រោះប្រគល់វត្ថុដូចដែលមានចែងនៅក្នុងមាត្រា ៣៦៣ ដោយគ្មានគោលបំណង សម្លាប់ជនរងគ្រោះនោះទេ។

**ចំណាំ៖** អំពើក្រៅចេតនា គឺជាអំពើដែលមិនមានគោលបំណងអោយកើតមាន ឬសំរេច។

ឧទាហរណ៍៖ នារីម្នាក់ កំពុងដើរតែម្នាក់ឯងកន្លែងស្ងាត់មួយ ។ ស្រាប់តែមានជនម្នាក់បាន ឃើញនារីនោះកំពុងកាន់កាបូបលុយ ក៏បានចូលវៃនាង ដើម្បីអោយ ប្រគល់ លុយមកឲ្យខ្លួន។ ដោយមានការភិតភ័យពេក នារីនោះក៏បានប្រគល់កាបូប ទៅ ឲ្យជនល្មើស រួចជននោះក៏បានច្រាននាងផ្ទប់ទៅនឹងទ្វាររបងដែក ដែលទ្វារនោះ

[25] មាត្រា ៣៦៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

នៅគៀកនឹងបង្គោលភ្លើង។ ស្រាប់តែពេលនោះ ចរន្តអគ្គិសនីឆ្លងប៉ះទៅនឹងទ្វាររបងនោះ ក៏បានឆក់នារីស្លាប់។ តើករណីនេះ ចាត់ទុកជាបទល្មើសអ្វី? យោងតាមមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ អំពើខាងលើ គឺជាការកំហែងយក ដោយសារតែជនល្មើសនោះបានធ្វើការកំហែងយកដោយបានប្រើហិង្សាទៅលើនារីរងគ្រោះ ក្នុងគោលបំណងឲ្យនារីនោះប្រគល់លុយដែលមានក្នុងកាបូបមកឲ្យខ្លួន។ លើសពីនេះទៅទៀត ក្នុងករណីខាងលើ បណ្តាលឲ្យនារីនោះបានបាត់បង់ជីវិត ប៉ុន្តែគេមិនចាត់ទុកជាបទល្មើសឃាតកម្មនោះទេ ដោយសារតែការស្លាប់នោះ ជនល្មើសគ្មានចេតនាសម្លាប់ទេ គឺគ្រាន់តែច្រាននាងចេញប៉ុណ្ណោះ ដោយជនល្មើសពុំបានដឹងថាទ្វាររបងនោះឆ្លងនឹងចរន្តអគ្គិសនីនោះឡើយដែលអាចធ្វើឲ្យនារីរងគ្រោះឆក់ស្លាប់។ដូច្នេះ អំពើនេះ គឺជា ការកំហែងយកដែលមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ។ ផ្ទុយទៅវិញ បើគាត់បានដឹងថាទ្វាររបងនោះឆក់ហើយ គាត់នៅតែរុញនារីនោះឲ្យឆក់ស្លាប់ ទើបយើងចាត់ទុកថាជា អំពើឃាតកម្ម ដោយសារតែមានចេតនាក្នុងការប្រព្រឹត្ត។

# ជំពូកទី៣

# ការប្រៀបធៀបបទល្មើសទាំងពីរ

## កថាខណ្ឌទី១ ភាពដូចគ្នា និងខុសគ្នា

ឆ្លងតាមការបកស្រាយនៃបទល្មើសទាំងពីរខាងលើ ដែលមានពីរជំពូក គឺជំពូកទី១ បទល្មើសលួច និងជំពូកទី២ ការកំហែងយក រួចមកហើយ យើងឃើញថា បទល្មើសទាំងពីរនេះ បានលេចចេញនូវចំណុចជាច្រើនដែលមានលក្ខណៈស្រដៀងគ្នាដែលអាចយកមកធ្វើការប្រៀបធៀបបាន។ បើធ្វើការវិភាគឲ្យបានស៊ីជម្រៅចំពោះបទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក យើងធ្វើការបែងចែកការប្រៀបធៀបជាពីរចំណុចធំៗ គឺ ទី១ យើងនឹងធ្វើការបកស្រាយចំណុចដូចនៃបទល្មើស និងទី២ ចំណុចខុសគ្នានៃបទល្មើស។

### ១. ចំណុចដូចគ្នា

ភាពដូចនៃបទល្មើសទាំងពីរ បើយើងសិក្សាឲ្យបានច្បាស់លាស់ ឃើញថាលក្ខណៈដូចគ្នាត្រូវបានញែកជា ៥ ចំណុចសំខាន់ៗដូចខាងក្រោមៈ

#### ១.១ នីត្យានុកូលភាពនៃបទល្មើស

នីត្យានុកូលភាពនៃបទល្មើស សំដៅលើការមានចែងនៅក្នុងបទបញ្ញត្តិព្រហ្មទណ្ឌនូវអំពើដែលបង្កើតជាបទល្មើស។ដូច្នេះហើយ ការបកស្រាយចំណុចនេះ យើងត្រូវមើលក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដោយផ្តោតសំខាន់ទៅលើការសិក្សាអំពី ទីតាំងនៃការចែងនៃបទល្មើសទាំងពីរនៅក្នុងក្រម។ នៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន ការរៀបចំរចនាសម្ព័ន្ធគឺរៀបចំតាមលំដាប់លំដោយដែលមានចែកជា គន្ថី មាតិកា ជំពូក និងផ្នែក។

បទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក គឺស្ថិតនៅក្នុងចំណុចមួយចំនួននៃរចនាសម្ព័ន្ធរបស់ក្រមដូចគ្នា។ យើងនឹងធ្វើការបែងចែកជា៣ចំណុចដូចខាងក្រោមៈ

##### ១.១.១ ការចែងនៅក្នុងគន្ថី

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ត្រូវបានបែងចែកជា៦គន្ថី ដោយគិតចាប់ពីគន្ថីទី១ បញ្ញត្តិទូទៅ រហូតដល់គន្ថីទី៦ អវសានប្បញ្ញត្តិ។ ប៉ុន្តែ គ្រប់គន្ថីទាំងអស់មិនមែនសុទ្ធតែលើកឡើងពីបទល្មើសទាំងអស់នោះទេ មានតែបីគន្ថីប៉ុណ្ណោះកំណត់ពីបទល្មើសគឺ គន្ថីទី២ បទល្មើសប្រឆាំងនឹងបុគ្គល គន្ថីទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងគន្ថីទី៤ បទល្មើសប្រឆាំងនឹងមនុស្សជាតិ។

ចំពោះ បទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក គឺមានចែងនៅក្នុងគន្ថីទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិដូចគ្នា។ មូលហេតុដែលបទល្មើសទាំងពីរចែងនៅក្នុងគន្ថីតែមួយ ដោយសារតែ អំពើធ្វើឡើងក្នុងគោលបំណងប៉ះពាល់ទៅដល់កម្មសិទ្ធិ ឬទ្រព្យសម្បត្តិរបស់អ្នកដទៃ។

**១.១.២ ការចែងនៅក្នុងមាតិកា**

នៅក្នុងគន្ថីនីមួយៗគឺត្រូវបែងចែកចេញជាមាតិកា មាតិកាគឺជាចំណុចមួយនៅលំដាប់បន្ទាប់ពីគន្ថី ដោយមានការកំណត់ជាមាតិកាច្រើន ឬតិច នៅក្នុងគន្ថីមួយអាស្រ័យទៅតាមវិសាលភាពរបស់វា។ យើងមើលឃើញថា បទល្មើសទាំងពីរស្ថិតនៅក្នុងមាតិកាទី១ ដូចគ្នាដែលកំណត់អំពី "ការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត" ។

**១.១.៣ ការចែងនៅក្នុងជំពូក**

ជំពូកជាចំណុចមួយដែលស្ថិតនៅលំដាប់បន្ទាប់ពីមាតិកា ហើយនៅក្នុងមាតិកាទី១នៃគន្ថីទី៣ មានការបែងចែកជាច្រើនជំពូកផងដែរ។ នៅក្នុងមាតិកាទី១ មានការបែងចែកជា ៤ ជំពូក ហើយនៅក្នុងជំពូក ដែលនិយាយអំពី ការលួច និងបទល្មើសប្រហាក់ប្រហែល យើងឃើញមានកំណត់អំពីបទល្មើសលួចដោយប្រើហិង្សា និងការកំហែង គឺស្ថិតនៅក្នុងជំពូកទី១ជាមួយគ្នា។

**១.២ ប្រធាននៃបទល្មើស**

ចំពោះបុគ្គលដែលជាប្រធាននៃបទល្មើសត្រូវបានបែងចែកជាពីរប្រភេទគឺ រូបវន្តបុគ្គល និងនីតិបុគ្គលដោយយោងទៅតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានធ្វើការកំណត់ឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះនីតិបុគ្គល ដែលជាសញ្ញាណថ្មីដែលពីមុនមកពុំមានកំណត់នៅក្នុងច្បាប់ចាស់ឡើយ។

ចំពោះប្រធាននៃបទល្មើស នៅក្នុងបទល្មើសលួចដោយប្រើហិង្សា និងការកំហែងយកគឺមានតែរូបវន្តបុគ្គលតែប៉ុណ្ណោះដែលទទួលខុសត្រូវពុំមាននីតិបុគ្គលនោះទេ។ រូបវន្តបុគ្គលដែលជាប្រធាននៃបទល្មើស យើងធ្វើការបកស្រាយទៅលើជនល្មើស និងជនរងគ្រោះ។

**១.២.១ ជនល្មើស**

ជនល្មើស ឬចារី បើយោងទៅតាមក្រមព្រហ្មទណ្ឌ មាត្រា២៥ បានកំណត់និយមន័យថាជាបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់ ឬជាបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម។ ចារីជាបុគ្គលតែម្នាក់ ដែលប្រព្រឹត្តបទល្មើស ប៉ុន្តែប្រសិនបើមានបុគ្គលច្រើនអ្នកចូលរួម យើងហៅថាសហចារី។ ពេលខ្លះការចូលរួមប្រព្រឹត្តបទល្មើសអាចមានទាំងអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតផងដែរ។

### ១.២.២ ជនរងគ្រោះ

យើងសូមលើកយកអត្ថន័យនៃជនរងគ្រោះមកបង្ហាញ មុននឹងឈានដល់ការបកស្រាយផ្សេងទៀតពាក់ព័ន្ធនឹងបទល្មើសកំហែងយក និងលួចដោយប្រើប្រាស់ហិង្សា។

**ជនរងគ្រោះមានន័យថា៖**

តាមន័យក្រមព្រហ្មទណ្ឌ ជនទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ។

តាមន័យទូទៅ ជនទទួលរងការឈឺចាប់ដោយអំពើខុសច្បាប់ដែលនាំឲ្យខូចសេចក្តីថ្លៃថ្នូរ កិត្តិយស បញ្ញាស្មារតី រូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន។

ប៉ុន្តែនៅក្នុងការបកស្រាយចំណុចនេះ យើងត្រូវពិនិត្យទៅលើអត្ថន័យតាមក្រមព្រហ្មទណ្ឌ។ នៅក្នុងបទល្មើសទាំងពីរខាងលើនេះ យើងត្រូវធ្វើការពិនិត្យលើលក្ខខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះនេះ ពីព្រោះលក្ខខណ្ឌនេះអាចជួយឲ្យយើងធ្វើការកំណត់នូវអាទិភាពនៃបទល្មើសទាំងពីរនេះបានដែលលក្ខខណ្ឌទាំងនោះមានដូចខាងក្រោម ៖

-ត្រូវមានអត្ថិភាពនៃជនរងគ្រោះ គឺត្រូវរកឲ្យឃើញថាមានជនរងគ្រោះពិតប្រាកដ

-ជនរងគ្រោះ គឺជាអ្នកដទៃដែលផ្សេង ឬក្រៅពីជនល្មើស ទោះបីជាសាច់ញាតិក៏ដោយ មានន័យថាជនរងគ្រោះមិនអាចជាជនល្មើសនោះទេ

-ជនរងគ្រោះត្រូវតែមានជីវិតនៅពេលមានបទល្មើសកើតឡើង ។

### ១.៣ លក្ខណៈនៃអំពើ

បទល្មើសទាំងពីរមានលក្ខណៈដូចគ្នា ដោយសារតែវាជាប្រភេទ អំពើសកម្ម។ អំពើសកម្ម គឺសំដៅទៅលើសកម្មភាព កាយវិការរបស់ចារីជាក់ស្តែងដែលអ្នកណាក៏បានឃើញថាចារីបានប្រព្រឹត្តអំពើនោះដែរ។

### ១.៤ មធ្យោបាយប្រព្រឹត្តបទល្មើស

អំពើលួចដោយប្រើហិង្សា និងការកំហែងយក ប្រព្រឹត្តឡើងដោយមានការប្រើហិង្សាដូចគ្នា។ ការប្រើហិង្សានោះ ធ្វើឡើងទៅលើជនរងគ្រោះ ឬសាច់ញាតិ ប៉ះពាល់ទៅដល់បូរណភាពរូបរាងកាយ ឬផ្លូវចិត្ត។

### ១.៥ បច្ច័យនៃបទល្មើស

បច្ច័យ គឺសំដៅទៅលើផលដែលកើតចេញពីបទល្មើស។ បើយើងមើលទៅលើបទល្មើសទាំង២ បច្ច័យរបស់វាមានលក្ខណៈដូចគ្នាដោយចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់

ខ្លួន និងអាចមានគោលបំណងបន្ថែមផ្សេងទៀត ដើម្បីសម្រេចគោលដៅចុងក្រោយ គោលបំណងនោះគឺសំដៅទៅលើបំពានលើរូបរាងកាយតាមរយៈការប្រើហិង្សាទៅលើម្ចាស់ទ្រព្យ ឬអ្នកគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិនោះ។

**២. ចំណុចខុសគ្នា**

បន្ទាប់ពីបានពិនិត្យដោយយកចិត្តទុកដាក់ លើការរៀបរាប់នូវបទល្មើសទាំងពីររួចមក យើងអាចលើកយកចំណុចខុសគ្នាមួយចំនួនមកធ្វើការបកស្រាយដោយបង្ហាញនូវចំណុចធំៗមួយចំនួនដូចជា៖ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

**២.១ ធាតុនីត្យានុកូល**

នៅក្នុងធាតុនេះ ជាមូលដ្ឋានយើងផ្អែកទៅលើការចែងអំពីបទល្មើសនីមួយៗនៅក្នុងច្បាប់ជាធរមាន។ ដូច្នេះហើយ រវាងបទល្មើសទាំងពីរមានលក្ខណៈខុសគ្នាត្រង់ចំណុចដូចខាងក្រោម៖

**២.១.១ នីត្យានុកូលភាពនៃបទល្មើស**

នីត្យានុកូលភាពនៃបទល្មើស គឺសំដៅលើអំពើបង្កើតជាបទល្មើស ហើយត្រូវបានផ្តន្ទាទោសនៅពេលដែលអំពើនោះ មានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន។ បើយើងមើលទៅលើភាពខុសគ្នានៃនិយមន័យដែលមានចែងនៅក្នុងច្បាប់គឺ៖

**លួចដោយប្រើហិង្សា** ជាការដកហូតទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងៗទៀតរបស់អ្នកដទៃ ដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយប្រើប្រាស់ដូចជា៖

-អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា។

-អំពើលួចនេះ ប្រព្រឹត្តដោយមានការកាប់គាស់ទម្លុះទម្លាយ។

បទល្មើសនេះមានចែងច្បាស់លាស់នៅក្នុងមាត្រា ៣៥៧ ក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

**ការកំហែងយក** ជាអំពើដែលប្រព្រឹត្តដោយការប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬដោយការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ ៖

១.ហត្ថលេខា ឬស្នាមម្រាមដៃ

២.ការសន្យា ឬការបោះបង់ចោលអ្វីមួយ

៣.ការបង្ហាញអាថិកំបាំងណាមួយ

៤.ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

ការកំហែងយកនេះមានចែងច្បាស់លាស់នៅក្នុងមាត្រា ៣៦៣ ក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

**២.១.២ និត្យានុកូលភាពនៃទោស**

ចំណុចនេះ យើងធ្វើការពិនិត្យទៅលើការបកស្រាយទៅលើទោសដែលត្រូវអនុវត្ត យើងសង្កេតឃើញថាបទលួចដោយប្រើហិង្សា និងការកំហែងយកមានភាពខុសគ្នាចំពោះទោសដែលត្រូវអនុវត្ត។

**លួចដោយប្រើហិង្សា** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) និងគ្មានការពិន័យជាប្រាក់ទេ។

**ការកំហែងយក** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

**២.១.៣ ប្រភេទនៃបទល្មើស**

នៅក្នុងក្រមព្រហ្មទណ្ឌ បទល្មើសត្រូវចាត់ជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ។ ចំពោះបទល្មើសទាំងពីរ គឺមិនស្ថិតនៅក្នុងប្រភេទតែមួយនោះទេ។

**លួចដោយប្រើហិង្សា** មានចរិកគ្រោះថ្នាក់ធ្ងន់ធ្ងរដែលចាត់ចូលជាប្រភេទបទឧក្រិដ្ឋ (យោងតាមមាត្រា៤៦) ។ បទល្មើសនេះ ការប៉ុនប៉ង ផ្អែកតាមមាត្រា ២៧ គឺមានន័យថា បទល្មើសនេះជាបទឧក្រិដ្ឋ ដូច្នេះការប៉ុនប៉ងត្រូវតែមានគ្រប់ករណី។

**ការកំហែងយក** មានលក្ខណៈស្រាលជាងទៅនឹងបទល្មើសលួចដោយហិង្សា ហើយគេចាត់ចូលវាជាប្រភេទនៃបទមជ្ឈិម (យោងតាមមាត្រា ៤៧) ។ បទល្មើសនេះ ការប៉ុនប៉ង ផ្អែកតាមមាត្រា ៣៧០ ជាប៉ុនប៉ងក្នុងបទល្មើសមជ្ឈិម។

**២.១.៤ អាជ្ញាយុកាល**

អាជ្ញាយុកាលនៅក្នុងរឿងព្រហ្មទណ្ឌត្រូវបានបែងចែកជាពីរប្រភេទគឺ អាជ្ញាយុកាលនៃទោស និងអាជ្ញាយុកាលនៃបទល្មើស។

**២.១.៤.១ អាជ្ញាយុកាលនៃទោស**

អាជ្ញាយុកាលនៃទោស មានន័យថា ជារយៈពេលដែលកំណត់អំពីអត្ថិភាពនៃទោសដែលអាចយកទៅអនុវត្តបានចំពោះទណ្ឌិតដែលត្រូវបានប្រកាសដោយតុលាការ។ ចិរវេលានៃអាជ្ញាយុកាលនេះត្រូវបានកំណត់ដូចខាងក្រោម៖

-ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ

-ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ

-ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ

បើយើងធ្វើការប្រៀបធៀបអាជ្ញាយុកាលនៃទោសរបស់បទល្មើសទាំងពីរ យើងឃើញថាវាមានលក្ខណៈខុសគ្នាដូចជា៖

**លួចដោយប្រើហិង្សា** ត្រូវចាត់ចូលជាបទឧក្រិដ្ឋ (យោងតាមមាត្រា ៤៦) ដូច្នេះអាជ្ញាយុកាលនៃទោសរបស់វាមានថេរវេលា ២០ (ម្ភៃ) ឆ្នាំ។

**ការកំហែងយក** ត្រូវចាត់ចូលជាបទមជ្ឈិម (យោងតាមមាត្រា ៤៧) ដូច្នេះអាជ្ញាយុកាលនៃទោសរបស់វាមានថេរវេលា ៥ (ប្រាំ) ឆ្នាំ។

**២.១.៤.២ អាជ្ញាយុកាលនៃបទល្មើស**

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលដែលកំណត់អំពីអត្ថិភាពនៃបទល្មើស ដែលបានកើតឡើង ហើយរយៈពេលអាចឲ្យអ្នកដែលមានសិទ្ធិ អាចធ្វើការប្តឹងអំពីបទល្មើសណាមួយចំពោះបុគ្គលដែលខ្លួនចង់ប្តឹងបន្ទាប់ពីបទល្មើសកើតឡើង។ ថិរវេលានៃអាជ្ញាយុកាលនៃបទល្មើស មានដូចតទៅ៖

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ

ដូច្នេះ បទល្មើសទាំងពីរមានលក្ខណៈខុសគ្នាត្រង់អាជ្ញាយុកាលនៃបទល្មើស៖

**លួចដោយប្រើហិង្សា** ត្រូវចាត់ចូលជាបទឧក្រិដ្ឋ (យោងតាមមាត្រា ៤៦) ដូច្នេះអាជ្ញាយុកាលនៃបទល្មើសរបស់វាមានថេរវេលា ១៥ (ដប់ប្រាំ) ឆ្នាំ។

**ការកំហែងយក** ត្រូវចាត់ចូលជាបទមជ្ឈិម (យោងតាមមាត្រា ៤៦) ដូច្នេះអាជ្ញាយុកាលនៃបទល្មើសរបស់វាមានថេរវេលា ៥ (ប្រាំ) ឆ្នាំ។

**២.២ ធាតុសត្យានុម័ត**

ធាតុសត្យានុម័ត (ធាតុសម្ភារៈ) សំដៅទៅលើ សកម្មភាពដែលកើតចេញរួចធ្វើឲ្យគេអាចសង្កេតឃើញជាសម្ភារៈខាងក្រៅ។

**២.២.១ រូបរាងនៃអំពើ**

រូបរាងនៃអំពើ សំដៅទៅលើសកម្មភាពណាមួយរបស់ជនល្មើសដែលបានប្រព្រឹត្តទៅលើជន

រងគ្រោះ។ ចំណុចនេះ យើងនឹងធ្វើការបកស្រាយទៅលើ ចំណុចខុសៗគ្នារវាងបទល្មើសទាំងពីរ ដែលរួមមាន៖ រូបភាពស្តែងឡើងតាមការដកហូតដោយទុច្ចរិត ការប្រគល់ និងមធ្យោបាយប្រព្រឹត្តបទល្មើស។

**លួចដោយប្រើហិង្សា** រូបរាងនៃអំពើគឺមានលក្ខណៈជាការដកហូតដោយទុច្ចរិតទៅលើទ្រព្យសម្បត្តិរបស់អ្នកដទៃយកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ចំពោះមធ្យោបាយប្រព្រឹត្តបទល្មើសវិញ គឺមានការប្រើប្រាស់ហិង្សា ឬ ពេលខ្លះមានការកាប់គាស់ទម្លុះទម្លាយ។

**ការកំហែងយក** វាមានលក្ខណៈផ្ទុយទៅនឹងលួចដោយហិង្សា ព្រោះវាពុំមានលក្ខណៈជាការដកហូតនោះទេ តែវាមានលក្ខណៈជាការព្រមព្រៀងប្រគល់ពីជនរងគ្រោះដោយឆន្ទៈមិនពិតប្រាកដ និងមិនសេរី។រីឯមធ្យោបាយប្រព្រឹត្តបទល្មើសវិញ គឺខុសពីបទល្មើសលួចដោយហិង្សានោះត្រង់ថា ការកំហែងយក អាចជាការគំរាមថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំ ម្យ៉ាងវិញទៀតបទល្មើសនេះ ពុំមានការកាប់គាស់ទម្លុះទម្លាយនោះទេ។

**២.២.២ លក្ខណៈនៃអំពើ**

ទោះបីជាបទល្មើសទាំងពីរ មានលក្ខណៈជាអំពើសកម្មដូចគ្នាក៏ដោយ ប៉ុន្តែវាមានចំណុចខុសគ្នាមួយចំនួនដូចជា៖

**លួចដោយប្រើហិង្សា** មិនទុកលទ្ធភាពឲ្យជនរងគ្រោះអាចសម្រេចអំពីឆន្ទៈព្រមប្រគល់ ឬមិនប្រគល់នោះឡើយ ហើយជនរងគ្រោះមិនអាចដោះខ្លួនចេញពីបទល្មើសនោះទេ។

**ការកំហែងយក** មានការទុកលទ្ធភាពឲ្យជនរងគ្រោះជាអ្នកសម្រេចក្នុងការប្រគល់ ឬ មិនប្រគល់ និងផ្តល់លទ្ធភាពអោយជនរងគ្រោះដោះខ្លួនចេញពីបទល្មើសនេះបាន។

**២.២.៣ កម្មវត្ថុនៃបទល្មើស**

បទល្មើសទាំងពីរមានគោលបំណងទទួលបាននូវកម្មវត្ថុផ្សេងៗគ្នា ដែលបានបញ្ញត្តិយ៉ាងច្បាស់ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។នៅត្រង់ចំណុចនេះ បទល្មើសទាំងពីរ មានកម្មវត្ថុដែលមានលក្ខណៈជាទ្រព្យសម្បត្តិដូចគ្នា តែវាមានភាពខុសគ្នាត្រង់ថាបទល្មើសលួចដោយប្រើហិង្សា គឺមានកម្មវត្ថុតែមួយគត់ រីឯការកំហែងយកវិញគឺមានកម្មវត្ថុច្រើន។ ដូច្នេះ ភាពខុសគ្នានៃកម្មវត្ថុរវាងបទល្មើសទាំងពីរមានដូចតទៅ៖

**លួចដោយប្រើហិង្សា** គឺមានកម្មវត្ថុត្រឹមតែជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ។

**ការកំហែងយក** គឺមានកម្មវត្ថុជាច្រើនដែលរួម ហត្ថលេខា ឬស្នាមមេដៃ ការសន្យា ឬការបោះបង់អ្វីមួយ ការបង្ហាញអាចកំបាំងណាមួយ និងមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិ។

**២.៣ ធាតុអត្តនោម័ត**

ធាតុអត្តនោម័ត (ធាតុចិត្តសាស្ត្រ) សំដៅទៅលើចេតនានៃការប្រព្រឹត្តបទល្មើសរួមទាំងគោលបំណងផងដែរ។ ភាពខុសគ្នារវាងបទល្មើសទាំងពីរ ចំពោះធាតុអត្តនោម័ត គឺគោលបំណងនៃការប្រព្រឹត្តបទល្មើស។ បទល្មើសទាំងពីរ មានគោលបំណងបំពានលើរូបបុគ្គលដូចគ្នា ប៉ុន្តែបទល្មើសលួចដោយប្រើហិង្សា មានគោលបំណងមួយទៀត គឺបំពានទៅលើសិទ្ធិលើលំនៅដ្ឋាន។ ចំនែកឯការកំហែងយក គឺគ្មានគោលបំណងបំពានសិទ្ធិលើលំនៅដ្ឋាននោះទេ។

**កថាខណ្ឌទី២ មូលហេតុ និងវិធានការ**

នៅក្នុងសង្គមបច្ចុប្បន្ន បទលួច និងការកំហែងយក មានការកើនឡើងជាលំដាប់ ធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយវាបានបង្កអោយមាននូវសោកនាដកម្ម និងផលវិបាកធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល។ ដូច្នេះហើយ ដើម្បីធ្វើការកាត់បន្ថយ និងលុបបំបាត់បទល្មើសទាំងពីរនេះបាន យើងគួរស្វែងយល់អំពីមូលហេតុ និងវិភាគស្វែងរកវិធានការដើម្បីទប់ស្កាត់។

**១. មូលហេតុ**

តាមភាពជាក់ស្តែង នៃការវិវត្តនៃបទល្មើស យើងធ្វើការកត់សម្គាល់ឃើញថាមានកត្តារួមផ្សំសំខាន់ៗចំនួនបី ដែលបណ្តាលឲ្យមានកំណើនបទល្មើសទាំងពីរដូចជាៈ កត្តាច្បាប់ កត្តាអប់រំ និងកត្តាបុគ្គល។

**១.១ កត្តាច្បាប់**

កត្តាច្បាប់ គឺជាកត្តាចម្បងបំផុតដែលមានទំនាក់ទំនងក្នុងការប្រព្រឹត្តបទល្មើស ពីព្រោះច្បាប់គឺជាវិធានគតិយុត្តមួយ កំណត់ពីព្រំដែននៃសិទ្ធិ និងអំពើដែលមិនអាចប្រព្រឹត្តបានរួមទាំងការដាក់ទណ្ឌកម្មផងដែរ។ ទោះបីជាមានការកំណត់អំពីបទល្មើសនៅក្នុងច្បាប់ក៏ដោយ ប៉ុន្តែបទល្មើសនៅតែកើតមានឡើង ដោយសារតែកង្វះខាតនៃការអនុវត្តច្បាប់ដែលមានស្រាប់ និងការអនុវត្តច្បាប់ដោយរំលោភបំពានគ្មានទិសដៅត្រឹមត្រូវ។ ជាពិសេសការកកើតឡើងនៃអំពើពុករលួយដែលសង្គមស្អប់ខ្ពើម តែងតែធ្វើឲ្យជនល្មើសរួចផុតពីការទទួលខុសត្រូវដោយខុសច្បាប់។

**១.២ កត្តាអប់រំ**

ការកង្វះខាតធនធានមនុស្ស ធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់សីលធម៌សង្គម មានន័យថា

ប្រជាពលរដ្ឋខ្វះចំណេះដឹង និងការគិតពិចារណា ក្នុងការបែងចែកអំពើល្អ និងអំពើអាក្រក់។ វាជាហេតុបណ្ដាលអោយសង្គមបាត់បង់នូវសន្តិភាព និងសន្តិសុខ ដែលធ្វើឲ្យមានការធ្លាក់ចុះនូវកម្រិតនៃការយល់ដឹងរបស់ប្រជាជននូវអំពើដែលខ្លួនបានប្រព្រឹត្ត។ មួយវិញទៀត អត្រានៃការអប់រំនៅក្នុងប្រទេសមានកម្រិតទាប ធ្វើឲ្យប្រទេសមានការអភិវឌ្ឍយឺតបំផុត រួមផ្សំជាមួយនឹងការឆ្លងកាត់នូវសង្គ្រាមជាច្រើនឆ្នាំ បណ្ដាលឲ្យប្រទេសយើង មានការខ្វះខាតខាងផ្នែកអប់រំយ៉ាងខ្លាំង ដែលឆ្ពោះទៅដល់ការប្រព្រឹត្តបទល្មើសផ្សេងៗ ដូចជាបទលួច កំហែងយក ពេលខ្លះឈានដល់ការសម្លាប់មនុស្សទៀតផង។បើយើងសង្កេតទៅមើលប្រទេសជឿនលឿន ប្រជាពលរដ្ឋរបស់គេពោរពេញទៅដោយចំណេះដឹង ដូច្នេះបទល្មើសពុំសូវកើតមានឡើងនោះទេ។ ម៉្យាងវិញទៀត ការអប់រំនេះគឺជាទុនមួយសំខាន់សម្រាប់បណ្ដុះបណ្ដាលនូវធនធានមនុស្សនៅក្នុងសង្គម កុំឲ្យមានគំនិត ឃោរឃៅអមនុស្សធម៌ គ្មានចំណេះដឹងដែលជាហេតុធ្វើអោយពួកគេ ប្រព្រឹត្តអំពើល្មើសច្បាប់ដោយគ្មានការគិតពិចារណាអ្វីទាំងអស់។ ហេតុនេះកត្តាអប់រំ មានសារៈសំខាន់បំផុត ដើម្បីកាត់បន្ថយនូវបទល្មើសផ្សេងៗកុំឲ្យកើតមានកាន់តែច្រើន ព្រមទាំងធ្វើអោយសង្គមមានសន្តិសុខល្អទៀតផង។

ការអប់រំផ្នែកសាសនាក៏ជាកត្តាមួយសំខាន់ផងដែរ ប្រសិនបើមានការធ្លាក់ចុះនូវឥទ្ធិពលសាសនា នាំឲ្យមានបទល្មើសកើតឡើង ដោយប្រជាពលរដ្ឋមិនខ្លាចរអានឹងអំពើបុណ្យបាប។ ចំពោះប្រជាជនកម្ពុជាភាគច្រើន ប្រកាន់យកព្រះពុទ្ធសាសនា ដែលសាសនានេះបានអប់រំទូន្មានប្រៀនប្រដៅអោយមនុស្សសាងតែអំពើល្អ និងមិនត្រូវចង់បានរបស់អ្នកមកធ្វើជារបស់ខ្លួន ក៏ប៉ុន្តែសព្វថ្ងៃនេះ ការប្រតិបត្តិតាមសាសនាមានការធ្លាក់ចុះដោយសារតែការរីកចម្រើនផ្នែកបច្ចេកវិទ្យាទំនើប ធ្វើឲ្យមនុស្សចង់មាន ចង់បានភ្លេចគិតពីបុណ្យ បាប គុណ ទោស ពិសេសការហូរចូលនូវវប្បធម៌បរទេស។ ម៉្យាងវិញទៀត មនុស្សភាគច្រើន គឺធ្វើអ្វីដើម្បីខ្លួនទទួលបានផលប្រយោជន៍រហូតដល់ឈានទៅការលួច កំហែងយក ឬអំពើខុសច្បាប់ផ្សេងទៀត។

**១.៣ កត្តាបុគ្គល**

បន្ទាប់ពីបានរៀបរាប់បកស្រាយអំពីមូលហេតុនៃកត្តាទាំងពីរខាងលើមក យើងឃើញថាកត្តាបុគ្គលក៏ជាកត្តាស្នូលមួយផងដែរ ដែលធ្វើឲ្យមានការកើនឡើងយ៉ាងខ្លាំងនូវការប្រព្រឹត្តបទល្មើស។ បទល្មើសដែលបានកើតឡើង គឺជាការជម្រុញដោយបុគ្គលខ្លួនយើងផ្ទាល់ និងពេលខ្លះដោយបុគ្គលដទៃដែលបាន ញុះញង់ឲ្យប្រព្រឹត្តអំពើណាដែលមិនគួរគប្បី ដែលវាផ្ដើមចេញដោយ បុគ្គលិកលក្ខ

ណៈ ការអប់រំបុគ្គលតាមរយៈសង្គម និងគ្រួសារ ការខ្វះការពិចារណា ជាពិសេសកម្រិតជីវភាព ។ ចំពោះបុគ្គលិកលក្ខណៈរបស់បុគ្គលនោះ គឺជាហេតុធ្វើឲ្យបុគ្គលនោះងាយនឹងធ្វើសកម្មភាពដែលផ្ទុយនឹងច្បាប់ ដូចជាមានសភាពឆាប់ខឹង ឆេវឆាវ គ្មានការអត់ធ្មត់ មិនមានភាពអធ្យាស្រ័យ នេះជាហេតុដែលធ្វើឲ្យ អត្រានៃការប្រព្រឹត្តបទល្មើសមានការកើនឡើងខ្ពស់គួរឲ្យកត់សម្គាល់ដែលឈានដល់ការសម្លាប់មនុស្សទៀតផង។ មួយវិញទៀត ការអប់រំបុគ្គលតាមរយៈសង្គមនោះជាចំណុចសំខាន់ខ្លាំងណាស់ ព្រោះថា សង្គមគឺជាកញ្ចក់សម្រាប់ឆ្លុះនូវតថភាពដែលបានកើតមានឡើង ហើយវាងាយនឹងអូសទាញបុគ្គលនោះប្រព្រឹត្តបទលួច ឬកំហែងយកជាដើម មានន័យថា សង្គមល្អប្រជាពលរដ្ឋមានការយល់ដឹងខ្ពស់ នោះបុគ្គលដទៃៗទៀតដែលបានរស់នៅក្នុងសង្គមនោះនឹងធ្វើតែអំពើល្អតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ប្រសិនបើសង្គមនោះមិនល្អ បទល្មើសកើតមានឡើងច្រើន ប្រជាពលរដ្ឋយករបរលួចជាអាជីព នោះបុគ្គលផ្សេងទៀតនឹងយកតម្រាប់តាម ដែលធ្វើឲ្យអំពើលួចមានកើនឡើង។ ម្យ៉ាងវិញទៀត ការអប់រំបុគ្គលតាមរយៈសង្គម មិនទាន់គ្រប់គ្រាន់នោះទេ វាត្រូវចូលរួមពីការអប់រំដោយគ្រួសារផងដែរ ព្រោះថាគ្រួសារជាកោសិកានៃសង្គម។ ប្រសិនបើបុគ្គលបានទទួលការអប់រំ ថែទាំ តាមដានការសិក្សា ទំនុកបម្រុងដោយ ឪពុក ម្តាយ ឬក្រុមគ្រួសារជាដើម នោះបុគ្គលពិតជាមិនងាយក្នុងការអូសទាញដោយកត្តាខ្លួនឯង និងកត្តាអ្នកដទៃនោះទេ ព្រោះថាខ្លួនមានការវិវត្តខាងផ្នែកសតិ និងបញ្ញាក្នុងគិតពិចារណាខ្ពស់ជាងបុគ្គលផ្សេងដែលខ្វះភាពកក់ក្តៅពីក្រុមគ្រួសារដែលងាយឲ្យបុគ្គលនោះធ្លាក់ខ្លួនជាជនល្មើសតាមរយៈការអូសទាញពីសំណាក់មជ្ឈដ្ឋានជុំវិញខ្លួន។

កម្រិតជីវភាព ក៏នៅតែជាបញ្ហាចម្បងចំពោះបុគ្គលផងដែរ ព្រោះថាប្រសិនបើជននោះ មានជីវភាពក្រខ្សត់ដែលគាត់ពុំអាចមានលទ្ធភាពក្នុងការទំនុកបម្រុងចំពោះខ្លួនឯង និងគ្រួសារទេ បូករួមទាំងមានការខ្វះខាតខាងផ្នែកអប់រំ និងជំនាញផង ជាហេតុធ្វើអោយគាត់មានសម្ពាធកាន់តែខ្លាំងក្នុងការប្រព្រឹត្តបទល្មើសលួច ឬការកំហែងយកទៅលើជនដទៃ ដើម្បីទទួលបានទ្រព្យសម្បត្តិ ឬរបស់របរណាដែលមានតម្លៃ សម្រាប់ធ្វើការផ្គត់ផ្គង់ជីវភាពរបស់គាត់។

**២. វិធានការប្រឆាំង**

បទល្មើសលួច និងការកំហែងយក តែងតែកើតឡើងជារឿយនៅបណ្តាប្រទេសទូទាំងសកលលោក ក្នុងនោះប្រទេសកម្ពុជាយើង ក៏មានការកើនឡើងនូវអត្រាប្រព្រឹត្តបទល្មើសទាំងពីរនេះផងដែរ។ ដូច្នេះ រាជរដ្ឋាភិបាល គួរយកចិត្តទុកដាក់ក្នុងការបង្ការនូវបទល្មើសនោះបន្ថែមទៀត

កុំឲ្យកើតមានជាហូរហែដែលបណ្តាលឲ្យប្រទេសអសន្តិសុខ និងអសណ្តាប់ធ្នាប់សង្គម និងបង្កឲ្យមានភាពចលាចល អសកម្ម និងអស្ថេរភាពជាដើម ដោយធ្វើការសហការជាមួយប្រជាពលរដ្ឋ ក្នុងការចាត់វិធានការផ្សេងៗយកមកអនុវត្តទៅតាមតំបន់មូលដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា។ ដើម្បីធ្វើការការពារ ក៏ដូចជារារាំងកុំឲ្យមានការប្រព្រឹត្តបទល្មើសដោយមានប្រសិទ្ធិភាព យើងត្រូវមានវិធានការចំនួនពីរ គឺ វិធានការទប់ស្កាត់ និងវិធានការប្រឆាំង។

**២.១ វិធានការទប់ស្កាត់**

វិធានការទប់ស្កាត់ គឺសំដៅទៅលើវិធានមួយសម្រាប់ធ្វើការរារាំងកុំឲ្យមានការប្រព្រឹត្តបទល្មើសនៅក្នុងសង្គម។ ដូច្នេះ ដើម្បីធ្វើការបង្ការកុំឲ្យកើនឡើងនូវបទល្មើសលួច និងការកំហែងយក យើងត្រូវធ្វើការ អប់រំប្រជាជនដល់មូលដ្ឋាន ពង្រឹងវិស័យច្បាប់ ពង្រឹងស្ថាប័នដែលពាក់ព័ន្ធ ការបង្កើតមជ្ឈមណ្ឌលអប់រំនានា និងធ្វើឲ្យមានស្ថេរភាពនយោបាយ។

**២.១.១ អប់រំប្រជាជនតាមមូលដ្ឋាន**

ដើម្បីធ្វើការទប់ស្កាត់អត្រានៃបទល្មើសដែលកើតមានឡើងនៅក្នុងសង្គម យើងគប្បីពង្រឹងនូវការអប់រំប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាននានា ឲ្យពួកគាត់បានយល់នូវសកម្មភាពផ្សេងៗ ក៏ដូចជាឲ្យគិតពិចារណាខ្ពស់ក្នុងការធ្វើអ្វីមួយ។ ការអប់រំនេះ អាចធ្វើឡើងជាច្រើនមធ្យោបាយ ដែលមានដូចជា ការធ្វើសមាជនៅក្នុងភូមិឃុំដែលរស់នៅ ការផ្សព្វផ្សាយតាមរយៈ ទូរទស្សន៍ កាសែត ជាដើម។ ជាពិសេស ត្រូវឲ្យប្រជាជនទាំងអស់ មានការស្វែងយល់អំពីវិស័យច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យមានភាពទូលំទូលាយ រួមទាំងសហការជាមួយមន្ត្រីនៅក្នុងមូលដ្ឋាន រាល់ការចាំបាច់ផ្សេងៗ ដូចជា មានករណីបទល្មើសណាមួយកើតឡើង។

មួយវិញទៀត ការអប់រំតាមព្រះពុទ្ធសាសនា ក៏ជាចំនុចសំខាន់បន្ទាប់ពីការអប់រំឲ្យប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់ផងដែរ ព្រោះថា ប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសកម្ពុជា ភាគច្រើនស្ទើរតែជាអ្នកកាន់សាសនាព្រះពុទ្ធ ម៉្យាងវិញទៀត យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញត្តិផងដែរថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ដូច្នេះហើយ ការអប់រំតាមព្រះពុទ្ធសាសនាក៏ជាផ្នែកមួយ ក្នុងការចូលរួមក្នុងការបញ្ចៀស ក៏ដូចជាទប់ស្កាត់បទល្មើសកើតមានឡើងផងដែរ។ តាមទ្រឹស្តីព្រះពុទ្ធ គឺសុទ្ធសឹងតែអប់រំឲ្យមនុស្សដើររកផ្លូវល្អ ចេះគោរពគ្នាទៅវិញទៅមក កុំលួចទ្រព្យសម្បត្តិអ្នកដទៃ និងជៀសវាងការសម្លាប់មនុស្សជាដើម មានន័យថា យើងគួរផ្សព្វផ្សាយឲ្យ

បានទូលំទូលាយ ដែលជាផ្នែកមួយ ក្នុងការអប់រំគំនិត និងបង្កើនផ្នែកសតិបញ្ញាឲ្យប្រជាជនដែលរស់នៅក្នុងមូលដ្ឋានបានមួយកម្រិតទៀត ដើម្បីបញ្ចៀសការប្រព្រឹត្តបទល្មើស។

**២.១.២ ពង្រឹងវិស័យច្បាប់**

ច្បាប់ គឺជាបទដ្ឋានគតិយុត្តមួយសម្រាប់ធ្វើការអនុវត្ត ដើម្បីធានាសណ្តាប់ធ្នាប់ និងសន្តិសុខនៅក្នុងសង្គម ដែលធ្វើការអនុម័តដោយរដ្ឋសភា រួមទាំងមានការពិនិត្យដោយព្រឹទ្ធសភា និងឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។

ការពង្រឹងផ្នែកច្បាប់ គឺជាចំនុចចម្បងជាងគេ មុននឹងធ្វើការអនុវត្ត ឲ្យស្របទៅតាមឆន្ទៈនៃច្បាប់។ ដូច្នេះ អ្នកបង្កើតច្បាប់ ត្រូវធ្វើសេចក្តីពង្រាងច្បាប់ អនុម័ត និងត្រួតពិនិត្យឲ្យបានហ្មត់ចត់ និងមានប្រសិទ្ធិភាព ជៀសវាងការចែងធ្វើឲ្យមានភាពខ្វះចន្លោះនៃច្បាប់ដែលបណ្តាលឲ្យបទល្មើសកាន់តែកើតមានឡើងជាលំដាប់។

**២.១.៣ ពង្រឹងស្ថាប័នដែលពាក់ព័ន្ធ**

វិធានការនេះ យើងសំដៅទៅលើការបណ្តុះបណ្តាលស្ថានប័នដែលមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ឲ្យស្គាល់ពីសិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងការអនុវត្ត។ ស្ថាប័នទាំងនោះ យើងរាប់បញ្ចូលទាំងស្ថាប័នយុត្តិធមិផងដែរ គឺប្រព័ន្ធតុលាការ។ ស្ថាប័នតុលាការត្រូវផ្តល់យុត្តិធមិតាម បញ្ញត្តិច្បាប់ដែលបានចែង ដើម្បីធានាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សង្គម ពិសេសទប់ស្កាត់ និងបង្ក្រាបឲ្យបានទាន់ពេលវេលានូវអំពើល្មើសច្បាប់គ្រប់ប្រភេទ។ មួយវិញទៀត ស្ថាប័នដែលសំខាន់បំផុត ក្នុងការអនុវត្តផ្ទាល់ ដើម្បីរក្សាសុវត្ថិភាព និងបង្ក្រាបបទល្មើសជូនប្រជាពលរដ្ឋគឺអាជ្ញាធរគ្រប់ជាន់ថ្នាក់ គួរតែមានការហ្វឹកហាត់ ឲ្យមានជំនាញច្បាស់លាស់ចំពោះមុខងាររបស់ខ្លួន។

**២.១.៤ បង្កើតមជ្ឈមណ្ឌលអប់រំ**

នៅក្នុងន័យច្បាប់ ការផ្តន្ទាទោសចំពោះបទល្មើសមួយគឺសំដៅទៅលើការអប់រំ ដើម្បីឲ្យជនល្មើសនោះកែប្រែខ្លួន វិលចូលមករស់នៅក្នុងសង្គមវិញ។ ដូច្នេះហើយ ការបង្កើតមជ្ឈមណ្ឌលអប់រំ ក៏ជាផ្នែកមួយក្នុងការបណ្តុះបណ្តាលធនធានមនុស្សឡើងវិញ និងអាចកាត់បន្ថយបទល្មើសដែលកើតមានឡើង ដោយសារតែការទទួលចំណេះដឹង និងវិជ្ជាជីវៈផ្សេងៗ នៅពេលដែលពួកគេរួចផុតពីទោស។ ម៉្យាងវិញទៀត មជ្ឈមណ្ឌលអប់រំនេះ ក៏អាចទទួលយកជនក្រីក្រគ្មានទីពឹង ជនអនាថាមកធ្វើការ

អប់រំផងដែរ ក្នុងគោលបំណងកសាងពួកគាត់ឲ្យទទួលបានចំនេះជំនាញ បញ្ចៀសនៅគំនិតទុច្ចរិត ដូចជាការប្រព្រឹត្តបទល្មើសផ្សេងៗជាដើម។

### ២.១.៥ ស្ថេរភាពនយោបាយ

ប្រទេសមួយមានសន្តិភាព ស្ថេរភាពបាន អាស្រ័យទៅតាមការដឹកនាំឲ្យមានស្ថេរភាពខាងផ្នែកនយោបាយ។ ស្ថេរភាពនយោបាយ ជាបញ្ហាមួយដ៏សំខាន់ដែលរាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ទៅលើបញ្ហានេះ ព្រោះកាលណាមានស្ថេរភាពហើយនោះ នឹងធ្វើឲ្យសង្គមរីកចម្រើន និងកាត់បន្ថយភាពក្រីក្រ។ ដូច្នេះប្រជាពលរដ្ឋអាចរស់នៅបានដោយសុខស្រួល មានការងារធ្វើ និងមានជីវភាពធូរធារ ដែលជាហេតុធ្វើការប្រព្រឹត្តបទល្មើសមានការថយចុះមួយកម្រិត។ តែផ្ទុយទៅវិញ ប្រសិនបើប្រទេសអស្ថេរភាពវិញ សង្គមក៏គ្មានសន្តិសុខ មានភាពច្របូកច្របល់ឥតឈប់ឈរ។ កត្តានេះហើយ ដែលបង្កើតឲ្យមានបទល្មើសពីជនឆ្លៀតឪកាស។

### ២.២ វិធានការបង្ក្រាប

វិធានការនេះ សំដៅទៅលើការស្តារស្ថានភាពដែលកើតមានរួចហើយឲ្យមានសណ្តាប់ធ្នាប់សន្តិសុខឡើងវិញ។ ដើម្បីឲ្យសម្រេចទៅបាន រាល់សកម្មភាពទាំងអស់ត្រូវមានការចូលរួមយ៉ាងខ្លាំងក្លាពីអាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋផងដែរ។ ក្នុងនោះ យើងគួរតែធ្វើការពង្រឹងជំនាញអនុវត្តផែនការឲ្យច្បាស់លាស់ ជម្រុញទឹកចិត្តដល់អាជ្ញាធរដែលបានធ្វើការយ៉ាងសកម្ម និងត្រូវសហការគ្នាជាមួយប្រជាពលរដ្ឋផងដែរ។

### ២.២.១ ពង្រឹងជំនាញអាជ្ញាធរមានសមត្ថកិច្ច

គ្រប់មន្ត្រីដែលមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ភាគច្រើនគឺពុំសូវបានហ្វឹកហាត់ពីជំនាញច្បាស់លាស់ និងរួមផ្សំទាំងការខ្វះខាតផ្នែកបច្ចេកទេសសម្ភារៈ ដែលបណ្តាលឲ្យការបំពេញការងារពុំសូវបានល្អ។ ដូច្នេះហើយ ជំហានដំបូង ត្រូវធ្វើអភិវឌ្ឍទៅលើផ្នែកធនធានមនុស្សនៅក្នុងស្ថាប័ន មានន័យថា មុននឹងមានតួនាទីចូលបម្រើការក្លាយជាអាជ្ញាធរមួយរូប ត្រូវមានការឆ្លងកាត់វគ្គបណ្តុះបណ្តាលឲ្យមានជំនាញត្រឹមត្រូវ។ បន្ទាប់ពីការបណ្តុះបណ្តាល កត្តាដែលសំខាន់មួយទៀតនោះគឺបញ្ហាបច្ចេកទេស និងសម្ភារៈ ស្ថាប័នដែលពាក់ព័ន្ធគួរតែបន្ថែមនៅសម្ភារៈណាដែលចាំបាច់ដើម្បីផ្គត់ផ្គង់ទៅអោយអាជ្ញាធរយកមកអនុវត្តបេសសកកម្មរបស់ខ្លួន រួមទាំងការបង្រៀនពីបច្ចេកទេសប្រើប្រាស់ ដូចជាការពិនិត្យកោសលវិច័យតាមបច្ចេកទេសទំនើប ការពិនិត្យស្នាមក្រយៅដៃ និងការបញ្ជាក់អត្តសញ្ញាណជាដើម ដូចបណ្តាប្រទេសជឿនលឿនមួយចំនួន។

**២.២.២ ការអនុវត្តផែនការឲ្យមានប្រសិទ្ធិភាព**

បន្ទាប់ពីមានជំនាញច្បាស់លាស់ គប្បីតែមានការកំណត់អំពីគោលដៅ និងផែនការច្បាស់លាស់ដើម្បីបង្ក្រាបបទល្មើសទៅតាមមូលដ្ឋាននីមួយៗ។ នៅក្នុងករណីនេះ ត្រូវរកគ្រប់មធ្យោបាយដើម្បីសម្រេចគោលដៅដែលបានដាក់ចេញមក នៅពេលដែលចុះប្រតិបត្តិការណ៍ត្រូវកំណត់អំពីមុខសញ្ញាឲ្យបានច្បាស់លាស់ និងបង្ក្រាបឲ្យទាន់ពេលវេលាជូនប្រជាពលរដ្ឋ។ ជាពិសេសការអនុវត្តតាមគោលដៅសំខាន់ៗដែលទទួលពត៌មានថា នឹងមានបទល្មើសកើតឡើង ដើម្បីបញ្ចៀស ការរត់គេចខ្លួនរបស់ជនល្មើស និងធ្វើការស៊ើបអង្កេតស្រាវជ្រាវគ្រប់ករណីទាំងអស់ ដោយមិនឲ្យជនណារួចពីសំណាញ់ច្បាប់នោះទេ។

**២.២.៣ លើកទឹកចិត្តដល់អាជ្ញាធរដែលបានសម្រេចភារកិច្ច**

ក្រោយពីសម្រេចភារកិច្ចចប់សព្វគ្រប់ ស្ថាប័នតាមមុខជំនាញនីមួយៗគួរតែបង្កើតឲ្យមានកម្មវិធីលើកទឹកចិត្តដល់មន្ត្រីដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ច ដោយផ្តល់ជា៖

-រង្វាន់ជាទឹកប្រាក់សម្រាប់ការលើកទឹកចិត្ត

-សម្ភារៈប្រើប្រាស់ផ្សេងៗ

-ផ្តល់ប័ណ្ណសរសើរ

ការធ្វើដូចនេះគឺជាការជម្រុញកម្លាំងចិត្តដល់មន្ត្រីគ្រប់រូបក្នុងទិសដៅ ដើម្បីជួយពង្រឹងទាំងផ្នែកស្មារតី និងកម្លាំងកាយរបស់ពួកគាត់ដែលបានខិតខំបំពេញការងាររបស់ខ្លួនបានជោគជ័យ។

**២.២.៤ ការសហការរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ**

ការចូលរួមរបស់ប្រជាពលរដ្ឋជាមួយនឹងសមត្ថកិច្ច វាជាកត្តាសំខាន់បំផុតដែលជួយពន្លឿនការងារ និងការអនុវត្តឲ្យមានភាពឆាប់រហ័ស ដោយសារតែប្រជាពលរដ្ឋ ជាអ្នកដែលនៅជិតបំផុតទៅនឹងស្ថានភាពដែលបង្កបទល្មើស។ ដូច្នេះហើយ ប្រជាពលរដ្ឋគួរតែទទួលពន្យល់ណែនាំពីអាជ្ញាធរដែលចុះទៅតាមមូលដ្ឋាន ដើម្បីបង្ហាត់បង្រៀនឲ្យយល់ដឹងអំពីច្បាប់ និងអំពើដែលល្មើសច្បាប់។ ជាចុងក្រោយ ការសហការគ្នារវាងប្រជាពលរដ្ឋ និងអាជ្ញាធរមានសមត្ថកិច្ច គឺពិតជាមានសារសំខាន់ក្នុងការបង្ក្រាបរាល់បទល្មើសនៅក្នុងមូលដ្ឋានទទួលបានជោគជ័យ។

# សេចក្តីសន្និដ្ឋាន

៙៙📖៙៙

ឆ្លងតាមការបកស្រាយទៅលើប្រធានបទខាងលើនេះ យើងសង្កេតឃើញថា វាមានលក្ខណៈស្រដៀងគ្នា ដែលមានទាំងចំណុចដូចគ្នា និងចំណុចខុសគ្នា។ ភាពដូចគ្នា និងខុសគ្នានៃបទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក ត្រូវបានបង្ហាញនៅក្នុងការប្រៀបធៀបបទល្មើសទាំងពីរដែលយើងត្រូវធ្វើការសិក្សាឲ្យស៊ីជម្រៅទៅលើបទល្មើសនីមួយៗជាមុន។

បទល្មើសលួចដោយប្រើហិង្សា គឺជាការដកហូតទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងៗទៀតរបស់អ្នកដទៃ ដោយប្រើប្រាស់អំពើហិង្សា ដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ នៅក្នុងបទល្មើសនេះផងដែរ គឺមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ៣៥៧ ដែលសំដៅទៅលើ សកម្មភាពលួចដោយហិង្សា ទោះបីប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលដោយប្រើប្រាស់ហិង្សាក៏ដោយ មួយវិញទៀតការកាប់គាស់ទម្លុះទម្លាយក៏ចាត់ចូលជាអំពើហិង្សាផងដែរ។ ចំពោះធាតុសម្ភារៈវិញ គឺស្តែងឡើងគ្រប់មធ្យោបាយ និងបានស្តែងចេញនូវរូបភាពនៃការដកហូតដោយទុច្ចរិត ដែលវាលេចចេញនូវសញ្ញាណពីរផ្សេងទៀត រួមមាន សញ្ញាណនៃការដកហូតដោយគ្មានសិទ្ធិ និងសញ្ញាណដកហូតដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ។ ចំពោះធាតុចិត្តសាស្ត្រ ដែលជាចេតនាទុច្ចរិតនៅក្នុងបទល្មើសនេះវិញ គឺមានគោលដៅតែមួយគត់នៃការប្រព្រឹត្តបទល្មើសចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកជារបស់ខ្លួន តាមរយៈការដកហូតដោយទុច្ចរិត។

បើយើងធ្វើការពិនិត្យទៅលើអំពើកំហែងយក គឺជាអំពើមួយដែលធ្វើការកំហែងដើម្បីទទួលនូវកម្មវត្ថុមួយចំនួន ដោយប្រើប្រាស់ហិង្សា ពេលខ្លះមិនបានឈានដល់ការប្រើហិង្សានោះទេ ត្រឹមតែធ្វើការគំរាមកំហែងថានឹងប្រើប្រាស់ហិង្សា ឬធ្វើការបង្ខិតបង្ខំជាដើម។ ធាតុនីត្យានុកូលនៃការកំហែងយក ត្រូវបានចែងនៅត្រង់មាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌ។ រីឯ ធាតុសត្យានុម័តនៃបទល្មើសវិញ គឺស្តែងឡើងតាមរយៈនៃការព្រមព្រៀងដោយអធន្ទៈក្នុងការប្រគល់ កម្មវត្ថុនៃការកំហែងយក និងរូបរាងនៃអំពើ។ កម្មវត្ថុនៃបទល្មើសនេះរួមមាន ហត្ថលេខា ឬស្នាមមេដៃ ការសន្យា ឬការបោះបង់អ្វីមួយ ការបង្ហាញអាថ៌កំបាំងណាមួយ និងមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិ។ ចំពោះរូបរាងនៃអំពើ គឺសំដៅទៅលើសកម្មភាពនៃការប្រព្រឹត្តបទល្មើស ដូចជាការប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំផ្សេងៗ។ ធាតុអត្តនោម័តនៃការកំហែងយក គឺស្តែងឡើងពី

ចេតនាទុច្ចរិត តាមរយៈអំពើដែលបានប្រព្រឹត្ត ក្នុងគោលបំណងតែមួយគត់ ទទួលបាននូវកម្មវត្ថុនៃបទល្មើស ដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន។ លើសពីនេះទៀត ការកំហែងយក ក៏មាននូវស្ថានទម្ងន់ទោសផងដែរក្នុងករណីមួយចំនួនដូចជា ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ស្ថានទម្ងន់ទោសដោយសារប្រើប្រាស់អាវុធ ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ និងស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ។

បន្ទាប់ពីបានស្វែងយល់ទៅលើបទល្មើសទាំងពីរនេះរួចមក យើងអាចធ្វើការទាញនូវចំណុចមួយចំនួននៃប្រធានបទ ដើម្បីយកមកប្រៀបធៀបគ្នា ដោយលើកឡើងពីភាពដូចគ្នា និងភាពខុសគ្នានៃបទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក។

បទល្មើសទាំងពីរនេះ មានចំណុចដូចគ្នាមួយចំនួនរួមមាន ការបែងចែកនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ដែលបានធ្វើការបែងចែកបទល្មើសទាំងពីរស្ថិតនៅក្នុងគន្ថីមាតិកា ជំពូកជាមួយគ្នា។ ម៉្យាងវិញទៀត បើយើងមើលទៅលើធាតុសត្យានុម័តមួយចំនួន ក៏មានលក្ខណៈដូចគ្នាផងដែរ ។ បទល្មើសទាំងពីរ សុទ្ធតែមានការប្រើហិង្សាដូចគ្នា មិនថាលួច និងការកំហែងយកនោះទេ។ ចំពោះផលដែលទទួលបានពីការសម្រេចនៃបទល្មើស គឺមានកម្មវត្ថុជាទ្រព្យសម្បត្តិ។ រីឯធាតុអត្តនោម័តនៃការប្រព្រឹត្តបទល្មើសវិញ គឺមិនមានភាពខុសគ្នាឡើយ។ បទល្មើសទាំងពីរ សុទ្ធតែមានចេតនាក្នុងការចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ យកមកជារបស់ផ្ទាល់ខ្លួនដូចគ្នា។

ភាពខុសគ្នានៃបទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក គឺមានលក្ខណៈទីទៃគ្នាមួយចំនួនផងដែរ ដែលអាចធ្វើឲ្យយើងមានការភ័ន្តច្រឡំចំណុចខ្លះៗរវាងបទល្មើសទាំងពីរនេះ។ ចំពោះចំណុចខុសគ្នានោះត្រង់ថា បទល្មើសលួចដោយប្រើហិង្សា គឺជនល្មើសជាអ្នកធ្វើការដកហូតទុច្ចរិតដោយខ្លួនឯង រីឯការកំហែងយកវិញ ជនល្មើសជាអ្នកធ្វើការកំហែងដោយអោយជនរងគ្រោះធ្វើការប្រគល់នូវកម្មវត្ថុណាមួយមកឲ្យខ្លួន ការព្រមព្រៀងប្រគល់នោះ គឺជាការប្រគល់ដោយអឆន្ទៈរបស់ជនរងគ្រោះមានន័យថា ជនរងគ្រោះពុំមានបំណងប្រគល់ទៅឲ្យនោះទេ។ លើសពីនេះទៅទៀត ចិរវេលានៃការប្រព្រឹត្តបទល្មើសទាំងពីរក៏ខុសគ្នាផងដែរ បទល្មើសលួចដោយប្រើហិង្សា ជាសកម្មភាពដែលកើតឡើងភ្លាមៗ ចំណែកឯការកំហែងយកវិញ គឺមានការទុកពេលវេលាឲ្យជនរងគ្រោះធ្វើការពិចារណាក្នុងការប្រគល់នូវកម្មវត្ថុដែលជនល្មើសបានទាមទារ។

សរុបមកវិញ បទល្មើសលួចដោយប្រើហិង្សា និងការកំហែងយក គឺមានលក្ខណៈស្រដៀងគ្នា ដែលអាចធ្វើអោយយើងងាយនឹងភ័ន្តច្រលំទៅលើចំណុចមួយចំនួន។ ទោះជា ក្រមព្រហ្មទណ្ឌ បានបញ្ញត្តិអំពើទាំងពីរនេះក៏ពិតមែន តែបទល្មើសទាំងពីរនេះ វាបានកើតឡើងជាញឹកញាប់នៅក្នុង សង្គមដែលបង្កឲ្យការប៉ះពាល់ដល់ការអនុវត្ត ចំពោះមន្ត្រីដែលមានសមត្ថកិច្ចទៅលើជនទាំងឡាយ ណាដែលបានប្រព្រឹត្តអំពើទាំងពីរនេះដែលជាមូលហេតុនាំឲ្យ អសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

បន្ទាប់ពីបានធ្វើសេចក្តីសន្និដ្ឋានរួចមក យើងខ្ញុំសូមបញ្ចេញនូវមតិយោបល់ផ្ទាល់ខ្លួនមួយចំនួន ដែលពាក់ព័ន្ធទៅនឹងបទល្មើសទាំងពីរដែលមានភាពខ្វះចន្លោះ ដែលនឹងទាញឡើងជាអនុសាសន៍នៅ ក្នុងចំណុចបន្ទាប់នេះ។

# អនុសាសន៍

ឈ្លង៊ឡ៙៙

ឆ្លងកាត់តាមការសិក្សារទៅលើបទល្មើសទាំងពីរ និងការប្រៀបធៀបនៃបទល្មើសនីមួយៗរួចមក បញ្ជាក់អោយឃើញថា មានចំណុចមួយចំនួនដែលជាផលវិជ្ជមាន (គុណសម្បត្តិ) និងមានចំណុចខ្លះជាផលអវិជ្ជមាន (គុណវិបត្តិ) ។

ដោយយើងបានសង្កេតឃើញពីចំណុចខ្វះខាតមួយចំនួននៃបទល្មើសលួចដោយប្រើហិង្សា និងការកំហែងយកនេះ ទើបយើងខ្ញុំសូមធ្វើការផ្តល់ជាមតិយោបល់មួយចំនួនក្នុងន័យជួយស្ថាបនា ដើម្បីអោយការអនុវត្តកាន់តែមានភាពរលូន និងមានប្រសិទ្ធិភាពជាងមុន យើងសូមលើឡើងនៅចំណុចសំខាន់ៗដូចជាៈ

## ១.ការបញ្ញត្តិនៃច្បាប់

សំដៅទៅលើការចែងអំពីបទល្មើសទាំងពីរនៅក្នុងក្រមព្រហ្មទណ្ឌ គួរធ្វើយ៉ាងណាអោយមានភាពងាយស្រួលក្នុងការយល់ និងអាចអោយអ្នកអនុវត្តស្រួលក្នុងការញែកសញ្ញាណនៃបទល្មើសដាច់ពីគ្នាពីមួយទៅមួយ។ មួយវិញទៀតការដាក់ទណ្ឌកម្មត្រូវតែកំណត់អោយសមស្របទៅនឹងស្ថានភាពសង្គម និងផលប៉ះពាល់នៃបទល្មើស ធ្វើយ៉ាងណាអោយមានភាពសមាមាត្ររវាងគ្នានិងគ្នា ដើម្បីផ្តល់យុត្តិធម៌ដល់បុគ្គលគ្រប់រូបទាំងជនរងគ្រោះ និងជនល្មើស។

## ២.ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការអនុវត្តអោយត្រូវគោលដៅ និងគោលបំណងនៃច្បាប់ដែលកំណត់អំពីសញ្ញាណនីមួយៗយ៉ាងជាក់ច្បាស់។ យើងគួរតែបង្កើតវគ្គបណ្តុះបណ្តាលតាមជំនាញទៅដល់មន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់រូប អោយពួកគាត់បានយល់ការតែច្បាស់ជាងមុន ដើម្បីផ្តល់ជាភាពងាយស្រួល និងតម្លាភាពផងដែរ។ វាជាប្រការមួយដែលមិនអាចខ្វះបាននោះទេ ព្រោះវាពង្រឹងអោយមានភាពខ្លាំងក្លាក្នុងការអនុវត្តផ្ទាល់ និងមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គលផងដែរ។

# ឯកសារយោង

ꕥꕥ📖ꕥꕥ

## លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

-ព្រះរាជក្រម នស/រកម/០៧០២/០១២ ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២

-ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

-ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

-ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧

-ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩

-ច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ

-ច្បាប់ ភូមិបាល ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១

-សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីវិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ រក្សាសិទ្ធិ ហ្វូណាន ឆ្នាំ២០០៥

## លិខិតបទដ្ឋានគតិយុត្តថ្នាក់អន្តរជាតិ

-ក្រមព្រហ្មទណ្ឌ ប្រទេសបារាំង

-ច្បាប់ពាណិជ្ជកម្ម ប្រទេសបារាំង

## ឯកសារដែលចងក្រងជាសៀវភៅ និងឯកសារសិក្សាផ្សេងៗ

-សៀវភៅនីតិព្រហ្មទណ្ឌពិសេស រៀបរៀងដោយ កៅ សីហា ឆ្នាំ២០១៤ ស្នាដៃទី៧

-សៀវភៅនីតិព្រហ្មទណ្ឌថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ (ឯកត្តម ហ៊ី សោភា)

-សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត) ឆ្នាំ ២០១២

-សៀវភៅព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ាង ឡេង

-វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត របស់វិទ្យាស្ថានសាសនបណ្ឌិត ឆ្នាំ២០០៩

-សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង របស់ទីស្ដីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ ២០១១

**ប្រព័ន្ធផ្សព្វផ្សាយ ឬគេហទំព័រផ្សេងៗ**

-www.khmer.rfi.com

-www.cen.com.kh

-www.everyday.com.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>តាងនាមប្រជារាស្ត្រខ្មែរ</u>**
**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ
លេខ: **១៧៩២**
ចុះថ្ងៃទី២២-០៥-២០១៥
-ជំនុំជម្រះលេខ១៨៨៣
ចុះថ្ងៃទី៣០-០៧-២០១៥
-សាលក្រមព្រហ្មទណ្ឌ
លេខ:......" **ឆ** " **ភ.ព.ព្រ.ទ**
ចុះថ្ងៃទី......-.......-២០១៥

បានបើកសវនាការជាសាធារណៈនាថ្ងៃទី**២០ ខែសីហា ឆ្នាំ២០១៥** វេលាម៉ោង **ដប់បួន និងសាមសិបនាទីរសៀល** ដោយមានសមាសភាពដូចតទៅ:

**<u>ចៅក្រមជំនុំជម្រះ</u>**

-លោក (**ក**) អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**<u>តំណាងអយ្យការ</u>**

-លោកស្រី (**ខ**) ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោកស្រី (**គ**) ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ**១៧៩២ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥** ដែលមាន:

-ជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិទួលកី សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះគ្មានលេខ ផ្លូវលេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ស៊ឹម សុភាព** "រ" ម្ដាយឈ្មោះ **កង សោភា** "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥**

ឃុំខ្លួនតាមដីកាលេខ**១៣១៩ ត.ព្រ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥**

ជាប់ចោទពីបទ **លួច** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៩ ផ្លូវលេខ២៣០ ក្រុមទី១៧ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥** បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៦** ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **ម៉ម ម៉ាណែត** ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-បានឃើញរបាយការណ៍សំយោគលេខ**៨៦ រ.ប.ក** ចុះថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥** របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ**១១៧៦ អ.យ.ដ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ**១៥៩៣ អ.យ.ដ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៥** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្ដោះអាសន្នលេខ**៣១៩៧ ដ.ជ.រ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥** របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាដំណោះស្រាយលេខ**៣១៩៦ ដ.ជ.រ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥** របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងនេះមានដូចតទៅ

កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល១១ព្រឹក** ជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** បានទៅលេងអ៊ីនធើណែតនៅ**ហាង៨៨៨ណែត** ស្ថិតនៅផ្ទះលេខ៥៩ ផ្លូវលេខ២៣០ ក្រុមទី១៧ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដោយមានឱកាសល្អ គ្មាននរណាផ្សេងក្រៅពីជនរងគ្រោះឈ្មោះ **ម៉ម ម៉ាណែត** ដែលកំពុងតែមើលរឿងភាគថៃ ស្រាប់តែជនជាប់ចោទបានលួចយកទូរស័ព្ទចំនួន០២គ្រឿង និងសោរម៉ូតូរបស់ជនរងគ្រោះ តែត្រូវជនរងគ្រោះឃើញ ហើយស្រែកថា ចោរៗ ក៏បង្កឱ្យមានការប្រតាយប្រតប់គ្នា ទើបបណ្ដាលឱ្យជនរងគ្រោះដួលប៉ះនឹងតុចំច្រមុះ បន្ទាប់មកជនជាប់ចោទបានរត់ចេញទៅក្រៅ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** បានឆ្លើយថា: កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥** វេលាម៉ោងប្រហែល១០ព្រឹក ខ្លួនបានជិះម៉ូតូឌុបចេញពីផ្ទះទៅលេងអ៊ីនធើណែត **ឃីហោ ៨៨៨** នៅម្ដុំសង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ពេលទៅដល់ទីនោះ ខ្លួនបានទិញគណនីចំនួន ១ ដុល្លារអាមេរិក (មួយដុល្លារអាមេរិក) ពីបុគ្គលិកឈ្មោះ **ម៉ម ម៉ាណែត** ដើម្បីលេងអ៊ីនធើណែតចាក់បាល់ ពេលខ្លួនកំពុងលេងអ៊ីនធើណែតបានប្រហែល៣០នាទី ដោយពុំមានអ្នកផ្សេង គឺមានតែបុគ្គលិកឈ្មោះ **ម៉ម ម៉ាណែត** អង្គុយនៅកន្លែងគិតប្រាក់តែម្នាក់ឯង ហើយថែមទាំងមានទូរស័ព្ទ០២គ្រឿងទៀតនៅលើតុ ខ្លួនឃើញដូច្នេះ ក៏ដើរចូលទៅយកទូរស័ព្ទទាំង០២គ្រឿងនោះ បន្ទាប់មកក៏មានការប្រតាយប្រតប់គ្នាធ្វើឱ្យបុគ្គលិកឈ្មោះ **ម៉ម ម៉ាណែត** ដួលត្រូវនឹងតុចំច្រមុះ នៅពេលនោះមានមនុស្សស្រីម្នាក់ទៀត បានដើរចូលមកហើយបានស្រែកថា ចោរៗ ដោយខ្លួនភ័យពេកក៏រត់ចេញមកក្រៅ ស្រាប់តែត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្ដង។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **ម៉ម ម៉ាណែត** បានឆ្លើយថា: កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង១១ព្រឹក** ខ្លួនកំពុងធ្វើការនៅហាង៨៨៨ណែត ពេលនោះជនជាប់ចោទបានចូលទៅលេងណែតតែម្នាក់ឯង ក៏ទិញគណនីចំនួន០១ដុល្លារអាមេរិក ហើយបានអង្គុយលេងណែត ចំណែកខ្លួនកំពុងតែមើលរឿងភាគថៃ ពេលនោះជនជាប់ចោទបានបន្លំលួចយកទូរស័ព្ទចំនួន០២គ្រឿង និងសោរម៉ូតូរបស់ខ្លួន តែខ្លួនបានឃើញ ហើយបានស្រែកថា ចោរៗ ហើយជនជាប់ចោទបានរត់ចេញទៅក្រៅ ស្រាប់តែពេលនោះមិត្តភក្តិរបស់ខ្លួនក៏ចូលមកដល់ ហើយជួយស្រែកថា ចោរៗ ពេលដែលជនជាប់ចោទរត់ចេញទៅដល់ក្រៅ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ នៅពេលនេះ ខ្លួនបានទទួលទូរស័ព្ទទាំងពីរគ្រឿង និងសោរម៉ូតូវិញហើយ។ ចំពោះចម្លើយដែលថា ជនជាប់ចោទបានប្រើហិង្សាមកលើខ្លួនគឺពុំមានទេ ជនជាប់ចោទគ្រាន់តែយកទូរស័ព្ទ ហើយរត់ចេញទៅក្រៅតែប៉ុណ្ណោះ។ នៅពេលនេះ ខ្លួនសុំដកពាក្យបណ្ដឹង មិនទាមទារអ្វីទេ ព្រោះខ្លួនមិនបានខាតបង់ទ្រព្យសម្បត្តិអ្វីឡើយ។

-សាក្សីឈ្មោះ **សរ ហត្ថារី** បានឆ្លើយថា: កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល១០ព្រឹក** ខ្លួននៅកន្លែងធ្វើការជាមួយឈ្មោះ **ម៉ម ម៉ាណែត** ក្រោយមកខ្លួនបានចេញទៅក្រៅដើម្បីទិញអីញ៉ាំ។ ពេលខ្លួនត្រឡប់ចូលក្នុងហាង៨៨៨ វិញ ក៏បានឃើញឈ្មោះ **ម៉ម ម៉ាណែត** ដួលនៅលើតុ ហើយជនជាប់ចោទបានរត់ទៅក្រៅ ខ្លួនឃើញដូចនេះ ភ័យពេកក៏ស្រែកថា ចោរៗ ពេលជនជាប់ចោទរត់ទៅដល់ខាងក្រៅក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា:

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** ថា:

## សំអាងហេតុ

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្ដុតាងចប់សព្វគ្រប់

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ឃើញថា:

១-កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល១០ព្រឹក** ស្ថិតនៅចំណុចផ្ទះលេខ៥៩ ផ្លូវលេខ២៣០ ក្រុមទី១៧ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានករណី **លួចទូរស័ព្ទ និងសោរម៉ូតូ** ពិតប្រាកដមែន ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** ភេទប្រុស អាយុ២៨ឆ្នាំ ។

២-ជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ជាសមត្ថជន និងជាជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវតាមផ្លូវច្បាប់។

៣-ផ្អែកតាមការបញ្ជាក់របស់ជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** បានឆ្លើយសារភាពគ្រប់ដំណាក់កាលនីតិវិធីប្រហាក់ប្រហែលគ្នាថា: កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល១០ព្រឹក** ក្នុងហាង៨៨៨ ស្ថិតនៅចំណុចផ្ទះលេខ៥៩ ផ្លូវលេខ២៣០ ក្រុមទី១៧ ភូមិ៧ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ខ្លួនបានលួចយកទូរស័ព្ទ០២គ្រឿង និងសោរម៉ូតូរបស់ជនរងគ្រោះឈ្មោះ **ម៉ម ម៉ាណែត** តែត្រូវជនរងគ្រោះឃើញ ហើយស្រែកថា ចោរៗ ពេល នោះដោយខ្លួនភ័យពេក ក៏រត់ចេញទៅក្រៅហាង៨៨៨ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្ដង។

៤-ផ្អែកតាមការបញ្ជាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **ម៉ម ម៉ាណែត** បញ្ជាក់ថា: កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល១១ព្រឹក** ជនជាប់ចោទឈ្មោះ **ស៊ឹម ខេនឌី** បានមកលេងអ៊ីនធើណែតក្នុង**ហាង៨៨៨** ដោយទិញគណនីចំនួន០១ ដុល្លារអាមេរិក (មួយដុល្លារអាមេរិក) រួចអង្គុយលេងតែម្នាក់ឯង បានប្រហែលជា៣០នាទី ជនជាប់ចោទបានលួចយកទូរស័ព្ទ០២គ្រឿង និងសោរម៉ូតូរបស់ខ្លួន តែត្រូវខ្លួនឃើញ ហើយស្រែកថា ចោរៗ ភ្លាមនោះឈ្មោះ **សរ ហត្ថារី** បានចូលមក ហើយជួយស្រែកថា ចោរៗ ពេលនោះជនជាប់ចោទរត់ចេញទៅក្រៅ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

៥-ផ្អែកតាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ **សរ ហត្ថារី** បញ្ជាក់ថា: កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល១០ព្រឹក** ខ្លួននៅហាង៨៨៨ណែតជាមួយឈ្មោះ **ម៉ម ម៉ាណែត** ក្រោយមកខ្លួនបានចេញទៅទិញអីញុំា ពេលខ្លួនត្រឡប់មកវិញ ក៏ឃើញឈ្មោះ **ម៉ម ម៉ាណែត** ដួលនៅលើឥដ្ឋ ហើយបានឃើញជនជាប់ចោទកំពុងរត់ចេញទៅក្រៅហាង ដោយខ្លួនភ័យពេកក៏ស្រែកថា ចោរៗ ហើយពេលជនជាប់ចោទរត់ចេញទៅខាងក្រៅហាង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

៦-តាមចម្លើយសារភាពរបស់ជនជាប់ចោទ, ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយសាក្សីមានលក្ខណៈស៊ីសង្វាក់នឹងគ្នា អាចបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

៧-អំពើប្រព្រឹត្តរបស់ឈ្មោះ **ស៊ឹម ខេនឌី** ជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ស៊ឹម ខេនឌី** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ពីបទ **លួច** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៩ ផ្លូវលេខ២៣០ ក្រុមទី១៧ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៦** ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៩-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ម៉ម ម៉ាណែត** បានទទួលទូរស័ព្ទ០២គ្រឿង និងសោរម៉ូតូវិញហើយ និងបានដកពាក្យបណ្តឹង ពុំប្តឹងទាមទារសំណងពីជនជាប់ចោទឈ្មោះ **ស៊ឹម ខេមឌី** ទេ តុលាការពុំគប្បីពិចារណាលើសំណងនេះឡើយ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

-ផ្តន្ទាទោសលើឈ្មោះ **ស៊ឹម ខេមឌី** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់............................................................................................................ ពីបទ **លួច** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៩ ផ្លូវលេខ២៣០ ក្រុមទី១៧ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី**២១ ខែឧសភា ឆ្នាំ២០១៥** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៦** ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី**២០ ខែសីហា ឆ្នាំ២០១៥** ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: **អ៊ូ គារ៉ាន់** ហត្ថលេខា និងត្រា: **កោ ចណ្ធី**

-----------------------------------------------------------------------------------

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

បានឃើញ រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥

**ចៅក្រមជំនុំជម្រះ** **ក្រឡាបញ្ជី**

១០-ជនជាប់ចោទឈ្មោះ **IORDACHE CRISTIAN** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិរ៉ូម៉ានី និងឈ្មោះ **FLOREA TRAIN DANIEL** ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិរ៉ូម៉ានី តុលាការគប្បីផ្តន្ទាទោស ជនជាប់ចោទទាំងពីរ ដោយដាក់ពន្ធនាគារ និងទោសពិន័យ ដោយផ្អែកតាមមាត្រា៩៧ ក្រមព្រហ្មទណ្ឌ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ
លេខៈ **៧១៧**
ចុះថ្ងៃទី០៦-០៣-២០១៤
-ជំនុំជម្រះ
លេខ ១២៦២
ចុះថ្ងៃទី០៥-០៦-២០១៤
-សាលក្រមព្រហ្មទណ្ឌ
លេខៈ**១៣៤ "ក្រ៥ល" ភ.ព.ព្រ.ទ**
ចុះថ្ងៃទី២៨-០៨-២០១៤

បានបើកសវនាការជាសាធារណៈនាថ្ងៃទី**១២ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ០៨ : ៣០ នាទីព្រឹក** ដោយមានសមាសភាពដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក (**ក**) អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ(ប្រធានក្រុមប្រឹក្សា)
-លោក (**ខ**) ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ(ចៅក្រមប្រឹក្សា)
-លោក (**គ**) ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ(ចៅក្រមប្រឹក្សា)

**តំណាងអយ្យការ**

-លោក (**ឃ**) ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី (**ង**) ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ**៧១៧ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤**ដែលមានៈ

១-ជនជាប់ចោទឈ្មោះ **ថេង សុខហ៊ិន** ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរបើករថយន្ត ទីកន្លែងកំណើតនៅផ្ទះលេខ៦៣E₂ ផ្លូវលេខ១២៨ សង្កាត់មនោរម្យ ខណ្ឌ៧មករា ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៦៣E₂ ផ្លូវលេខ១២៨ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ **ថេង ប៊ុង** "រ" ម្តាយឈ្មោះ **ហេង តៀង** "រ" ប្រពន្ធឈ្មោះ **ហេង សុជា** មានកូន០១នាក់ ធ្លាប់ជាប់ពន្ធនាគាររយៈពេល១ឆ្នាំ ជានីតិជន ។

ឃាត់ខ្លួនថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤

ឃុំខ្លួនតាមដីកាលេខ៤៤៥ តព្រ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤

ដោយមានកញ្ញា **ឯក មាលា** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

២-ជនជាប់ចោទឈ្មោះ **ឆៃ វន្ត** ហៅ **អូន** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកហៅភ្ញៀវនៅក្នុងហាងសែនអាល័យ ទីកន្លែងកំណើតស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ននៅខារ៉ាអូខេសែនអាល័យ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ **វី** "ស" ម្តាយឈ្មោះ **ឆៃរ៉ុន** "រ" ប្រពន្ធឈ្មោះ **រស់ ចាន់ទី** "រ" ទោសពីមុនគ្មាន ជានីតិជន។

ឃាត់ខ្លួនថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤

ឃុំខ្លួនតាមដីកាលេខ៤៤៦ តព្រ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤

ដោយមានកញ្ញា **ឯក មាលា** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

៣-ជនជាប់ចោទឈ្មោះ **សុខ កាម** ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើតនៅសង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះគ្មានលេខ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ **សុខ វ៉ាត** "រ" ម្តាយឈ្មោះ **សុខ ថា** "រ" ប្រពន្ធឈ្មោះ **ជា រដ្ឋា** "រ" ទោសពីមុនគ្មាន ជានីតិជន ។

ឃាត់ខ្លួនថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤

ឃុំខ្លួនតាមដីកាលេខ៤៤៧ តព្រ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤

ដោយមានកញ្ញា **ឯក មាលា** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិភូមិភ្នាត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី**០៤ ខែមីនា ឆ្នាំ២០១៤** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិតមាត្រា**៣៥៣** និងមាត្រា**៣៥៧**ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **រឿន សុធារ័ត្ន** ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះជួលផ្លូវលំ ក្រុម៥ ភូមិភ្នាត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គី ចន្ថា** ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះជួលផ្លូវលំ ភូមិភ្នាត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គង់ សុខរី** ភេទស្រី អាយុ២៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះជួលផ្លូវលំ ភូមិភ្នាត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-បានឃើញរបាយការណ៍សំយោគលេខ**០២៦/២០១៤ រ.ប.ក** ចុះថ្ងៃទី**០៥ ខែមីនា ឆ្នាំ២០១៤** របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ**៤២៧ អ.យ.ឃ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ**១១២០ អ.យ.ណ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ**១៨១៩ ដ.ជ.រ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤**។

-បានឃើញដីកាសម្រេចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ**១៨២០ ដ.ជ.រ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤**។

-បានឃើញដីកាសម្រេចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ**១៨២១ ដ.ជ.រ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤**។

-បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ**១៨២២ ដ.ជ.រ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤** របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងនេះមានដូចតទៅ

កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង **០២ និង ៣០** នាទីរំលងអាធ្រាត្រ កម្លាំងនគរបាលប៉ុស្តិ៍ស្ទឹងមានជ័យ បានធ្វើការល្បាតក្នុងភូមិសាស្ត្រសង្កាត់ស្ទឹងមានជ័យ ពេលមកដល់ចំណុចផ្លូវបេតុង ភូមិទ្រា៤ ក៏ប្រទះឃើញជនសង្ស័យ០៤នាក់ ក្នុងនោះឈ្មោះ **ថេង សុខហ៊ុន** ជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរី២០០៥ ពាក់ផ្លាកលេខកំពង់ចាម **1D ៩៤៦៩** ឈ្មោះ **សុខ កាម** និងឈ្មោះ **ផៃ វ័ន្ត** ហៅ **អូន** ជិះម៉ូតូម៉ាកស្មាសវី ពណ៌ខ្មៅ គ្មានផ្លាកលេខ និងជនសង្ស័យម្នាក់ទៀត មិនស្គាល់ឈ្មោះ ជិះម៉ូតូម៉ាកអាយខន ពណ៌លឿង ពាក់ផ្លាកលេខ **ភ្នំពេញ 1AG ៤៨៤៩** ជិះមុខក្រោយបន្តបន្ទាប់គ្នា ដោយមានការសង្ស័យកម្លាំងល្បាតបានហៅដើម្បីត្រួតពិនិត្យ ស្រាប់តែជនសង្ស័យម្នាក់មិនស្គាល់ឈ្មោះ ដែលជិះម៉ូតូម៉ាកអាយខនពណ៌លឿង បានផ្តួលម៉ូតូចោលរួចរត់គេចខ្លួនបាត់ ខណៈនោះកម្លាំងនគរបាលបានឃាត់ខ្លួនជនសង្ស័យទាំងបីនាក់ (**ថេង សុខហ៊ុន, សុខ កាម និងផៃ វ័ន្ត**) យកមកសាកសួរ ហើយកម្លាំងនគរបាលបានរកឃើញម៉ូតូ០១គ្រឿងទៀតម៉ាកណិច ពណ៌សលាយផ្កាឈូក ពាក់ផ្លាកលេខ**ភ្នំពេញ 1CB ១៦៣៦** ដែល

ត្រូវបានផ្តួងចោល នៅភូមិភ្នាត សង្កាត់ស្ទឹងមានជ័យ។ លុះមកដល់វេលាម៉ោង **០៧** ថ្ងៃខែឆ្នាំដដែល ស្រាប់តែមានជនរងគ្រោះ៣នាក់: ឈ្មោះ **រឿន សុធារ័ត្ន** (ម្ចាស់ម៉ូតូសេ១២៥ ពណ៌ខ្មៅ), ឈ្មោះ **គង់ សុខរី** (ម្ចាស់ម៉ូតូណិច), និងឈ្មោះ **គី ចន្ថា** (ម្ចាស់ម៉ូតូអាយខន) បានមកដាក់ពាក្យបណ្តឹង និងអះអាងថា ម៉ូតូដែលសមត្ថកិច្ចដកហូតបាននេះ ជាម៉ូតូដែលជនជាប់ចោទគាស់សោរបន្ទប់ឃ្លាំងលួចយកកាលពីយប់ថ្ងៃទី០៤ **ខែមីនា ឆ្នាំ២០១៤** នៅចំណុចផ្ទះជួល ភូមិភ្នាត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ **ថេង សុខហ៊ុន** បានឆ្លើយថា: កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង០១ រំលងអាធ្រាត្រ ខ្លួនបានដើរចេញពីក្លឹបលេហ្សីមកដល់របងវត្តស្ទឹងមានជ័យ ប្រទះឃើញម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរី២០០៥ ដួលក្បែររបងវត្ត ភ្លើងកុងតាក់ភ្លឺ តែគ្មានកូនសោរ ខ្លួនក៏លើកយកម៉ូតូនោះជិះមកដល់ភូមិទ្រា៤ ជួបម៉ូតូពីរគ្រឿងម៉ាកស្មាសរី ពណ៌ខ្មៅ ជិះគ្នា០២នាក់ និងម៉ាកអាយខន ពណ៌លឿង ជិះម្នាក់ឯង ក្នុងពេលនោះសមត្ថកិច្ចមកដល់ អ្នកជិះម៉ូតូអាយខន បានផ្តួលម៉ូតូ ហើយរត់គេចខ្លួនបាត់ ខណៈនោះសមត្ថកិច្ចក៏បានឃាត់ខ្លួន និងអ្នកជិះម៉ូតូម៉ាកស្មាសរីយកមកសាកសួរតែម្តង។ ខ្លួនមិនស្គាល់ឈ្មោះ **សុខ កាម** និងឈ្មោះ **ឆៃ វ័ន្ត** ទេ។ ខ្លួនមានបំណងយកម៉ូតូគេ ដែលទុកចោលប៉ុណ្ណោះ ។

-ជនជាប់ចោទឈ្មោះ **សុខ កាម** បានឆ្លើយថា: កាលពីថ្ងៃទី**០៣ ខែមីនា ឆ្នាំ២០១៤** វេលាម៉ោងប្រហែល២៣ រំលងអាធ្រាត្រ រូបខ្លួនកំពុងនៅផ្ទះ ស្រាប់តែពេលនោះឈ្មោះ **ឆៃ វ័ន្ត** ហៅ **អូន** ភេទប្រុស អាយុ១៨ឆ្នាំ បានទូរស័ព្ទមកខ្លួន ហើយនិយាយថា ឲ្យខ្លួនមកឌុបវាពីកន្លែងលក់នំប៉័ងនៅសង្កាត់ស្ទឹងមានជ័យ។ មួយសន្ទុះក្រោយមកខ្លួនបានជិះម៉ូតូម៉ាកស្មាសរី ពណ៌ខ្មៅ ស៊េរី២០១៤ គ្មានផ្លាកលេខ មកជួបឈ្មោះ **ឆៃ វ័ន្ត** ហៅ **អូន** កន្លែងលក់នំប៉័ង ក្រោយពីហូបនំប៉័ងហើយ ខ្លួនឌុបឈ្មោះ **ឆៃ វ័ន្ត** ហៅ **អូន** ទៅផ្ទះរបស់វានៅម្តុំពោធិ៍ចិនតុង ពេលជិះបានពាក់កណ្តាលផ្លូវ ស្រាប់តែឃើញម៉ូតូពីរគ្រឿងម៉ាកអាយខន ពណ៌លឿងមួយគ្រឿង ជិះម្នាក់ឯង និងមួយគ្រឿងទៀតម៉ាកសេ១២៥ ពណ៌ខ្មៅជិះម្នាក់ឯង ។ ម៉ូតូពីរគ្រឿងនេះជិះពីក្រោយខ្លួន ពេលនោះខ្លួនបានបង្អង់ម៉ូតូ ឲ្យម៉ូតូទាំងពីរគ្រឿងនេះជិះទៅមុខខ្លួន ពេលខ្លួនជិះម៉ូតូបានបន្តិចទៀត ក៏ត្រូវសមត្ថកិច្ចហៅ ពេលនោះម្ចាស់ម៉ូតូអាយខនពណ៌លឿង បានផ្តួលម៉ូតូចោលរត់គេចខ្លួន ចំណែកខ្លួន និងម្ចាស់ម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ត្រូវសមត្ថកិច្ចឃាត់ខ្លួនយកមកប៉ុស្តិ៍នគរបាលស្ទឹងមានជ័យធ្វើការសាកសួរតែម្តង។ ម៉ូតូនេះជារបស់អ៊ុំខ្លួនទិញឲ្យជិះប្រហែល៥ខែ តែមិនទាន់ធ្វើផ្លាកលេខ មានតែសំបុត្រពន្ធ ។

-ជនជាប់ចោទឈ្មោះ **ឆៃ វ័ន្ត** ហៅ **អូន** បានឆ្លើយថា: កាលពីថ្ងៃទី**០៣ ខែមីនា ឆ្នាំ២០១៤** ខ្លួនបានជិះម៉ូតូឌុបចេញពីផ្ទះរបស់ខ្លួននៅសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ មកលេងអ្នកស្គាល់គ្នានៅម្តុំក្លឹបលេហ្សី នៅសង្កាត់ស្ទឹងមានជ័យ លុះមកដល់ម៉ោងជាងមួយរំលងអាធ្រាត្រ ឆ្លងចូលថ្ងៃ**ទី០៤ ខែមីនា ឆ្នាំ២០១៤** ខ្លួនត្រូវត្រឡប់ទៅផ្ទះវិញ ហើយហៅម៉ូតូឌុបជិះតែគេមិនព្រមឌុប ខ្លួនក៏ទូរស័ព្ទហៅបងធម៌ឈ្មោះ **សុខ កាម** ភេទប្រុស អាយុប្រហែលជា២០ឆ្នាំ ពេលឈ្មោះ **សុខ កាម** មកដល់ក៏បានជិះម៉ូតូមួយគ្រឿងម៉ាកស្មាសរី ពណ៌ខ្មៅ គ្មានផ្លាកលេខ មកឌុបខ្លួន ចេញទៅដល់ចំណុចភូមិទ្រា ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនយកមកសាកសួរតែម្តង។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **រឿន សុធារ័ត្ន** ថា: មុនពេលកើតហេតុ ខ្លួនបានចេញពីធ្វើការត្រឡប់មកផ្ទះជួលខាងលើ នៅវេលាម៉ោង ដប់ប្រាំបីយប់ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ហើយខ្លួនបានយកម៉ូតូម៉ាកសង់ស៊េរីឆ្នាំ២០០៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ

កំពង់ចាម ១D ៩៤៦៩ លេខម៉ាស៊ីន ៨១០៤០៥៧ លេខតួ ៨១០៤០៥៧ មកទុកក្នុងឃ្លាំង (ក្នុងបរិវេណផ្ទះជួល) ភូមិត្នោត សង្កាត់ស្ទឹងមានជ័យ ហើយចាក់សោរក, ចាក់សោរកងខាងមុខ និងចាក់សោរស្វឡិចទ្វារឃ្លាំង បន្ទាប់មកខ្លួនក៏ដើរចូលផ្ទះសំរាក លុះព្រឹកឡើង ម៉ោងប្រាំមួយ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤ ខ្លួនចេញពីផ្ទះដើរមកយកម៉ូតូស្រាប់តែបាត់តែម្តង រួចខ្លួនក៏មកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលស្ទឹងមានជ័យ ស្រាប់តែឃើញម៉ូតូខ្លួន និងជនជាប់ចោទមួយចំនួននៅប៉ុស្តិ៍ស្ទឹងមានជ័យតែម្តង។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គី ចន្ថា** ថា: កាលពីវេលាម៉ោងប្រហែលម្ភៃយប់ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ខ្លួនបានជិះម៉ូតូរបស់ខ្លួនម៉ាកអាយខន ស៊េរី២០០៩ ពណ៌លឿង ផ្លាកលេខ ភ្នំពេញ ១AG ៩៨៩៩ លេខតួ៨០០៩៨២ លេខម៉ាស៊ីន៨០០៩៨២ ចេញពីកន្លែងធ្វើការងារ ត្រឡប់មកផ្ទះវិញ ក៏យកម៉ូតូមកទុកនៅក្នុងបន្ទប់ជំហៀងផ្ទះ ចាក់សោរក, សោរជញ្ជាំល ហើយបិទទ្វារចាក់សោរស្វឡិច បន្ទាប់មកឡើងទៅលើផ្ទះជាន់ទី២គេង លុះគេងរហូតដល់ម៉ោងប្រហែលប្រាំមួយព្រឹកថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤ ពេលដែលខ្លួនបានចុះពីលើផ្ទះមកក្រោមបំរុងយកម៉ូតូទៅធ្វើការ ស្រាប់តែឃើញទ្វារបន្ទប់ចំហរ បាត់ម៉ូតូនៅក្នុងបន្ទប់ ក្រោយមកខ្លួនបានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងមានជ័យ ស្រាប់តែឃើញម៉ូតូរបស់ខ្លួននៅក្នុងប៉ុស្តិ៍ជាមួយជនជាប់ចោទ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គង់ សុខរី** ថា: កាលពីវេលាម៉ោងប្រហែល ១៨ និង ៣០ នាទី ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ខ្លួនបានជិះម៉ូតូម៉ាក SUZUKI NEX១១០ ស៊េរី២០១៤ ពណ៌លឿងខ្ចី លេខម៉ាស៊ីន៣០១១០៧ លេខតួ៣០១១០៦ ចេញពីកន្លែងធ្វើការ ត្រឡប់មកផ្ទះវិញ ក៏យកម៉ូតូមកទុកនៅក្នុងបន្ទប់ចាក់សោរក ចាក់សោរច្រវ៉ាក់ រួចទាញទ្វារបិទចាក់សោរស្វឡិច បន្ទាប់មកដើរឡើងទៅលើផ្ទះជាន់ទី២គេង លុះដល់ម៉ោងប្រហែល ០៦ ព្រឹកថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤ ខ្លួនបានចុះពីលើផ្ទះមកក្រោម ស្រាប់តែឃើញទ្វារបន្ទប់ចំហរ ហើយបាត់ម៉ូតូ ក្រោយមកខ្លួនបានដាក់ពាក្យបណ្តឹងទៅប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងមានជ័យ ស្រាប់តែឃើញម៉ូតូនៅក្នុងប៉ុស្តិ៍ជាមួយជនជាប់ចោទ។

-សាក្សីឈ្មោះ **សុខ ផល** បានធ្វើការបំភ្លឺថា: ឈ្មោះ **សុខ កាម** ត្រូវជាក្មួយរស់នៅជាមួយខ្លួន ដោយហេតុថា ឈ្មោះ **សុខ កាម** ពុំមានឪពុកម្តាយ។ ម៉ូតូនេះខ្លួនពិតជាបានទិញឲ្យឈ្មោះ **សុខ កាម** ជិះប្រាកដមែន ដូចមានកិច្ចសន្យា និងសំបុត្រពន្ធដាក់ជូនតុលាការ ហើយម៉ូតូនេះមិនទាន់បានធ្វើផ្លាកលេខនៅឡើយទេ។

-តាមរបាយការណ៍សំយោគរបស់សមត្ថកិច្ច បានបញ្ជាក់ថា: ម៉ូតូដែលបានចាប់យកនៅថ្ងៃកើតហេតុមាន៤គ្រឿង ហើយដើមបណ្តឹង៣នាក់បានមកដាក់ពាក្យបណ្តឹងយកម៉ូតូទៅវិញអស់៣គ្រឿងហើយ ដោយមានការឯកភាពប្រគល់ម៉ូតូពីតំណាងអយ្យការដែរ។ នៅសល់ម៉ូតូ១គ្រឿងម៉ាកស្មាសវី ពណ៌ខ្មៅ បានបញ្ជូនមកតុលាការ ដែលតាមកំណត់ហេតុដកហូតពីឈ្មោះ **សុខ កាម** មានលេខម៉ាស៊ីន E៤៨០, ១៣៣៨៤២ និងលេខតួ ១៣៣៨៤២។ លោក **សន ភឿន** ជានគរបាលប៉ុស្តិ៍រដ្ឋបាលស្ទឹងមានជ័យ បានបំភ្លឺថា នៅយប់កើតហេតុក្រុមខ្លួនបានចុះល្បាត បានជួបជនសង្ស័យ០៤រូបកំពុងជិះម៉ូតូ ហើយធ្វើការឃាត់ខ្លួនសាកសួរ ស្រាប់តែជនម្នាក់បានផ្តួលម៉ូតូរត់គេចខ្លួន ក៏បានឃាត់អ្នកទាំងបីនៅចំពោះមុខ មកប៉ុស្តិ៍រដ្ឋបាល។ ឈ្មោះ **សុខ កាម** គ្រាន់តែអះអាងថា ម៉ូតូនោះជារបស់ខ្លួន ប៉ុន្តែមិនបានដាក់ឯកសារបញ្ជាក់ពីកម្មសិទ្ធិរបស់ខ្លួនទេ។

-តាមលិខិតទិញលក់ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ មានឈ្មោះ **សុខ ផល** ជាអ្នកទិញម៉ូតូ

ម៉ាកស្មាសរី ដោយមានបង្កាន់ដៃពន្ធយានយន្តចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ តំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ **១១២០ អ.យ.ណ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤** និងស្នើសុំលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់ ។

-កញ្ញា **ឯក មាលា** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការ និងការពិនិត្យលើសំណុំឯកសារ ឃើញថានៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ កូនក្តីខ្លួនឈ្មោះ **ថៃ សុខហ៊ុន** បានអះអាងថា ការដែលសមត្ថកិច្ចចាប់ខ្លួននេះ ដោយមូលហេតុថាគាត់បានជិះម៉ូតូមួយគ្រឿង ដែលការសាកសួរទៅមានការសង្ស័យ ហើយកូនក្តីខ្លួនក៏បានទទួលស្គាល់ថាពិតជាបានយកម៉ូតូដែលគេទុកចោលយកទៅជិះ ប៉ុន្តែកូនក្តីខ្លួនមិនបានធ្វើការគាស់ទម្លុះទម្លាយផ្ទះរបស់ជនរងគ្រោះលួចម៉ូតូនោះទេ ដែលមានជនរងគ្រោះឈ្មោះ **រឿន សុធាវ័ត្ន** បានបាត់ម៉ូតូម៉ាក សេ១២៥ ស៊េរី២០០៥ កូនក្តីខ្លួនបានទទួលស្គាល់ពីកំហុសរបស់ខ្លួន ហេតុនេះខ្លួនសំណូមពរឲ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចកែប្រែបទចោទលើកូនក្តីខ្លួនឈ្មោះ **ថៃ សុខហ៊ុន** ពីមាត្រា៣៥៧ មកមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តតាមមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការព្យួរទោស ព្រមទាំងបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ព្រោះថេរវេលានៃការឃុំខ្លួនមានរយៈ៥ខែ ៥ថ្ងៃហើយ ចំពោះកូនក្តីខ្លួនឈ្មោះ **សុខ កាម** និងឈ្មោះ **ឆៃ វ័ន្ត** បានឆ្លើយបញ្ជាក់ថា ពួកគេបានចេញពីផ្ទះមែន ប៉ុន្តែគ្មានចេតនាទៅបបួលបក្ខពួក ទៅលួចទ្រព្យសម្បត្តិរបស់គេនោះទេ ហើយពេលដែលសមត្ថកិច្ចឃាត់ខ្លួនកូនក្តីខ្លួននោះ ដោយសារកូនក្តីខ្លួនជិះម៉ូតូអត់ពាក់ផ្លាកលេខ ដូច្នេះក្នុងរឿងនេះកូនក្តីខ្លួនបានឆ្លើយថាមិនដែលស្គាល់ គ្នាពីមុនមកទេ ហើយក៏មិនបានរួមគំនិតគ្នាដែរ ម្យ៉ាងទៀតជនរងគ្រោះទាំងបីនាក់បានអះអាងថា គាត់បានបាត់ម៉ូតូ ប៉ុន្តែមិនបានបញ្ជាក់ថាអ្នកណាជាអ្នកលួចម៉ូតូដែរ ហើយជនរងគ្រោះក៏បាន ទទួលម៉ូតូអស់ហើយដែរ ដូច្នេះកូនក្តីខ្លួនពិតជាមិនបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់របស់តំណាងអយ្យការទេ តាងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់ តាមមាត្រា៣៥០ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងសម្រេចកែប្រែបទចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ **ថេង សុខ ហ៊ុន** ព្រមទាំងដោះលែងកូនក្តីខ្លួនឈ្មោះ **សុខ កាម** និងឈ្មោះ **ឆៃវ័ន្ត** ឲ្យមានសេរីភាពវិញ ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ **ថេង សុខហ៊ុន** ថា: ខ្លួនស្នើសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ **សុខ កាម** ថា: ខ្លួនស្នើសុំឲ្យតុលាការលើកលែងចោទប្រកាន់ដល់ខ្លួនផង។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ **ឆៃ វ័ន្ត** ថា: ខ្លួនស្នើសុំឲ្យតុលាការលើកលែងចោទប្រកាន់ដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យឯកសារភស្តុតាងចប់សព្វគ្រប់
-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**

១-ជនជាប់ចោទឈ្មោះ **ថេង សុខហ៊ិន** បានសារភាពថា ខ្លួនបានប្រទះឃើញម៉ូតូមួយគ្រឿង នៅក្បែររបងវត្តស្ទឹងមានជ័យក៏មានចេតនាចង់យកម៉ូតូនោះ ប៉ុន្តែបានបដិសេធមិនបានចូលគាស់បន្ទប់យកម៉ូតូទេ។

២-តាមចម្លើយរបស់ជនរងគ្រោះទាំង៣រូប បានឆ្លើយប្រហាក់ប្រហែលគ្នាថា នៅព្រឹកក្រោយយប់កើតហេតុ ខ្លួនភ្ញាក់ពីគេងឃើញបន្ទប់ទុកម៉ូតូចំហរតែបាត់ម៉ូតូ ហើយទៅប្តឹងសមត្ថកិច្ចប៉ុស្តិ៍ ក៏ឃើញម៉ូតូខ្លួននៅទីនោះ ក៏បានដាក់ពាក្យបណ្តឹង និងសុំយកម៉ូតូមកប្រើប្រាស់វិញ។

៣-យប់កើតហេតុ សមត្ថកិច្ចបានឃាត់ខ្លួនជនទាំង៣រូប នៅកន្លែងតែមួយ ពេលកំពុងធ្វើដំណើរតាមផ្លូវវេលាម៉ោងជាង១រំលងអាធ្រាត្រ អាចកំណត់បានថា អ្នកទាំង៣ព្រមទាំងជនរត់គេចខ្លួនម្នាក់ទៀត គឺជាក្រុមជនល្មើសតែមួយ ដែលបានទៅគាស់បន្ទប់ដាក់ម៉ូតូយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះ។

៤-តាមការសំអាងហេតុទី១ ដល់ទី៣ ខាងលើអាចកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

៥អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិឯកជន ដែលក្រមព្រហ្មទណ្ឌកំណត់ថាជាបទល្មើសដែលត្រូវផ្តន្ទាទោស តាមមាត្រា៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦-ជនជាប់ចោទមានស្មារតីយល់ដឹង អាចពិចារណាបានអំពីសកម្មភាពប្រព្រឹត្តរបស់ខ្លួនត្រូវឲ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

៧-ជនរងគ្រោះបានទទួលយកម៉ូតូវិញហើយ តុលាការមិនពិចារណាចំណុចនេះទេ។

៨-ដោយសារម៉ូតូម៉ាក ស៊ុយស៊ុយគីស្មាសវី ជារបស់ឈ្មោះ **សុខ ផល** ដូចមានលិខិតទិញលក់ និងបង្កាន់ដៃពន្ធយានយន្តមានលេខតួ និងលេខម៉ាស៊ីនដូចគ្នា គប្បីប្រគល់ម៉ូតូឲ្យម្ចាស់ដើមវិញ។ ដោយឡែកសោរ និងសោរច្រវាក់ខូចដែលត្រូវរឹបអូស និងបំផ្លាញចោល។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសៈ

ក-ឈ្មោះ **ថេង សុខហ៊ិន** ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ **សុខ កាម** ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ

គ-ឈ្មោះ **ផៃ វន្តៃ** ហៅ **អូន** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៤ឆ្នាំ (បួន) ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិភ្នាត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី**០៤ ខែ**

**មីនា ឆ្នាំ២០១៤** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុចាប់យករួមមាន:

ក-ម៉ូតូម៉ាកស្មាសវី ពណ៌ខ្មៅ គ្មានផ្លាកលេខ គ្មានកុងទ័រ ចំនួន១គ្រឿង ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ។

ខ-សោរចំនួន០៣ (ខូចទាំងអស់)។

គ-សោរច្រវ៉ាក់០៣។

ត្រូវរឹបអូសតាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី**១២ ខែសីហា ឆ្នាំ២០១៤** ចំពោះមុខជនជាប់ចោទឈ្មោះ **ថេង សុខហ៊ុន**, ឈ្មោះ **សុខ កាម**, ឈ្មោះ **ផៃ វ័ន្ត**, មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **រឿន សុធាវ័ត្ន**, ឈ្មោះ **គង់ សុខរី**, ឈ្មោះ **គី ចន្ថា** ប្រកាសជាសាធារណៈនៅ**ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤** បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈដែលច្បាប់កំណត់ ។

**ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ចៅក្រមជំនុំជម្រះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៧៧៧
ចុះថ្ងៃទី១០-០៩-២០១៣
-ជំនុំជម្រះលេខ ១១៥១
ចុះថ្ងៃទី២៦-០៥-២០១៤
-សាលក្រមព្រហ្មទណ្ឌ
លេខ:........ " ល " ភ.ព.ព្រ.ទ
ចុះថ្ងៃទី......-......-.........

បានបើកសវនាការជាសាធារណៈនាថ្ងៃទី**១៣ ខែវិច្ឆិកា ឆ្នាំ២០១៤** វេលាម៉ោង ដប់បួន រសៀល ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

-លោក (**ក**) ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក (**ខ**) ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី (**គ**) ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ**២៧៧៧ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣** ដែលមាន:

-ជនជាប់ចោទឈ្មោះ **លន់ គីមហុង** ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរជាងម៉ាស៊ីនត្រជាក់ ទីកន្លែងកំណើតនៅភូមិពោធិ៍២ ឃុំការ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នផ្ទះជួលលេខ៤៣៨ ផ្លូវលេខ១៦៣ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ **លន់សុខហ៊ួរ** " រ " ម្តាយឈ្មោះ **ចៃ ឡាំងអ៊ីម** " រ " ប្រពន្ធឈ្មោះ **ហ៊ុន ស្រីមុំ** ទោសពីមុនគ្មាន ជានីតិជន។ **(ក្រៅឃុំ)**

ដោយមានលោកស្រី **ម៉ុន វិមានចំប៉ា** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ជាប់ចោទពីបទ **កំហែងយក និងធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភោជនីយដ្ឋានប្រេ្គនយ៉ាម៉ាតុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៦៣, ៣៦៤ និង៤១០** នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គង់ សំរេច** ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ១ ផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ**២០៤៥ អ.យ.ញ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ**១០៦០ អ.យ.ជ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាបញ្ជូនរឿងអោយជំនុំជម្រះលេខ**១៦៨៤ ដ.ជ.រ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤** របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ឈ្មោះ **គង់ សំរេច** បានជួលជាងម៉ាស៊ីនត្រជាក់ឈ្មោះ **លន់ គីមហុង** មកតំឡើងម៉ាស៊ីនត្រជាក់ នៅក្នុងភោជនីយដ្ឋានប្រេ្គនយ៉ា

ម៉ាតុ ស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ពេលឈ្មោះ **លន់ គឹមហុង** ដំណើរការតំឡើងម៉ាស៊ីនត្រជាក់បានប្រមាណ ៥០% ហើយបានមកសុំឈ្មោះ **គង់ សំរេច** ទូទាត់ប្រាក់ទាំងអស់ ប៉ុន្តែឈ្មោះ **គង់ សំរេច** បានទូទាត់ប្រាក់ឲ្យតែចំនួន**១៥០០ ដុល្លារអាមេរិក (មួយពាន់ប្រាំរយ)** សល់ប្រាក់ចំនួន **៣៥៦ ដុល្លារអាមេរិក (បីរយហាប្រាំមួយ)** ទុកទូទាត់នៅពេលឈ្មោះ **លន់ គឹមហុង** ធ្វើការងារចប់ជាស្ថាពរ។ បន្ទាប់ពីឈ្មោះ **លន់ គឹមហុង** សុំទូទាត់ប្រាក់មិនបានទាំងអស់ ក៏បានទៅកាត់បំផ្លាញខ្សែភ្លើង រួចយកខ្សែភ្លើងទៅតភ្ជាប់ជាមួយខ្សែម៉ាស ក្នុងគោលបំណងធ្វើឲ្យទុសេឆេះភោជនីយដ្ឋានហ្រ្គេនយ៉ាម៉ាតុ។ មិនតែប៉ុណ្ណោះឈ្មោះ **លន់ គឹមហុង** បានគំរាមកំហែងឈ្មោះ **គង់ សំរេច** ប្រគល់ប្រាក់ចំនួន **១.០០០ ដុល្លារអាមេរិក (មួយពាន់)** បន្ថែមទៀត បើមិនព្រមប្រគល់ទេ ម៉ាស៊ីនត្រជាក់ទាំងអស់ គ្មានជាងណាអាចតំឡើងបន្តទៀតបានឡើយ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ **លន់ គឹមហុង** បានឆ្លើយថា: ខ្លួនជាជាងជួសជុលម៉ាស៊ីនត្រជាក់ធម្មតា ពុំមានក្រុមហ៊ុន ឬ ផ្លាកយីហោអ្វីទេ ក្នុងដើមឆ្នាំ២០១៣ មានមិត្តខ្លួនទាក់ទងមកថា មានគេចង់តំឡើងម៉ាស៊ីនត្រជាក់នៅភោជនីយដ្ឋានហ្រ្គេនយ៉ាម៉ាតុ រួចខ្លួនក៏ទៅជួបជាមួយឈ្មោះ **ធា** និងឈ្មោះ **គង់ សំរេច** ដោយចរចារក្នុងតំលៃតាមប្រភេទរបស់ម៉ាស៊ីនត្រជាក់ដូចជា Cassettes (២HP to ៣HP) តំលៃ**២៨ ដុល្លារអាមេរិក (ម្ភៃប្រាំបី)** ក្នុងមួយគ្រឿង ឯតំលៃជើងដែក, ជើងដែកចាប់មុខ, ប្តូរទីតាំង, បញ្ចូលហ្គាស និងទុយោស្ពាន់ ខ្លួនយកតែតំលៃឈ្នួល ឯសម្ភារៈរបស់ម្ចាស់ភោជនីយដ្ឋាន ក្រោយពីខ្លួនបានតំឡើងម៉ាស៊ីនត្រជាក់បាន៩០% ឈ្មោះ **គង់ សំរេច** បានទូទាត់ប្រាក់មកឲ្យខ្លួនចំនួន**១៥០០ ដុល្លារអាមេរិក (មួយពាន់ប្រាំរយ)** នៅខ្វះប្រាក់ប្រហែលជាចំនួន **៣០០ ដុល្លារអាមេរិក (បីរយ)** ជាង រងចាំខ្លួនតខ្សែភ្លើងបញ្ចូលឲ្យរួចរាល់ជាស្ថាពរ តែដោយពេលនោះម្ចាស់ភោជនីយដ្ឋានមិនទាន់តភ្លើងបញ្ចូល ហើយឲ្យខ្លួនផ្អាកការងារសិន ហើយខ្លួនរងចាំប្រហែលមួយខែ ទើបគេទាក់ទងខ្លួនឲ្យទៅតភ្លើងបញ្ចប់ ពេលទៅដល់ឈ្មោះ **គង់ សំរេច** បានឲ្យខ្លួនប្តូរទីតាំងម៉ាស៊ីនចំនួន២គ្រឿង ខ្លួនក៏យល់ព្រម ហើយក៏ទៅពិនិត្យឃើញ ខ្សែភ្លើងម៉ាស៊ីនត្រជាក់ត្រូវកាត់ផ្តាច់ខុសពីភាពដើមដែលខ្លួនតពីមុន ឃើញដូច្នេះក៏សុំសេវាកម្មបន្ថែម តែឈ្មោះ **គង់ សំរេច** មិនព្រម ហើយព្រមទាំងព្រមានប្តឹងរូបខ្លួនទៀតផង ចាប់ពីពេលនោះមកខ្លួន ក៏ផ្អាកទំនាក់ទំនងគ្នារហូត។ ខ្លួនពុំបានកាត់បំផ្លាញខ្សែភ្លើង ឬ សម្ភារៈម៉ាស៊ីនត្រជាក់ឡើយ ហើយក៏ពុំបានគំរាមកំហែងទារលុយដូចដែលឈ្មោះ **គង់ សំរេច** ប្តឹងនោះដែរ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គង់ សំរេច** បានឆ្លើយថា: កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣ ខ្លួនបានជួលជាងម៉ាស៊ីនត្រជាក់ឈ្មោះ **លន់ គឹមហុង** ដើម្បីតម្លើងម៉ាស៊ីនត្រជាក់នៅភោជនីយដ្ឋានហ្រ្គេនយ៉ាម៉ាតុ ដែលមានតំលៃពលកម្មចំនួន**១៨៥៦ ដុល្លារអាមេរិក (មួយពាន់ប្រាំបីរយហាសិបប្រាំមួយ)** នៅពេលឈ្មោះ **លន់ គឹមហុង** ដំណើរការតំឡើងម៉ាស៊ីនត្រជាក់បានប្រមាណ**៨៥%** ស្រាប់តែឈ្មោះ **លន់ គឹមហុង** បានមកសុំទូទាត់ប្រាក់ថ្លៃតំឡើងម៉ាស៊ីនត្រជាក់ទាំងអស់តែម្តង ប៉ុន្តែខ្លួនបានទូទាត់ឲ្យតែចំនួន**១៥០០ ដុល្លារអាមេរិក (មួយពាន់ប្រាំរយ)** ប៉ុណ្ណោះ នៅសល់ចំនួន៣៥៦ ដុល្លារអាមេរិក (បីរយហាសិបប្រាំមួយ) ទៀតទុកទូទាត់នៅពេលឈ្មោះ **លន់ គឹមហុង** តំឡើងម៉ាស៊ីនត្រជាក់ចប់**១០០% (មួយរយភាគរយ)**

នៅពេលឈ្មោះ **លន់ គឹមហុង** សុំទូទាត់ប្រាក់មិនបានគ្រប់ចំនួន គាត់ក៏បានសម្តែងអាកប្បកិរិយាខឹងខ្លួន ប៉ុន្តែដោយមានការសម្របសម្រួលឈ្មោះ **លន់ គឹមហុង** ក៏ចេញទៅបាត់ ហើយចាប់ពីថ្ងៃនោះមក ឈ្មោះ **លន់ គឹមហុង** បានមកភោជនីយដ្ឋានខ្លួនជាធម្មតា ប៉ុន្តែឈ្មោះ **លន់ គឹមហុង** មិនបានទៅធ្វើការងារបញ្ចប់នោះទេ ឈ្មោះ **លន់ គឹមហុង** បែរជាទៅកាត់បំផ្លាញខ្សែភ្លើង ហើយយកខ្សែភ្លើងទៅតភ្ជាប់ជាមួយនឹងខ្សែម៉ាស ក្នុងគោលបំណងធ្វើឲ្យទុសេឆេះភោជនីយដ្ឋានរបស់ខ្លួនតែម្តង ហើយឈ្មោះ **លន់ គឹមហុង** បានគេចខ្លួនមិនព្រមចូលធ្វើការបញ្ចប់នោះទេ ខ្លួនបានហៅឈ្មោះ **លន់ គឹមហុង** តាមរយៈទូរស័ព្ទ ឲ្យមកបន្តការងារ ស្រាប់តែឈ្មោះ **លន់ គឹមហុង** បានគំរាមកំហែងខ្លួនថា ប្រសិនបើមិនប្រគល់ប្រាក់ចំនួន**១000 ដុល្លារអាមេរិក (មួយពាន់)** បន្ថែមទៀតទេ ឈ្មោះ **លន់ គឹមហុង** នឹងមិនមកតំឡើងម៉ាស៊ីនត្រជាក់បន្តនោះទេ ហើយឈ្មោះ **លន់ គឹមហុង** បានបន្តទៀតថា ក្រៅពីខ្លួនគ្មានជាងណាអាចតំឡើងម៉ាស៊ីនត្រជាក់បានឡើយ ក្រោយពេលឈ្មោះ **លន់ គឹមហុង** បាននិយាយគំរាមបែបនេះហើយខ្លួនក៏មានការសង្ស័យ ហើយបានហៅជាងផ្សេងមកត្រួតពិនិត្យឃើញថា ខ្សែភ្លើងទាំងអស់ត្រូវបានឈ្មោះ **លន់ គឹមហុង** កាត់បំផ្លាញចោល ហើយយកខ្សែចរន្តភ្លើងទៅភ្ជាប់ជាមួយនឹងខ្សែចរន្តម៉ាស ដែលភ្លើងមានកម្លាំង ៣ ហ្វា និងកាត់បំផ្លាញផ្ទាំងបិតបញ្ជាគ្រប់ម៉ាស៊ីនត្រជាក់ក្នុងបំណងបំផ្លិចបំផ្លាញភោជនីយដ្ឋានរបស់ខ្លួនតែម្តង។ ខ្លួនសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារថ្លៃខូចខាតព្រមទាំងជម្ងឺចិត្តចំនួន**១០,000 ដុល្លារអាមេរិក (មួយម៉ឺន)**។

-សាក្សីឈ្មោះ **សុខ ស៊ុន** បានឆ្លើយថាៈ ក្នុងអំឡុងខែសីហា ឆ្នាំ២០១៣ ខ្លួនត្រូវបានម្ចាស់ភោជនីដ្ឋានប្រេ្តនយ៉ាម៉ាតុ ហៅឲ្យជួយពិនិត្យ និងជួសជុលម៉ាស៊ីនត្រជាក់បន្តពីជាងមុន នៅពេលខ្លួនចូលទៅត្រួតពិនិត្យឃើញថា ការតំឡើងម៉ាស៊ីនត្រជាក់របស់ជាងមុន គឺខុសបច្ចេកទេសទាំងស្រុង ព្រមទាំងមានការកាត់បំផ្លាញខ្សែភ្លើង ហើយចំពោះម៉ាស៊ីនត្រជាក់នីមួយៗ ដែលបានតំឡើងរួច ត្រូវបានជាងមុនបំផ្លាញតាមបិតបញ្ជាម៉ាស៊ីនត្រជាក់ទាំងអស់នោះដូចជាៈ កាត់យកខ្សែយ៉ូត, ដកចំរ៉ស់ភ្លើង, ដកខ្សែភ្ជាប់ភ្លើង និងបន្ថែមគ្រឿងឲ្យម៉ាស៊ីនត្រជាក់ឲ្យតំណើរការខុសពីធម្មតា ហើយជាងមុនបានតភ្ជាប់ខ្សែម៉ាស ជាមួយនឹងខ្សែចរន្តភ្លើងកម្លាំង៣ ហ្វា ទើបធ្វើឲ្យកម្លាំងភ្លើងខ្លាំងជាងមុន បើមានអ្នកណាបើកភ្លើងនឹងធ្វើឲ្យទុសេឆេះភោជនីយដ្ឋានតែម្តង និងកាត់បំផ្លាញខ្សែភ្លើងមួយទៀត ជាងមុនបានបំផ្លាញខ្សែប៉ាសេ ដែលតភ្ជាប់ពីក្បាលម៉ាស៊ីនត្រជាក់ នៅកន្ទុយម៉ាស៊ីនត្រជាក់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ

-លោកស្រី **ម៉ុន វិមានចំប៉ា** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថាៈ

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ **លឹម គឹមហុង** ថាៈ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ការបំភ្លឺរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងចប់សព្វគ្រប់

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>យល់ឃើញថា</u>**

១-ឈ្មោះ **លន់ គឹមហុង** ភេទប្រុស អាយុ៣១ឆ្នាំ ជាសមត្ថជន និងជាជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវតាមផ្លូវច្បាប់។

២-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **លន់ គឹមហុង** ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ពីបទ **ការកំហែងយក និងធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅចំណុចភោជនីយដ្ឋានប្រេ្គនយ៉ាម៉ាតុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីពីអំឡុងឆ្នាំ២០១៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៦៣, ៣៦៤ និង៤១០** នៃក្រមព្រហ្មទណ្ឌ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គង់ សំរេច** បានប្តឹងទាមទារសំណងថ្លៃខូចខាត និងសំណងជម្ងឺចិត្តចំនួន **១០,០០០ ដុល្លារអាមេរិក (មួយម៉ឺន)** ពីជនជាប់ចោទឈ្មោះ **លន់ គឹមហុង** តុលាការគប្បីពិចារណា ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១-ផ្តន្ទាទោសឈ្មោះ **លន់ គឹមហុង** ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់...............................ពីបទ **ការកំហែងយក និងធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅចំណុចភោជនីយដ្ឋានប្រេ្គនយ៉ាម៉ាតុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីពីអំឡុងឆ្នាំ២០១៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៦៣, ៣៦៤ និង៤១០** នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យឈ្មោះ **លន់ គឹមហុង** ភេទប្រុស អាយុ៣១ឆ្នាំ សងសំណងថ្លៃខូចខាត និងសំណងជម្ងឺចិត្តចំនួន....................................ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ **គង់ សំរេច** ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី**១៣ ខែវិច្ឆិកា ឆ្នាំ២០១៤** ចំពោះមុខជនជាប់ចោទឈ្មោះ **លន់ គឹមហុង**, មេធាវី **ម៉ុន វិមានចំប៉ា** ការពារសិទ្ធិឲ្យជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គង់ សំរេច**, និងប្រកាសជាសាធារណៈនៅ**ថ្ងៃទី.......ខែ.......... ឆ្នាំ២០១៤** បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: **អ៊ូ គារ៉ាន់** ហត្ថលេខា និងត្រា: **តាំង ស៊ុនឡាយ**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៤
**ក្រឡាបញ្ជី**

បានឃើញ
**ចៅក្រមជំនុំជម្រះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តស្ទឹងត្រែង

-សំណុំរឿងព្រហ្មទណ្ឌលេខ: ២២៣ អ.ក
ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០១៥
-សាលក្រមព្រហ្មទណ្ឌលេខ: [illegible]
ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តស្ទឹងត្រែង

សាលាដំបូងខេត្តស្ទឹងត្រែងបានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៩ និង ០០ នាទីព្រឹក និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោង០៤ និង៤០ នាទីរសៀល ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

-លោក [illegible] ជាចៅក្រម សាលាដំបូងខេត្តស្ទឹងត្រែង

**តំណាងអយ្យការ**

-លោក [illegible]ភាគ ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តស្ទឹងត្រែង

**[illegible]ឡាបញ្ជីសវនាការ**

-លោកស្រី [illegible]ភ្នា ជាក្រឡាបញ្ជីសាលាដំបូងខេត្តស្ទឹងត្រែង

**មេធាវី**

-លោក [illegible] ជាមេធាវីការពារជនជាប់ចោទ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ២២៣ អ.ក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទដូចខាងក្រោម:

១-ឈ្មោះ **គឹម សុវណ្ណារិទ្ធិ** ភេទប្រុស អាយុ ៤១ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ព័ត៌មាននគរជ ទីកន្លែងកំណើតភូមិស្វាយ ឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ២៥ ផ្លូវលេខ ១៤ ភូមិបឹងកក់០១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ គឹម សារឿង (ស្លាប់) ម្តាយឈ្មោះ យូន សារ៉ាន់ (ស្លាប់) ប្រពន្ធឈ្មោះ ទ្រី ចិន្តា មានកូន ០១នាក់ ទោសពីមុន- គ្មាន ។(ក្រៅឃុំ)

២-ឈ្មោះ **មុំ ម៉ុន** ភេទប្រុស អាយុ ៥៤ ឆ្នាំ ជាតិ ខ្មែរ មុខរបរ សារព័ត៌មានសង្គមខ្មែរ ទីកន្លែងកំណើតភូមិគគី ឃុំល្វៀង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃធំ ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកឈ្មោះ មុំ សារ៉េត (ស្លាប់) ម្តាយឈ្មោះ នុន ម៉ាច (ស្លាប់) ប្រពន្ធឈ្មោះ បូ លីណា មានកូន ០៨នាក់ ទោសពីមុន-គ្មាន ។(ក្រៅឃុំ)

៣-ឈ្មោះ **គឹម នឿន** ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិ ខ្មែរ មុខរបរសារព័ត៌មានជាតិខ្មែររស់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិផ្សារគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ គឹម សារឿង (ស្លាប់) ម្តាយឈ្មោះ យូន សារ៉ាន់ (ស្លាប់) ប្រពន្ធឈ្មោះ វណ្ណ ទីណា មានកូន ០១នាក់ ទោសពីមុន-គ្មាន ។(ក្រៅឃុំ)

ជាប់ចោទពីបទៈ "កំហែងយក" ប្រព្រឹត្តនៅភូមិតាឡាត ឃុំខ្យាច់ថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

__ដើមបណ្តឹងរដ្ឋប្បវេណី__

-ឈ្មោះ ស៊ី សុនា ភេទប្រុស អាយុ៣៦ ឆ្នាំ ជាតិ ខ្មែរ មុខរបរ មន្ត្រីកងរាជអាវុធហត្ថ ទីកន្លែងកំណើតភូមិចំរើនផល ឃុំតាអូន ស្រុកចំការលើ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិកំភុន ឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង ឪពុកឈ្មោះ ឡៀប សុវណ្ណ (រស់) ម្តាយឈ្មោះ នាថ ស្រីនាង (ស្លាប់) ប្រពន្ធឈ្មោះ ខាំ ស្នាក់ចាត់ចែង មានកូន ០២នាក់ ។

__អង្គហេតុ__

កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ វេលាម៉ោង ១១ និង ៣០នាទី នៅចំណុចផ្លូវចូលទៅភូមិតាឡាត ឃុំខ្យាច់ថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង មានករណីកំហែងយក ដែលប្រព្រឹត្តឡើងដោយឈ្មោះ គឹម សុវណ្ណារិទ្ធិ, ឈ្មោះ មុំ ម៉ន, និងឈ្មោះ គឹម នឿន ដែលមានតួនាទីជាអ្នកសារព័ត៌មានបានធ្វើការទាមទារប្រាក់ពីឈ្មោះ ស៊ី សុនា ចំនួន USD ៥០០ (ប្រាំរយដុល្លាអាមេរិក) ។ ដោយឃើញឈ្មោះ ស៊ី សុនា បានដឹកឈើមិនបានដឹងថាឈើនោះជាឈើដែលដឹកសម្រាប់យកទៅអង្គភាពកងរាជអាវុធហត្ថ។

បានឃើញៈរបាយការណ៍បញ្ជូនសំណុំរឿងលេខៈ ២៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ របស់ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង។

បានឃើញៈដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរលេខៈ ៧៧០អ.យ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង។

បានឃើញៈ កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ មុំ ម៉ុន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ បានឆ្លើយសារភាពថាៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ខ្លួននិងឈ្មោះ គឹម សុវណ្ណារិទ្ធ និងឈ្មោះ គឹម នឿន រួមទាំងឈ្មោះ ទ្រី ចិន្តា ជាត្រូវជាប្រពន្ធឈ្មោះគឹម សុវណ្ណារិទ្ធ បានធ្វើដំណើររួមគ្នាទៅភ្នំពេញ ពេលដល់ចំណុចស្រែសាមី បានឃើញគោយន្តចំនួន ០២គ្រឿង ទើបតែទំលាក់ឈើរួច ហើយពួកខ្លួនក៏ឈប់ឡាន ចុះទៅមើលគំនរឈើនោះរួចក៏ដើរត្រឡប់មកវិញ ស្របពេលនោះក៏មានឡាន០១គ្រឿង ជិះមកដល់ហើយអ្នកបើកបរឡាននោះបានសួរខ្លួនថាមកពីណា ខ្លួនតបវិញថាជាអ្នកកាសែត បន្ទាប់មកខ្លួនសួរទៀតថាឈើនេះជារបស់អ្នកណាម្ចាស់ឡាននោះ ឆ្លើយថាឈើរបស់គេក្នុងពេលនោះខ្លួនក៏សុំសាំងឡានបន្តិចបន្តួចពីអ្នកបើកឡាន ចំពោះប្រពន្ធរបស់ឈ្មោះ គឹម សុវណ្ណារិទ្ធ គឺអង្គុយនៅក្នុងឡានរហូត។ ហើយគេក៏បាននិយាយថាយកទៅជួបមេនៅស្នាក់ការតែខ្លួនមិនបានដឹងថាស្នាក់ការណាទេ ក៏ទៅតាមរួចបានជួបឡានបេអឹមគេឱ្យចូលមកទីបញ្ជាការខេត្ត ក៏បានធ្វើកំណត់ហេតុ និងឃាត់ខ្លួនតែម្តង។

បានឃើញៈ កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ គឹម សុវណ្ណារិទ្ធ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ បានឆ្លើយសារភាពថាៈ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ

២០១៤ ខ្លួនបានធ្វើដំណើរពីខេត្តរតនគីរីទៅភ្នំពេញជាមួយឈ្មោះមុំ ម៉ន និងឈ្មោះគឹម នឿន រួមទាំងប្រពន្ធខ្លួនឈ្មោះ ទ្រី ចិន្តា ទៅដល់ចំណុចស្រែសាមីពួកខ្លួនបានឃើញគោយន្តកន្ត្រៃពីរគ្រឿងបើកចេញពីកន្លែងគំនរឈើរួចពួខ្លួនក៏បានឈប់ឡាន ចុះពីឡានទៅមើលជាមួយឈ្មោះ មុំ ម៉ន និងឈ្មោះ គឹម នឿន និងបានសួរនាំពីរបីមាត់ជាមួយមនុស្សប្រុសម្នាក់នោះប្រាប់ថាឈើរបស់គេ ហើយឈ្មោះ មុំ ម៉ន បានសុំសាំងឡានបំណាងមកចាក់ឡាន។ ក៏ស្រាប់តែគេនិយាយថាចាំជួបមេនៅស្នាក់ការ តែខ្លួនមិនដឹងថាស្នាក់ការណាទេ រួចក៏បានជិះឡានមកតាម ហើយមានឡានបេអឹមបានជិះមកឱ្យចូលស្នាក់ការខេត្ត និងធ្វើការឃាត់ខ្លួនតែម្តង។

បានឃើញ: កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ គឹម នឿន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ បានឆ្លើយសារភាពថា៖ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ ខ្លួនបានធ្វើដំណើរពីខេត្តរតនគីរីទៅភ្នំពេញមានគ្នាចំនួន ០៤នាក់ មានឈ្មោះ គឹម សុវណ្ណារិទ្ធ ឈ្មោះ មុំ ម៉ន និងឈ្មោះ ទ្រី ចិន្តា បានមកដល់ចំណុចស្រែសាមី ក៏បានឃើញគោយន្តពីរគ្រឿងបានទំលាក់ឈើរួច បន្ទាប់មកមានឡានកាមរីស្ទិតបើកបរដោយឈ្មោះ ស៊ី សុនា ចុះពីឡានមកបងប្រុសខ្លួនឈ្មោះ គឹម សុវណ្ណារិទ្ធ បានសួរឈើរបស់នរណាគេ ក្រោយមកគេឆ្លើយថាជាឈើរបស់មេខេត្ត ធ្វើយកទៅឱ្យមេ បន្ទាប់មកពួកខ្លួនបានឡើងឡានវិញ ហើយឈ្មោះ ស៊ី សុនា បានឱ្យពួកខ្លួនទៅជួបមេនៅស្នាក់ការច្រប់មិនទាន់ទៅដល់ផងមានឡានបេអឹមមានសារ៉ែនឃាត់ខ្លួនពួកខ្លួនតែម្តង។

បានឃើញ: ដីកាបង្គាប់ឱ្យឃុំខ្លួនឈ្មោះ គឹម សុវណ្ណារិទ្ធ លេខ: ៧០៨ ព.ស ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរ។

បានឃើញ: ដីកាបង្គាប់ឱ្យឃុំខ្លួនឈ្មោះ គឹម នឿន លេខ: ៧១០ ព.ស ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរ។

បានឃើញ: ដីកាបង្គាប់ឱ្យឃុំខ្លួនឈ្មោះ មុំ ម៉ន លេខ: ៧០៦ ព.ស ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរ។

បានឃើញ: កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ទ្រី ចិន្តា ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ បានឆ្លើយសារភាពថា៖ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ ខ្លួនបានធ្វើដំណើរពីខេត្តរតនគីរីទៅភ្នំពេញមានគ្នាចំនួន ០៤នាក់ មានប្តីឈ្មោះ គឹម សុវណ្ណារិទ្ធ ឈ្មោះ មុំ ម៉ន និងប្អូនឈ្មោះ គឹម នឿន ពេលជិះឡានមកដល់ចំណុច ដែលមានឈើទុកនៅក្បែរផ្លូវនោះស្រាប់តែប្តីរបស់ខ្លួនព្រមទាំងប្អូន និងពូ បានចុះពីលើឡានដើរទៅមើល តែខ្លួននៅអង្គុយនិយាយទូរស័ព្ទក្នុងឡានម្នាក់ឯង ចំពោះរឿងថាប្តីខ្លួនទៅទារលុយនោះទេ។

បានឃើញ: ពាក្យការពារក្តី ចុះថ្ងៃទី២៣ ខែកក្កដាឆ្នាំ២០១៤ របស់មេធាវី មៅ សារី។

បានឃើញ:សំណើសុំធានាលេខ: ៦៧ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ របស់មន្ទីរព័ត៌មានខេត្តរតនគីរី។

បានឃើញៈ កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ី សុនា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ បានឆ្លើយថាៈ នៅថ្ងៃកើតហេតុថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៤ វេលាម៉ោង ០៧ព្រឹក ខ្លួនចេញពីភូមិស្រែសាមី ចាំលើកឈើប្រភេទ ថ្មិតឡើងលើឡានដោយឈើនេះខ្លួនទិញសម្រាប់យកមកធ្វើផ្ទះ។ មូលហេតុដែលឈើនោះ ខ្លួនទុកនៅផ្លូវព្រោះឈើនោះខ្លួនទិញពីក្នុងព្រៃមកហើយដឹកដោយគោយន្តមកទំលាក់នៅ ស្រែសាមីនេះ ហើយបំណងយកឡានកូរ៉េមួយបាំងកន្លះ ដើម្បីដឹកបន្តយកទៅផ្ទះខ្លួននៅភូមិ កំភុន។ ឈើនេះមានចំនួន ៦០សន្លឹក(ទំហំ ០៧ ហុន X ២៥) ហើយខ្លួនទិញបានតាំងពីកន្លះ ខែមុនដោយទុកនៅក្នុងព្រៃទាល់តែមានលុយទើបបានដឹកចេញពីព្រៃរួចកល់ថ្ងៃកើតហេតុ ទើបខ្លួនបានដឹកឈើនោះចេញពីព្រៃ។ ហើយឈើនេះខ្លួនបំរុងដឹកយកទៅផ្ទះ ស្រាប់តែមាន ឡានម៉ាកកាមរីស្ទិត ពណ៌ស ស្លាកលេខ ២២៩៨ ដោយមានមនុស្សបីនាក់ ចុះពីឡានមក រកខ្លួន ដោយមានមនុស្ស ០៣នាក់ ក្នុងចំណោមនោះខ្លួនបានដឹងថាមានម្នាក់ឈ្មោះ គឹម សុវណ្ណារិទ្ធ ហើយក្នុងចំណោមបីនាក់នោះបាននិយាយមកកាន់ខ្លួនផ្ទាល់ថាឈើរបស់ នរណា ខ្លួនតបវិញថាជាឈើរបស់ខ្លួន ហើយឈ្មោះ គឹម សុវណ្ណារិទ្ធ បាននិយាយថាចឹងគិត ថ្លៃសាំងឱ្យគេទៅ USD ៥០០(ប្រាំរយដុល្លាអាមេរិក)។

បានឃើញៈ សំណើសុំធានាក្រៅឃុំអ្នកសារព័ត៌មានលេខៈ ២០ កសក ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាសារព័ត៌មានកម្ពុជា។

បានឃើញៈដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខៈ ៨១៣ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៤។

បានឃើញៈដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខៈ ៨១៦ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៤។

បានឃើញៈដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខៈ ៨១៩ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៤។

បានឃើញៈដីកាសម្រេចប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមវិញលេខៈ ២២១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤។

បានឃើញៈ លិខិតជូនព័ត៌មានអំពីការបញ្ចប់ការស៊ើបសួរលេខៈ ៣៥៧ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរ។

បានឃើញៈដីកាបញ្ជូនរឿងមូលទៅពិនិត្យលេខៈ ៣៦០ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៤ របស់ចៅក្រមស៊ើបសួរ។

បានឃើញៈដីកាសន្និដ្ឋានស្ថាពរលេខៈ ១០៧៣ អ.យ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង។

បានឃើញៈដីកាបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខៈ ១១០១ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៤ របស់ចៅក្រមស៊ើបសួរ។

បានឃើញៈដីកាចាត់តាំងចៅក្រមជំនុំជំរះលេខៈ ១០៧២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ របស់សាលាដំបូងខេត្តស្ទឹងត្រែង។

បានឃើញៈការផ្តល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយអនុលោមតាម មាត្រា ១៩២ និងមាត្រា បន្តបន្ទាប់។

**នាពេលសវនាការ**

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ មុំ ម៉ន

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ គីម សុវណ្ណារិទ្ធ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ គីម នឿន

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ី សុនា

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ ទ្រី ចិន្តា

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចរាលហើយ

**សាលាដំបូងខេត្តស្ទឹងត្រែង**

**យល់ឃើញថា**

-កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ វេលាម៉ោង ១១ និង ៣០នាទី នៅចំណុចផ្លូវចូលទៅភូមិតាឡាត ឃុំខ្សាច់ថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង មានករណីកំហែងយក ដែលប្រព្រឹត្តឡើងដោយឈ្មោះ គីម សុវណ្ណារិទ្ធិ, ឈ្មោះ មុំ ម៉ន, និងឈ្មោះ គីម នឿន ដែលមានតួនាទីជាអ្នកសារព័ត៌មានបានធ្វើការទាមទារប្រាក់ពីឈ្មោះ ស៊ី សុនា ចំនួន USD ៥០០ (ប្រាំរយដុល្លាអាមេរិក) ។ ដោយឃើញឈ្មោះ ស៊ី សុនា បានដឹកឈើមិនបានដឹងថាឈើនោះជាឈើដែលដឹកសម្រាប់យកទៅអង្គភាពកងរាជអាវុធហត្ថ។

-តាមអំណានចម្លើយនាពេលសវនាការជនជាប់ចោទឈ្មោះ មុំ ម៉ន បានឆ្លើយសារភាពថាៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ខ្លួននិងឈ្មោះ គីម សុវណ្ណរិទ្ធ និងឈ្មោះ គីម នឿន រួមទាំងឈ្មោះ ទ្រី ចិន្តា ជាត្រូវជាប្រពន្ធឈ្មោះគីម សុវណ្ណរិទ្ធ បានធ្វើដំណើររួមគ្នាទៅភ្នំពេញ ពេលដល់ចំណុចស្រែសាមី បានឃើញគោយន្តចំនួន ០២គ្រឿង ទើបតែទំលាក់ឈើរួចហើយពួកខ្លួនក៏ឈប់ឡាន ចុះទៅមើលគំនរឈើនោះរួចក៏ដើរត្រឡប់មកវិញ ស្របពេលនោះក៏មានឡាន០១គ្រឿង ជិះមកដល់ហើយអ្នកបើកបរឡាននោះបានសួរខ្លួនថាមកពីណាខ្លួន តបវិញថាជាអ្នកកាសែត បន្ទាប់មកខ្លួនសួរទៀតថាឈើនេះជារបស់អ្នកណាម្ចាស់ឡាននោះ ឆ្លើយថាឈើរបស់គេក្នុងពេលនោះខ្លួនក៏សុំសាំងឡានបន្តិចបន្តួចពីអ្នកបើកឡានចំពោះប្រពន្ធរបស់ឈ្មោះ គីម សុវណ្ណរិទ្ធ គឺអង្គុយនៅក្នុងឡានរហូត។ ហើយគេក៏បាននិយាយ ថាយកទៅជួបមេនៅស្នាក់ ការតែខ្លួនមិនបានដឹងថាស្នាក់ការណាទេ ក៏ទៅតាមរួចបានជួបឡានបេអឹមគេឱ្យចូលមកទីបញ្ជាការខេត្ត ក៏បានធ្វើកំណត់ហេតុ និងឃាត់ខ្លួនតែម្តង។

-តាមអំណានចម្លើយនាពេលសវនាការជនជាប់ចោទឈ្មោះ គឹម សុវណ្ណារិទ្ធ បានឆ្លើយសារភាពថា៖ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ ខ្លួនបានធ្វើដំណើរពីខេត្តរតនគីរីទៅភ្នំពេញជាមួយឈ្មោះមុំ ម៉ន និងឈ្មោះគឹម នឿន រួមទាំងប្រពន្ធខ្លួនឈ្មោះ ទ្រី ចិន្តា ទៅដល់ចំណុចស្រែសាមីពួកខ្លួនបានឃើញគោយន្តកន្ត្រៃពីរគ្រឿងបើកចេញពីកន្លែងគំនរឈើរួចពួកខ្លួនក៏បានឈប់ឡាន ចុះពីឡានទៅមើលជាមួយឈ្មោះ មុំ ម៉ន និងឈ្មោះ គឹម នឿន និងបានសួរនាំពីរបីមាត់ជាមួយមនុស្សប្រុសម្នាក់នោះប្រាប់ថាឈើរបស់គេ ហើយឈ្មោះ មុំ ម៉ន បានសុំសាំងឡានបំណាងមកចាក់ឡាន។ ក៏ស្រាប់តែគេនិយាយថាចាំជួបមេនៅស្នាក់ការ តែខ្លួនមិនដឹងថាស្នាក់ការណាទេ រួចក៏បានជិះឡានមកតាម ហើយមានឡានបេអឹមបានជិះមកឱ្យចូលស្នាក់ការខេត្ត និងធ្វើការឃាត់ខ្លួនតែម្តង។

-តាមអំណានចម្លើយនាពេលសវនាការជនជាប់ចោទឈ្មោះ គឹម នឿន បានឆ្លើយសារភាពថា៖នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ ខ្លួនបានធ្វើដំណើរពីខេត្តរតនគីរីទៅភ្នំពេញមានគ្នាចំនួន ០៤នាក់ មានឈ្មោះ គឹម សុវណ្ណារិទ្ធ ឈ្មោះ មុំ ម៉ន និងឈ្មោះ ទ្រី ចិន្តា បានមកដល់ចំណុចស្រែសាមី ក៏បានឃើញគោយន្តពីរគ្រឿងបានទំលាក់ឈើរួច បន្ទាប់មកមានឡានកាមរីស៊ិតបើកបរដោយឈ្មោះ ស៊ី សុនា ចុះពីឡានមកបងប្រុសខ្លួនឈ្មោះ គឹម សុវណ្ណារិទ្ធ បានសួរឈើរបស់នរណាគេ ក្រោយមកគេឆ្លើយថាជាឈើរបស់មេខេត្ត ធ្វើយកទៅឱ្យមេ បន្ទាប់មកពួកខ្លួនបានឡើងឡានវិញ ហើយឈ្មោះ ស៊ី សុនា បានឱ្យពួកខ្លួនទៅជួបមេនៅស្នាក់ការច្រប់មិនទាន់ទៅដល់ផងមានឡានបេអឹមមានសារ៉ែនឃាត់ខ្លួនពួកខ្លួនតែម្តង។

-នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ី សុនា បានឆ្លើយអះអាងថា៖ នៅថ្ងៃកើតហេតុថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ វេលាម៉ោង ០៧ព្រឹក ខ្លួនចេញពីភូមិស្រែសាមី ចាំលើកឈើប្រភេទថ្កិតឡើងលើឡានដោយឈើនេះខ្លួនទិញសម្រាប់យកមកធ្វើផ្ទះ។ មូលហេតុដែលឈើនោះខ្លួនទុកនៅផ្លូវព្រោះឈើនោះខ្លួនទិញពីក្នុងព្រៃមកហើយដឹកដោយគោយន្តមកទំលាក់នៅស្រែសាមីនេះ ហើយបំណាងយកឡានកូរ៉េមួយបាំងកន្លះ ដើម្បីដឹកបន្តយកទៅផ្ទះខ្លួននៅភូមិកំភុន។ ឈើនេះមានចំនួន ៦០សន្លឹក(ទំហំ ០៧ ហុន X ២៥) ហើយខ្លួនទិញបានតាំងពីកន្លះខែមុនដោយទុកនៅក្នុងព្រៃទាល់តែមានលុយទើបបានដឹកចេញពីព្រៃរួចកល់ថ្ងៃកើតហេតុទើបខ្លួនបានដឹកឈើនោះចេញពីព្រៃ។ ហើយឈើនេះខ្លួនបំរុងដឹកយកទៅផ្ទះ ស្រាប់តែមានឡានម៉ាកកាមរីស៊ិត ពណ៌ស ស្លាកលេខ ២២៩៨ ដោយមានមនុស្សបីនាក់ ចុះពីឡានមក រកខ្លួន ដោយមានមនុស្ស ០៣នាក់ ក្នុងចំណោមនោះខ្លួនបានដឹងថាមានម្នាក់ឈ្មោះ គឹម សុវណ្ណារិទ្ធ ហើយក្នុងចំណោមបីនាក់នោះបាននិយាយមកកាន់ខ្លួនផ្ទាល់ថាឈើរបស់នរណា ខ្លួនតបវិញថាជាឈើរបស់ខ្លួន ហើយឈ្មោះ គឹម សុវណ្ណារិទ្ធ បាននិយាយថាចឹងគិតថ្លៃសាំងឱ្យគេទៅ USD ៥០០(ប្រាំរយដុល្លាអាមេរិក)។

-តាមអំណានចម្លើយនាពេលសវនាការសាក្សីឈ្មោះ ទ្រី ចិន្តា បានឆ្លើយបំភ្លឺថា៖ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ ខ្លួនបានធ្វើដំណើរពីខេត្តរតនគីរីទៅភ្នំពេញមានគ្នាចំនួន ០៤នាក់ មានប្តីឈ្មោះ គឹម សុវណ្ណារិទ្ធ ពូឈ្មោះ មុំ ម៉ន និងប្អូនឈ្មោះ គឹម នឿន ពេលជិះឡានមក

ដល់ចំណុច ដែលមានឈើទុកនៅក្បែរផ្លូវនោះស្រាប់តែប្ដីរបស់ខ្លួនព្រមទាំងប្អូន និង១ បាន ចុះពីលើឡានដើរទៅមើល តែខ្លួននៅអង្គុយនិយាយទូរស័ព្ទក្នុងឡានម្នាក់ឯង ចំពោះរឿងថា ប្ដីខ្លួនទៅទារលុយនោះទេ។

**-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា៖** ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹង រដ្ឋប្បវេណីឈ្មោះ ស៊ី សុនា និងអំណានចម្លើយរបស់ជនជាប់ចោទ ឃើញថាជនជាប់ចោទ បានសុំសាំងពីដើមបណ្ដឹងដោយពួកគេគ្មានទំនាក់ទំនងគ្នាទាល់តែសោះ។ អំពើរបស់ជន ជាប់ចោទបានចត់រូបគំនរឈើ និងទារលុយពីដើមបណ្ដឹង អំពើនេះជាការគំរាមគំហែងទៅ លើដើមបណ្ដឹងរដ្ឋប្បវេណី។ហេតុដូច្នេះតំណាងអយ្យការរក្សាការចោទប្រកាន់តាមដីកា សន្និដ្ឋានស្ថាពរដដែល ពីបទ៖ "កំហែងយក" ប្រព្រឹត្តនៅភូមិតាឡាត ឃុំខ្សាច់ថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៣៦៣ និងមាត្រា៣៦៤** នៃក្រមព្រហ្មទណ្ឌ។

**-មេធាវីការពារជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា៖** ក្នុងរឿងនេះគ្មិតតែអវត្តមានជនជាប់ចោទតែជនជាប់ចោទបានឆ្លើយគ្រប់ដំណាក់កាលកន្លងមក ហើយតំណាងអយ្យការបាន ចោទប្រកាន់ទៅលើកូនក្ដីខ្លួនពីបទ: កំហែងយក ដូច្នេះខ្លួនសុំពន្យល់ពីបទកំហែងយក គឺការ គំរាមគំហែង តែការសុំនេះឱ្យមិនឱ្យក៏ហើយ ដោយកូន ដោយកូនក្ដីខ្លួនមិនបានសំឡុត រឺធ្វើ អ្វីជាថ្នូដើម្បីបានលុយទេ។ ម្យ៉ាងទៀតកូនក្ដីថតរូបមែនដោយមិនបាននិយាយថាយកទៅ បង្ហោះវែបហ្សាយ និងគ្មានការដាក់លក្ខខណ្ឌគំនាបទេ ណាមួយធាតុផ្សំបទល្មើស និងភស្តុតាងដាក់បន្ទុកក៏ជាអង្គហេតុប្រយោល ដោយគ្មានលក្ខណៈគ្រប់គ្រាន់។ ដូច្នេះសូមតុលាការ មេត្តាសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ មុំ ម៉ន ឈ្មោះ **គឹម សុវណ្ណារិទ្ធ**, និងឈ្មោះ **គឹម នឿន** បានឆ្លើយសារភាពថាពួកគេបានពិតជាបានទៅសុំសាំងឡានពីឈ្មោះ ស៊ី សុនា ប្រាកដមែន។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ មុំ ម៉ន ,ឈ្មោះ**គឹម សុវណ្ណារិទ្ធ** ,ឈ្មោះ **គឹម នឿន** និងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស៊ី សុនា ព្រមទាំងសាក្សីឈ្មោះ ទ្រី ចិន្តា មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ដោយជនជាប់ចោទ ពិតជាបានប្រព្រឹត្តអំពើ កំហែងយកប្រាក់ប្រាកដមែន។

-មានភស្តុតាង,បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ មុំ ម៉ន ភេទ ប្រុស អាយុ ៥៨ឆ្នាំ ឈ្មោះ **គឹម សុវណ្ណារិទ្ធិ** ភេទប្រុស អាយុ ៩១ឆ្នាំ និងឈ្មោះ **គឹម នឿន** ភេទប្រុស អាយុ ២៨ឆ្នាំ ពីបទ: "**កំហែងយក**" ប្រព្រឹត្តនៅភូមិតាឡាត ឃុំខ្សាច់ថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង កាល ពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៣៦៣ និងមាត្រា៣៦៤** នៃក្រមព្រហ្មទណ្ឌ។

-អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សន្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយ និង សន្តិសុខសង្គម។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ មុំ ម៉ន ឈ្មោះ គឹម សុវណ្ណារិទ្ធ និងឈ្មោះ គឹម នឿន មានចេតនាទុច្ចរិតប្រព្រឹត្តអំពើកំហែកយកលើឈ្មោះ ស៊ី សុនា ដែលល្មើសទៅនឹងប្បញ្ញត្តិនៃច្បាប់បានហាមឃាត់។

-ជនជាប់ចោទឈ្មោះ មុំ ម៉ន ឈ្មោះ គឹម សុវណ្ណារិទ្ធ និងឈ្មោះ គឹម នឿន មិនព្រមចូលខ្លួនមកបំភ្លឺតាមការកោះហៅរបស់តុលាការនៅពេលសវនាការ ដូច្នេះគប្បីតុលាការពិចារណា។

-ជនជាប់ចោទជា នីតិជនមានស្មារតីទទួលខុសត្រូវនូវព្យសនកម្មដែលកើតពីអំពើប្រព្រឹត្តរបស់ខ្លួន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ី សុនា មិនប្តឹងទាមទារអ្វីទេ តែឱ្យតុលាការចាត់ការទៅតាមច្បាប់។

**ហេតុដូច្នេះសាលាដំបូងខេត្តស្ទឹងត្រែង**

**សម្រេចសេចក្តី**

១-ផ្តន្ទាទោស:

ក- ជនជាប់ចោទឈ្មោះ [illegible] ភេទប្រុស អាយុ ៥៤ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន និងពិន័យជាប្រាក់ចំនួន ៦,០០០,០០០៛(ប្រាំមួយលានរៀល) ដើម្បីបង់ចូលថវិការដ្ឋ។

ខ- ជនជាប់ចោទឈ្មោះ គឹ[illegible]ទ្ធ ភេទប្រុស អាយុ ៤១ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី)ឆ្នាំគិតពីថ្ងៃចាប់ខ្លួនបាន និងពិន័យជាប្រាក់ចំនួន៦,០០០,០០០៛(ប្រាំមួយលានរៀល) ដើម្បីបង់ចូលថវិការដ្ឋ។

គ- ជនជាប់ចោទឈ្មោះ [illegible] ភេទប្រុស អាយុ ២៨ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី)ឆ្នាំគិតពីថ្ងៃចាប់ខ្លួនបាន និងពិន័យជាប្រាក់ចំនួន៦,០០០,០០០៛(ពីរលានរៀល) ដើម្បីបង់ចូលថវិការដ្ឋ។

ពីបទ: "កំហែងយក" ប្រព្រឹត្តនៅភូមិតាឡាត ឃុំខ្សាច់ថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [illegible] ឈ្មោះ គឹម [illegible]ទ្ធ និងឈ្មោះ [illegible] សងសំណងជម្ងឺចិត្តចំនួន ១,០០០,០០០៛(មួយលានរៀល) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ី សុនា ចាប់ពីពេលសាលក្រមចូលជាស្ថាពរ។

៣-បង្គាប់ឱ្យភ្នាក់ងារមានសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទឈ្មោះ មុំ ម៉ន, ឈ្មោះ គឹម សុវណ្ណារិទ្ធ និងឈ្មោះ គឹម នឿន តាមដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមជំនុំជំរះ តាមមាត្រា ៣៥៣ កថាខណ្ឌ ០១ ចំណុច ០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-សាលក្រមនេះជំនុំជំម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ វេលា

ម៉ោង០៥ និង៥០ នាទីរសៀល កំបាំងមុខជនជាប់ចោទឈ្មោះ មុំ ម៉ន ,ឈ្មោះ គឹម សុវណ្ណារិទ្ធ និងឈ្មោះគឹម នឿន និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ី សុនា។

»បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា

**ចៅក្រមជំនុំជំរះ**

ហត្ថលេខា និងត្រា

---

**បានឃើញ**

**ចៅក្រមជំនុំជំរះ**

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ស្ទឹងត្រែង.ថ្ងៃទី......... ខែតុលា ឆ្នាំ២០១៥

**ក្រឡាបញ្ជី**

# ឃាត់ខ្លួនអ្នកសារព័ត៌មាន៤នាក់ រត់រួច២នាក់ ពីបទកំហែងយកប្រាក់

ចាន់ធី 12/2/2017 11:31 Am ព័ត៌មានជាតិ, សន្តិសុខ និងសង្គម

LIKE

ឧត្តរមានជ័យ ៖ កម្លាំងអធិការដ្ឋាននគរបាលស្រុកត្រពាំងប្រាសាទ បានទទួលពាក្យបណ្តឹងរបស់ជនរងគ្រោះ និង តាមបញ្ជារបស់លោកកួយ កាន់យ៉ា ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តឧត្តរមានជ័យ បានធ្វើការឃាត់ខ្លួន ជនសង្ស័យចំនួន០៤ នាក់ ពីបទកំហែងយកប្រាក់។



ជនសង្ស័យទាំង៤នាក់នោះ៖ទី១.ឈ្មោះ ស៊ិញ សំឡី ភេទប្រុស អាយុ៥០ឆ្នាំ នាយកនិពន្ធសារព័ត៌មាន (វិមានឯករាជ្យ) រស់នៅភូមិ គោកឫស្សី ឃុំ កែវព័រ ស្រុកពួក ខេត្ត សៀមរាប។

ទី២.ឈ្មោះ ស ធុច ភេទប្រុសអាយុ ៥១ឆ្នាំ ជាភ្នាក់ងារសារព័ត៌មាន (កោះពេជ្រ ) រស់នៅភូមិ ដូនស ឃុំស្វាយជ្រុំ ស្រុកស្វាយជ្រុំ ខេត្ត ស្វាយរៀង។ ទី៣.ប៉ាវទិត ណារ៉ុង ភេទ ប្រុស អាយុ៣២ឆ្នាំ ជាអ្នកយកព័ត៌មាន(ខ្មែរម្ចាស់ស្រុក) រស់នៅភូមិព្រៃកព្រះ ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង។

ទី៤. ឈ្មោះ សឿង សាន ភេទប្រុស អាយុ២៨ឆ្នាំ មុខរបរមិនពិតប្រាកដ រស់នៅភូមិតាំងក្រសាំង,ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម។





សមត្ថកិច្ចចុះប្រតិបត្តិការឃាត់ខ្លួនជនសង្ស័យបានឲ្យដឹងថា នៅថ្ងៃ១១ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង១០និង១០នាទីព្រឹក ក្រុមជនសង្ស័យ មានគ្នា០៦នាក់រថយន្ត ០២ គ្រឿង ១ ម៉ាក Camry ពណ៌សំបកឪឡឹកពាក់ស្លាកលេខ ភ្នំពេញ 2C 0130 និង១គ្រឿងទៀត Camry កាលីហ្វកញ៉ា ពណ៌ក្រហម មិនចាំស្លាកលេខ បានទៅគំរាមទារប្រាក់ពីជនរងគ្រោះ ឈ្មោះ នូវសាន ភេទប្រុស អាយុ៤៣ឆ្នាំរស់នៅភូមិទំនប់ថ្មី ឃុំ-ស្រុកត្រពាំងប្រាសាទ ដោយគំរាមថានឹងចុះផ្សាយបើពុំបានប្រាក់។ គេនឹងផ្សាយពីជនរងគ្រោះ ថារកស៊ីឈើ។ តាមចម្លើយជនសង្ស័យ ពួកខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន។

ប្រភពបន្តថា វត្ថុតាងចាប់យករួមមានៈ ប្រាក់ចំនួន១លាន ២៩ម៉ឺនរៀល និងរថយន្ត០១គ្រឿងនៅសល់ក្រៅពីនោះត្រូវបក្ខពួក០២នាក់ ដែលរត់រួចយកទៅជាមួយ។

ចំពោះប្រាក់ជាវត្ថុតាងចាប់យកបានគឺត្រូវបានផ្ទៀងផ្ទាត់លេខលើក្រដាសប្រាក់ឃើញថា ត្រូវនឹងលេខដែលជនរងគ្រោះបានកត់ទុក មុនពេលប្រគល់ឲ្យក្រុមជនសង្ស័យ។

បច្ចុប្បន្នសមត្ថកិច្ចកំពុងធ្វើការសាកសួរ កសាងសំណុំរឿងតាមនីតិវិធី៕



# ប៉ូលិស ចាប់ក្មេងទំនើងញៀនថ្នាំ កំហែងយក និងឆបោកទូរស័ព្ទ iPhone ពីកូនក្រឡាបញ្ជី ខេត្តបន្ទាយមានជ័យ

0 0
G+ Tweet

(ថ្ងៃទី 16 កញ្ញា 2014, ម៉ោង 04:23:PM) | ដោយ: សូផុន



បន្ទាយមានជ័យ: ក្មេងទំនើងញៀនគ្រឿងញៀនម្នាក់ បានទៅសំលឹងមុខកំហែង និងឆបោកយកទូរស័ព្ទដៃ iPhone 4S ពីក្មេងប្រុសអាយុ ១៣ ឆ្នាំ ដែលជាកូនក្រឡាបញ្ជីខេត្តបន្ទាយមានជ័យ ត្រូវបានសមត្ថកិច្ចប៉ូលិសចម្រុះ បានឃាត់ខ្លួនជនសង្ស័យ នៅមុខក្លឹបកំសាន្តភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ កាលពីម៉ោង ១១ យប់ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤។

លោកវរសេនីយ៍ សិទ្ធ ឡោះ ស្នងការរងនគរបាល ខេត្តបន្ទាយមានជ័យ បានអោយដឹង នៅថ្ងៃទី១៦កញ្ញាថា ជនរងគ្រោះ ម្ចាស់ទូរស័ព្ទដៃម៉ាក iPhone 4S មានឈ្មោះ ឈិន ពិនពិសិដ្ឋ ជាសិស្សថ្នាក់ទី៨ រៀននៅអនុវិទ្យាល័យ សិរីសោភ័ណ ត្រូវជាកូនរបស់លោក ឈិន ទេពភិរុណ ក្រឡាបញ្ជី នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។ ឯជនសង្ស័យ មានឈ្មោះ សំ វណ្ណៈ ហៅ ណាក់ ភេទប្រុស អាយុ ២៦ឆ្នាំ គ្មានរបរពិតប្រាកដ និងញៀនគ្រឿងញៀន ហើយជាមុខសញ្ញាល្មើសច្រើនករណី ហើយស្នាក់នៅបណ្ដោះអាសន្ន នៅម្ដុំខាងក្រោយសាលាគំរូភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ។

សូមរំលឹកថា នៅម៉ោង១កន្លះ ថ្ងៃទី១៣កញ្ញា ជនរងគ្រោះបានទៅរៀនគួរ នៅសាលាគំរូ (អនុវិទ្យាល័យសិរីសោភ័ណ) មានជនមិនស្គាល់អត្តសញ្ញាណពីរនាក់ បានមកខ្ចីទូរស័ព្ទនិយាយ។ ពេលនោះ ជនរងគ្រោះ ឆ្លើយថា "មិនមាន" តែត្រូវជនល្មើសម្នាក់ ដែលមានសភាពញៀនម៉ា បានសំលឹងសំឡុតមុខជនរងគ្រោះ ហើយជនរងគ្រោះ ខ្លាច ក៏ហុចទូរស័ព្ទអោយ។

ជនល្មើសនិយាយចប់ ក៏អោយជនរងគ្រោះឌុបខ្លួន តាមម៉ូតូ ឆ្ពៃលទៅផ្ដុំស្ថានីយរថភ្លើងសិរីសោភ័ណ ដោយមានគ្នាពីរនាក់ រួចក៏អោយម្នាក់ចុះ។ បន្ទាប់មកជនល្មើសឈ្មោះ សំ វណ្ណៈ បានអោយជនរងគ្រោះ ជូនខ្លួនមកផ្ទះវិញ ផ្ដុំសាលាគំរូ។ លុះជនរងគ្រោះ សុំទូរស័ព្ទដៃវិញ តែជនល្មើសប្រាប់ថា គ្នាគេម្នាក់ទៀត យកបាត់ ហើយក៏ដើចូលទៅផ្ទះធ្វើព្រងើយបាត់ទៅ។

លោក សិទ្ធ ឡោះ និយាយបន្តទៀតថា ក្រោយទទួលបណ្ដឹងសមត្ថកិច្ចតាមស្រាវជ្រាវ រក និងកំណត់មុខសញ្ញា រួចបង្ក្រាបបានម្នាក់ ឈ្មោះ សំ វណ្ណៈ ជាជនដៃដល់ ដោយអន្ទងមកក្លឹបកំសាន្ត៕



# កំពុងផ្តឹះសោទ្វារបន្ទប់គេប៉ងលួចទ្រព្យសម្បត្តិ ត្រូវម្ចាស់គេមកទាន់ចាប់ខ្លួន

សឿន 21/7/2017 11:47 Pm ព័ត៌មានជាតិ, សន្តិសុខ និងសង្គម

♡ LIKE

ភ្នំពេញ ៖ បុរសវ័យក្មេងម្នាក់ត្រូវបានប្រជាជននាំគ្នាចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចមូលដ្ឋានចាត់ការតាមច្បាប់ ខណៈជននេះបានកំពុងតែធ្វើសកម្មភាពផ្តឹះសោទ្វារបន្ទប់គេប៉ងលួចយកទ្រព្យសម្បត្តិ តែពុំបានសម្រេច។

ករណីនេះបានកើតឡើងនៅវេលាម៉ោង១០ព្រឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ នៅបន្ទប់ផ្ទះជួលក្នុងដីឡូត៍លេខ៤៣៥ ផ្លូវលេខ២០១៣ ស្ថិតក្នុងភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ។

បុរសជនជាប់ចោទឈ្មោះ ម៉ី ឧត្តម អាយុ២៣ឆ្នាំ គ្មានមុខរបរស្នាក់នៅបន្ទប់ជួលក្បែរ ជនរងគ្រោះនៅម្តុំចំណុចកើតហេតុ ខាងលើ។ អ្នកស្រី គឹ សុម៉ាលី អាយុ៣៦ឆ្នាំ ដែលបានអះអាងថា គាត់ជាជនរងគ្រោះនិងជាដើមបណ្តឹងក្នុងករណីនេះបានរាយការណ៍ប្រាប់សមត្ថកិច្ចថា នៅថ្ងៃកើតហេតុគាត់បាន ពរកូនទៅទិញនំឲ្យវា នៅចម្ងាយប្រហែល ៥០ម៉ែត្រពីផ្ទះដោយបានចាក់សោត្រឹមត្រូវ លុះពេលត្រឡប់មកវិញស្រាប់តែប្រទះឃើញបុរសម្នាក់នេះកំពុងខិនផ្តឹះសោទ្វារបន្ទប់របស់គាត់ស្នាក់នៅ។

អ្នកស្រីបានបន្តថា នៅពេលភ្លាមៗនោះគាត់ក៏បានស្រែកចោរៗភ្ញាក់ផ្អើលដល់ប្រជាជននៅក្បែរនោះនាំគ្នាជួយចាប់បានភ្លាមយកប្រគល់ឲ្យប៉ូលិសមកទទួលយកទៅចាត់ការតាមច្បាប់។

នៅពេលឃាត់ខ្លួននោះប៉ូលិសបាន រកឃើញវត្ថុតាងដែកកែច្នៃសម្រាប់ផ្តឹះសោចំនួន១ និងមេសោខ្មៅចំនួន១ មានកូនចំនួន៣ ហើយជនជាប់ចោទក៏បានសារភាពថា រូបគេពិតជាបានធ្វើសកម្មភាពផ្តឹះសោប៉ងលួចទ្រព្យសម្បត្តិគេមែន ដោយសារតែខ្លួនគ្មានការងារធ្វើនិងគ្មានលុយចាយផង៕

# នគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ស្រាវជ្រាវ និងបង្ក្រាបជនសង្ស័យមុខសញ្ញាប្លន់បាន២នាក់

ស៊ុយ ចាន់ធា 20/7/2017 8:03 Am ព័ត៌មានជាតិ, សន្តិសុខ និងសង្គម

♡ LIKE

**ព្រះសីហនុ ៖** ជនសង្ស័យចំនួន២នាក់ ជាមុខសញ្ញាលួចមានស្ថានទម្ងន់ទោស(ប្លន់) ប្រដាប់ដោយកាំបិតចំនួន២ដើម ត្រូវបានសមត្ថកិច្ចនគរបាលការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ស្រាវជ្រាវ និងបង្ក្រាបចាប់ខ្លួនបាននៅម៉ោងប្រមាណ១យប់រំលងអាធ្រាត្រ ឈានចូលថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧។




សមត្ថកិច្ចបានឲ្យដឹងថា ក្រុមជនសង្ស័យទាំងនេះ កម្លាំងជំនាញចាប់ខ្លួនដោយយោងតាមពាក្យបណ្តឹងរបស់ជនរងគ្រោះ ឈ្មោះ ស្រ៊ិន វ៉ានីន ភេទស្រី អាយុ២៨ឆ្នាំ មុខរបរមេផ្ទះ រស់នៅក្រុម២២ ភូមិ១ សង្កាត់២ ក្រុង-ខេត្តព្រះសីហនុ ដែលបានប្តឹងនៅព្រឹកថ្ងៃទី១៧ កក្កដា កន្លងមកនេះ។សមត្ថកិច្ចបន្តថា ជនសង្ស័យដែលបង្ក្រាបបាននេះមាន ១/ឈ្មោះ ជាម ប្រុស ហៅប្រុស អាយុ៣២ឆ្នាំ (ជាជនដៃដល់) មានមុខរបរមិនពិតប្រាកដ ស្នាក់នៅផ្ទះជួលក្នុងភូមិ៤ សង្កាត់លេខ៤ ក្រុង/ខេត្តព្រះសីហនុ និងទី២/ឈ្មោះ ចុង សុខជា ភេទប្រុស អាយុ៣០ឆ្នាំ (ជនដៃដល់)មានមុខរបរមិនពិតប្រាកដ ស្នាក់នៅផ្ទះជួល ក្នុងភូមិ៤ សង្កាត់លេខ២ ក្រុង/ខេត្តព្រះសីហនុ។




សមត្ថកិច្ចបានឲ្យដឹងទៀតថា យោងតាមពាក្យបណ្តឹងបានឲ្យដឹងថា នៅវេលាម៉ោង០០ និង២០នាទីរំលងអាធ្រាត្រ ឈានចូលថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ នាងបានហូបបបរជាមួយមិត្តប្រុស លុះត្រលប់មកផ្ទះវិញត្រង់ចំណុចផ្លូវចាក់បេតុង ស្ថិតនៅក្រុមទី២២ ភូមិ១ សង្កាត់២ ក្រុង-ខេត្តព្រះសីហានុ ស្រាប់តែមានជនមិនស្គាល់មុខចំនួន២នាក់ ជិះម៉ូតូ១គ្រឿងមិនស្គាល់ម៉ាក បានស្ទាក់ពីមុខម៉ូតូ ដែលជាហេតុធ្វើឱ្យម៉ូតូនាងខ្ញុំដួលទៅលើដី ហើយពួកវាទាំងពីរនាក់កាន់កាំបិតម្នាក់១ដើម ភ្ជង់គំរាមកាប់នាងខ្ញុំ និងមិត្តប្រុសខ្ញុំ បើមិនព្រមឱ្យពួកវាទេនឹងចាក់កាប់សម្លាប់ចោល។ ក្នុងករណីនេះ ក្រុមជនសង្ស័យបានប្លន់យកទ្រព្យសម្បត្តិពីជនរងគ្រោះមានដូចជា ម៉ូតូម៉ាកហុងដា ZOOMER-X ពណ៌ក្រហម ១គ្រឿង សេរីឆ្នាំ២០១៦, ទូរស័ព្ទម៉ាក i-Phone 7Plus ពណ៌ខ្មៅ ២គ្រឿង និងលុយ ៣០០ដុល្លារ។




សមត្ថកិច្ចបានឲ្យដឹងទៀតថា ក្រោយពេលឃាត់ខ្លួនជនសង្ស័យទាំង២នាក់ខាងលើនេះ ក្រុមសមត្ថកិច្ចបានធ្វើការដកហូតវត្ថុតាងរួមមាន ម៉ូតូម៉ា ZOOMER-X ១គ្រឿង (ផលចោរកម្ម), ម៉ូតូម៉ាកអ៊ែប្លែត ១គ្រឿង (មធ្យោបាយធ្វើសកម្មភាព), ទូរស័ព្ទដៃចំនួន ៨គ្រឿង (ម៉ាក i-Phone 7 Plus ២គ្រឿង ផលចោរកម្ម), កាំបិតកាចែត ចំនួន២ដើម (ឧបករណ៍សម្រាប់ប្លន់)។

បច្ចុប្បន្នជនសង្ស័យ និងវត្ថុតាង ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់កំពុងបន្តនីតិវិធី បញ្ជូនទៅសាលាដំបូងខេត្តព្រះសីហានុ ដើម្បីផ្តន្ទាទោសទៅតាមផ្លូវច្បាប់៕

# ចោរឆក់កាបូប បណ្តាលឲ្យស្ត្រីម្នាក់ដួលរបួសធ្ងន់នៅស្វាយប៉ាក

2,645
SHARE

Share

**រាជធានីភ្នំពេញ៖** ស្ត្រីម្នាក់បានរងរបួសធ្ងន់ និងត្រូវបានបញ្ជូនទៅសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យកាល់ម៉ែត្រ ដោយសារចោរឆក់កាបូប ។

ហេតុការណ៍នេះបានកើតឡើង នៅវេលាម៉ោង១ និង២០នាទីរសៀល ថ្ងៃទី១៦ កញ្ញា ២០១៦ នៅតាមបណ្តោយផ្លូវជាតិលេខ៥ ចំណុចភូមិ-សង្កាត់ស្វាយប៉ាក ខណ្ឌឬស្សីកែវ។

ស្ត្រីរងគ្រោះឈ្មោះ អ៊ុច សុគន្ធា អាយុ៤៣ឆ្នាំ ជាបុគ្គលិកអង្គការផ្ទះនាងរហាត់ជួយសង្គ្រោះកុមារកំព្រានិងជួញដូរផ្លូវភេទ មានទីលំនៅក្នុងភូមិចំរើនផល សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ ។

បើតាមអ្នកឆ្លើយឆ្លង ព័ត៌មានកោះសន្តិភាព បានឲ្យដឹងថា មុនពេលកើតហេតុ ស្ត្រីរងគ្រោះជិះម៉ូតូម៉ាកហុងដាគ្លិក ពណ៌ផ្កាឈូកលាយខ្មៅ ពាក់ស្លាកលេខភ្នំពេញ 1V 4923 ក្នុងទិសដៅពីត្បូងទៅជើង លុះមកដល់ចំណុចកើតហេតុក៏ លេចមុខជនសង្ស័យ២នាក់ជិះម៉ូតូអែប នឹងឆក់កាបូបដែលស្ត្រីរងគ្រោះ ដាក់នៅពីមុខរានខាង មុខ បណ្តាលឲ្យទាក់ដៃចង្កូតដួល បោកក្បាលរបួសធ្ងន់តែម្តង ។

សេចក្តីរាយការណ៍បានបន្តថា នៅក្នុងកាបូបដែលចោរឆក់ បានសម្រេចនោះមានលុយ២០០ដុល្លារ និងទូរស័ព្ទម៉ាកសាំសុង១គ្រឿង ៕



# ឆក់ទូរស័ព្ទបានសម្រេចជិះម៉ូតូទៅប៉ះជាមួយរថយន្តអ្នកដំណើរប៉ូលិសចាប់ដាក់ខ្នោះ

ស្រីរ័ត្ន 10/7/2017 9:09 Pm ព័ត៌មានជាតិ, សន្តិសុខ និងសង្គម

♡ LIKE

ភ្នំពេញ ៖ ជនសង្ស័យម្នាក់ក្នុងចំណោមបក្សពួក២នាក់ត្រូវបានកម្លាំងល្បាតរបស់នគរបាលប៉ុស្តិ៍រដ្ឋបាលបឹង សាឡាង ខណ្ឌទួលគោក ឃាត់ខ្លួនបានជាក់ស្តែង ខណៈ ធ្វើសកម្មភាពឆក់ទូរស័ព្ទគេបានសម្រេច ហើយនៅពេលជិះ ម៉ូតូទៅប៉ះជាមួយរថយន្តអ្នកដំណើរ ទើបប៉ូលិសចាប់ដាក់ខ្នោះតែម្តង។

អំពើឆក់នេះបានកើតឡើងកាលពីរសៀលនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ១៦និង០០នាទី នៅចំណុចមុខផ្ទះលេខ៨២សេ ផ្លូវលេខ៦៦៨ ក្រុមទី៣ ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។




ជនសង្ស័យឈ្មោះ ជា វណ្ណថេង ហៅ ថេង ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្សថ្នាក់ទី ១១E1 វិទ្យាល័យ ជា ស៊ីម សាមគ្គី ស្នាក់នៅផ្ទះជួល គ្មានលេខ ផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។



ចំណែកជនរងគ្រោះឈ្មោះ នាង រចនា ភេទស្រី អាយុ ២៤ ឆ្នាំ ជនជាតិខ្មែរ មុខរបរ និស្សិតឆ្នាំទី២( ច្បាប់ )សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ស្នាក់នៅផ្ទះលេខ២៤៤ ផ្លូវ ៣៦៩ ភូមិព្រែកថ្មី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

វត្ថុតាងដែលបានចាប់យក រួមមានទូរស័ព្ទមួយគ្រឿងម៉ាក Samsung Galaxy A7 ពណ៌ស មានស៊ីមលេខ 096 9728913 ( បានប្រ គល់អោយជនរងគ្រោះ )។

ម៉ូតូមួយគ្រឿងម៉ាក Honda C125 ពណ៌ខ្មៅ ស៊េរី២០១១ ពាក់ស្លាកលេខភ្នំពេញ 1AU-4445 មានលេខតួ និងលេខម៉ាស៊ីន 8552935 ( ជាម៉ូតូដែលជនសង្ស័យ ជិះធ្វើសកម្មភាព )។




មន្ត្រីប៉ូលិសខណ្ឌទួលគោកបានឲ្យដឹងថា នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១៦និង០០នាទី ជនរងគ្រោះឈ្មោះនាង រចនា បានម៉ូតូម៉ាក Honda Scoopy ពណ៌ស ស៊េរី២០១៥ ពាក់ស្លាកលេខភ្នំពេញ 1CY-2673 តាម បណ្តោយផ្លូវលេខ៦៦៤ ពីលិចមកកើត ពេលមកដល់ ចំណុចកើតហេតុ ជនរងគ្រោះបានដកទូរស័ព្ទចេញពីកាបូបមកកាន់បម្រុងទំនាក់ទំនងទៅមិត្តភក្តិ ស្រាប់តែជនសង្ស័យពីរនាក់ជិះម៉ូតូតាមពីក្រោយ ទន្ទឹមអែបខាង ឆ្វេង ធ្វើសកម្មភាពឆក់យកទូរស័ព្ទពីជនរងគ្រោះបាន សម្រេច ហើយព្យាយាមជិះម៉ូតូគេចខ្លួន ដោយជនរង គ្រោះជិះម៉ូតូដេញតាមពីក្រោយព្រមទាំងស្រែកចោរៗ ជនសង្ស័យបានជិះ ម៉ូតូទៅប៉ះជាមួយរថយន្តអ្នកដំណើរបណ្តាលឲ្យដួលម៉ូតូ។ ភ្លាមនោះមានការអន្តរាគមន៍ពី កម្លាំងនគរបាលប៉ុស្តិ៍បឹងសាឡាង ដែលកំពុងល្បាតការពារសុវត្ថិភាពនៅក្នុងមូលដ្ឋាន ឃាត់ខ្លួនបានជន សង្ស័យម្នាក់ជាក់ស្តែង ចំណែកជនសង្ស័យម្នាក់ទៀតបានរត់គេចខ្លួនបាត់។

បច្ចុប្បន្នជនសង្ស័យខាងលើ កំពុងឃាត់ខ្លួនជាបណ្តោះ អាសន្ននៅអធិការដ្ឋាននគរបាលខណ្ឌទួលគោក ដើម្បីសាកសួរ និងកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានីភ្នំពេញ ចាត់ការតាមផ្លូវច្បាប់៕



ការពិភាក្សាច្បាប់

# ការប្រៀបធៀប បទលួចមានស្ថានទម្ងន់ដោយសារការប្រព្រឹត្តអំពើហិង្សា និង បទកំហែងយក

=============

## វិសាលភាពនៃការបកស្រាយ

បទលួចមានស្ថានទម្ងន់ដោយសារការប្រព្រឹត្តអំពើហិង្សា និងបទកំហែងយក នៅក្នុងតារាងប្រៀបធៀបនេះ ត្រូវបានបកស្រាយផ្អែកតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

| លក្ខណៈវិនិច្ឆ័យ | | ភាពដូចគ្នាវាង<br>បទលួចមានស្ថានទម្ងន់ដោយសារការប្រព្រឹត្តអំពើហិង្សា និង បទកំហែងយក | ភាពខុសគ្នា<br>បទលួចមានស្ថានទម្ងន់ដោយសារការប្រព្រឹត្តអំពើហិង្សា | ភាពខុសគ្នា<br>បទកំហែងយក |
|---|---|---|---|---|
| នីត្យានុកូលភាពនៃបទល្មើស | | -បទល្មើសប្រឆាំងនឹងទ្រព្យ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ គន្ថីទី ៣ មាតិកាទី ១ ជំពូកទី ១ ស្តីពី ការលួច និង បទល្មើសប្រហាក់ប្រហែល។ | -បទល្មើសដែលមានចែងក្នុងមាត្រា ៣៥៣ នៃក្រម ព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ។ | -បទល្មើសដែលមានចែងក្នុងមាត្រា ៣៦៣ នៃក្រម ព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ។ |
| នីត្យានុកូលភាពនៃទោស | | គ្មាន | បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៣ ឆ្នាំ ទៅ ១០ ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ។ | បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លាន រៀល ទៅ ១០ លាន រៀល តាមមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។ |
| ចរិកគ្រោះថ្នាក់នៃបទល្មើស | | គ្មាន | កម្រិតទោសឧក្រិដ្ឋ<br>(ចិរកគ្រោះថ្នាក់ធ្ងន់ធ្ងរ) | កម្រិតទោសមជ្ឈិម<br>(ចិរកគ្រោះថ្នាក់មធ្យម) |
| កម្មវត្ថុនៃបទល្មើស | | ១-បូរណភាពនៃសិទ្ធិកម្មសិទ្ធិលើទ្រព្យសម្បត្តិអ្នកដទៃ(ចម្បង)<br>២-បូរណភាពលើរូបបុគ្គល (បន្ទាប់បន្សំ) ហើយមាន លក្ខណៈមិនដាច់ខាត "អាចមាន ឬគ្មានការបំពាន") | -បូរណភាពនៃសិទ្ធិលើលំនៅដ្ឋាន "ជីវភាពឯកជន"<br>(បន្ទាប់បន្សំ) | គ្មានការបំពានលើបូរណភាពនៃសិទ្ធិលើលំនៅដ្ឋាន |
| ប្រធាននៃបទល្មើស | | រូបវន្តបុគ្គល "ទូទៅ" | គ្មាន | |
| មុខសញ្ញានៃបទល្មើស | | ទ្រព្យសម្បត្តិអ្នកដទៃ | ទ្រព្យសម្បត្តិអ្នកដទៃ | ១.ហត្ថលេខា ឬស្នាមម្រាមដៃ ២.ការសន្យា ឬការបោះបង់ចោលអ្វីមួយ ៣.ការបង្ហាញអាថ៌កំបាំងណាមួយ ៤.ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ។ |
| ធាតុសម្ភារៈ | រូបរាងនៃអំពើ | អំពើយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើកម្មសិទ្ធិផ្ទាល់ខ្លួន ដោយទុច្ចរិត | ដកហូតយក ឬដណ្តើមយកទ្រព្យពីជនរងគ្រោះ | ទទួលបាននូវទ្រព្យពីជនរងគ្រោះ តាមរយៈការប្រគល់ឱ្យ ដោយឆន្ទៈមិនពិតប្រាកដ និងមិនដោយសេរី |
| | លក្ខណៈនៃអំពើ | អំពើសកម្ម | អំពើនោះមិនទុកលទ្ធភាពឱ្យជនរងគ្រោះអាចសម្រេចអំពី ឆន្ទៈព្រមប្រគល់ ឬមិនប្រគល់ឡើយ | អំពើនោះទុកលទ្ធភាពឱ្យជនរងគ្រោះអាចសម្រេចអំពី ឆន្ទៈព្រមប្រគល់ ឬមិនប្រគល់ |
| | មធ្យោបាយប្រព្រឹត្តបទល្មើស | អាចមានការប្រើហិង្សាដូចគ្នា | ១.អំពើលួចប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេល ប្រើហិង្សា<br>២.អំពើលួចប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ | ការកំហែងយកប្រព្រឹត្តដោយប្រើហិង្សា ការគំរាមកំហែងថា នឹងប្រើហិង្សា ឬ ដោយការបង្ខិតបង្ខំ |
| | លក្ខណៈនៃបច្ច័យ | មានលក្ខណៈមិនដាច់ខាត/ប្រកាន់យកទ្រឹស្តីនៃនីតិអត្តវិស័យ [ជនរងគ្រោះអាចបាត់ ឬមិនបាត់បង់ទ្រព្យសម្បត្តិ(ការប៉ុនប៉ង)] | គ្មាន | |



រៀបចំដោយ ៖ មួន សៀងលី
ជំនួយការរៀបចំដោយ ៖ ហេង សុផារិទ្ធ

| ធាតុអត្តនោម័ត | កំហុស | ចេតនាប្រព្រឹត្តអំពើ និងទទួលយកលទ្ធផលនៃអំពើ | ចេតនាទុច្ចរិតទូទៅ | ចេតនាទុច្ចរិតទូទៅ/ចេតនាទុច្ចរិតពិសេស[1] |
|---|---|---|---|---|
| | គោលបំណង | -ចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន និង អាចមានគោលបំណងបន្ថែមផ្សេងទៀត (គោលបំណងបន្ទាប់បន្សំ) ដើម្បីសម្រេចគោលដៅចុងក្រោយ (ជាអាទិ៍ គោលបំណងបំពានលើរូបបុគ្គលតាមរយៈការប្រើហិង្សាលើម្ចាស់ទ្រព្យ ឬអ្នកគ្រប់គ្រង ថែរក្សាទ្រព្យសម្បត្តិនោះ)។ | -គោលបំណងបំពានលើរូបបុគ្គល និង/ឬ<br>-គោលបំណងបំពានលើសិទ្ធិលើលំនៅដ្ឋាន។ | -គោលបំណងបំពានលើរូបបុគ្គល |
| | | | ករណីដែលមានគោលបំណងបំពាន "បូរណភាពលើអាយុជីវិតមនុស្ស" ដើម្បីសម្រេចនូវគោលដៅចុងក្រោយ យកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន នឹងនាំឲ្យចរិកគ្រោះថ្នាក់នៃអំពើនោះវិវត្តន៍ទៅជាបទឃាតកម្ម។ *"ចេតនាសម្លាប់មនុស្សដើម្បីយកទ្រព្យអ្នកដទៃ"* | |
| | គោលដៅ | ចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន | *គ្មាន* | |

[1] ជនល្មើសមានចេតនាចង់ឲ្យបទល្មើសដែលខ្លួនប្រព្រឹត្តផ្តល់នូវផលពិសេសណាមួយ ។ ចេតនាតុច្ឆរិតពិសេស ក៏អាចកើតចេញពីអំពើមួយទៀត ដែលជនល្មើសគ្រោងទុក ។